ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត
(គ.ជ.ប)

# របាយការណ៍
## ស្តីពី
## ការគ្រប់គ្រង និងការប្រព្រឹត្តទៅនៃការបោះឆ្នោតជ្រើសរើស ក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី៥ ឆ្នាំ២០២២

# មាតិកា

I- **សេចក្តីផ្តើម** ........ ១

II- **ក្របខ័ណ្ឌច្បាប់ និងផែនការ** ........ ២

**១- ក្របខ័ណ្ឌច្បាប់** ........ ២

**២- ផែនការ** ........ ៤

III- **រចនាសម្ព័ន្ធរដ្ឋបាល និងការងារមន្ត្រីបុគ្គលិក** ........ ៥

**១- រចនាសម្ព័ន្ធរដ្ឋបាល គ.ជ.ប** ........ ៥

១.១- សមាសភាព គ.ជ.ប ........ ៥

១.២- សមាសភាពអគ្គលេខាធិការ និងអគ្គលេខាធិការរង ........ ៦

**២- រចនាសម្ព័ន្ធថ្នាក់ក្រោម គ.ជ.ប** ........ ៦

២.១- ដំណាក់កាលនៃការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោត ឆ្នាំ២០២១ ........ ៦

២.២- ដំណាក់កាលនៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី៥ ឆ្នាំ២០២២ ........ ៦

**៣- រចនាសម្ព័ន្ធអគ្គលេខាធិការដ្ឋាននៃ គ.ជ.ប** ........ ៦

**៤- ការងារមន្ត្រី បុគ្គលិក** ........ ៧

៤.១- ដំណាក់កាលនៃការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោត ឆ្នាំ២០២១ ........ ៧

ក- នៅថ្នាក់ គ.ជ.ប ........ ៧

ខ- នៅថ្នាក់ក្រោម ........ ៧

៤.២- ដំណាក់កាលនៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី៥ ឆ្នាំ២០២២ ........ ៧

ក- នៅថ្នាក់ គ.ជ.ប ........ ៨

ខ- នៅថ្នាក់ក្រោម ........ ៨

៤.៣- ផលប៉ះពាល់ និងវិធានការទប់ស្កាត់ការឆ្លងរាលដាលជំងឺកូវីដ-១៩ ........ ៨

IV- **ការគ្រប់គ្រង និងការប្រព្រឹត្តទៅនៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី៥ ឆ្នាំ២០២២** ........ ៨

**១- ការងារហិរញ្ញវត្ថុ** ........ ៨

១.១- ដំណាក់កាលនៃការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោត ឆ្នាំ២០២១ ........ ៨

ក- ថវិកាចំណូល ........ ៨

ខ- ថវិកាចំណាយ ........ ៩

១.២- ដំណាក់កាលនៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី៥ ឆ្នាំ២០២២ ........ ៩

ក- ថវិកាចំណូល ...................................................................... ៩
ខ- ថវិកាចំណាយ ...................................................................... ៩
**២- ការងារបណ្តុះបណ្តាល និងអប់រំអ្នកបោះឆ្នោត** ...................................................................... ៩
២.១- ការចុះបញ្ជីបេក្ខជនបេក្ខជនគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត
និងការឃោសនាបោះឆ្នោត ...................................................................... ៩
ក- នៅថ្នាក់ គ.ជ.ប ...................................................................... ៩
ខ- នៅថ្នាក់ គធ.ខប ...................................................................... ១០
គ- នៅថ្នាក់ គឃ.សប ...................................................................... ១០
២.២- ការបោះឆ្នោត និងការរាប់សន្លឹកឆ្នោត ...................................................................... ១០
ក- នៅថ្នាក់ គ.ជ.ប ...................................................................... ១០
ខ- នៅថ្នាក់ គធ.ខប ...................................................................... ១០
គ- នៅថ្នាក់ គឃ.សប ...................................................................... ១០
២.៣- ការថត បញ្ជូន និងបញ្ចូលទិន្នន័យប្រព័ន្ធទីតាំងសកល (GPS)
នៃទីតាំងការិយាល័យបោះឆ្នោត ...................................................................... ១១
**៣- ការងារអប់រំសាធារណជន** ...................................................................... ១១
**៤- ការផ្សព្វផ្សាយ និងការបញ្ជ្រាបការយល់ដឹងអំពីសារៈសំខាន់នៃការបោះឆ្នោតនៅតាមរាជធានី ខេត្ត** ...................................................................... ១៣
**៥- ការងារព័ត៌មាន និងទំនាក់ទំនងសាធារណៈ** ...................................................................... ១៣
៥.១- ការងារព័ត៌មាន ...................................................................... ១៣
៥.២- ការងារទំនាក់ទំនងសាធារណៈ ...................................................................... ១៣
ក- ក្រសួង ស្ថាប័នជាតិ ...................................................................... ១៤
ខ- ស្ថាប័នអន្តរជាតិ ...................................................................... ១៤
៥.៣- កម្មវិធីស្វែងយល់អំពីការបោះឆ្នោត ...................................................................... ១៤
ក- ផ្សព្វផ្សាយតាមទូរទស្សន៍ ...................................................................... ១៤
ខ- ផ្សព្វផ្សាយតាមវិទ្យុ ...................................................................... ១៥
៥.៤- កម្មវិធីស្មើភាពផ្សព្វផ្សាយអំពីគោលនយោបាយរបស់គណបក្ស ...................................................................... ១៥
៥.៥- កម្មវិធីស្វែងយល់អំពីសារៈសំខាន់នៃការបោះឆ្នោតផ្សព្វផ្សាយដោយ គធ.ខប ...................................................................... ១៥
៥.៦- កិច្ចសម្ភាសន៍តាមប្រព័ន្ធអនឡាញ ...................................................................... ១៦
**៦- ការងារប្រតិបត្តិការ និងភស្តុភារ** ...................................................................... ១៦
៦.១- ការងារប្រតិបត្តិការ និងបច្ចេកទេស ...................................................................... ១៦
៦.១.១- ការបិទផ្សាយបញ្ជីឈ្មោះទីតាំងការិយាល័យចុះឈ្មោះបោះឆ្នោត ...................................................................... ១៦

៦.១.២- ការបញ្ជាទិញ និងការបែងចែកសម្ភារ បរិក្ខារ និងឯកសារផ្សេងៗ .......................១៦
៦.១.៣- ការបែងចែកសម្ភារបរិក្ខារកុំព្យូទ័រ និងឯកសារផ្សេងៗ ......................................១៧
៦.១.៤- ការបញ្ជាទិញទឹកខ្មៅលុបមិនជ្រះ ......................................................................១៧
៦.១.៥- ការបោះពុម្ពសន្លឹកឆ្នោត .......................................................................................១៨
៦.១.៦- ការផលិត និងការចែកប័ណ្ណព័ត៌មានអ្នកបោះឆ្នោត ............................................ ១៨
៦.១.៧- ការបង្កើតកម្មវិធីគ្រប់គ្រងការចេញ ឯ.អ ..............................................................១៩
៦.១.៨- ការបង្កើតកម្មវិធីគ្រប់គ្រងការចុះបញ្ជីបេក្ខជននៃគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត ....១៩
៦.១.៩- ការបង្កើតកម្មវិធីត្រួតពិនិត្យ ផ្ទៀងផ្ទាត់ និងបូកសរុបលទ្ធផលនៃការបោះឆ្នោត ...........២០
៦.១.១០-ការប្រើប្រាស់កម្មវិធីថត បញ្ជូន និងបញ្ចូលទិន្នន័យប្រព័ន្ធទីតាំងសកល (GPS) នៃទីស្នាក់ការ (គឃ.សប) សាលាឃុំ សង្កាត់ ទីតាំងការិយាល័យបោះឆ្នោត និងទីតាំង (គធ.ខប) ......២០
៦.២- ការងារភស្តុភារ និងដឹកជញ្ជូនសម្ភារបរិក្ខារ .................................................... ២០
**៧- ការចុះបញ្ជីបេក្ខជននៃគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត** ................................. ២១
៧.១- ការត្រៀមរៀបចំបញ្ជីបេក្ខជននៃគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត .................. ២១
៧.២- ដំណាក់កាលចុះបញ្ជីបេក្ខជននៃគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត ................. ២១
៧.៣- ការចាប់ឆ្នោតដើម្បីកំណត់លំដាប់លេខរៀងបញ្ជីបេក្ខជន...........................................២៣
**៨- ការចុះឈ្មោះអ្នកសង្កេតការណ៍ អ្នកសារព័ត៌មាន និងភ្នាក់ងារគណបក្សនយោបាយ** ..................២៣
៨.២- អ្នកសង្កេតការណ៍អន្តរជាតិ ..................................................................................... ២៣
៨.៣- ភ្ញៀវពិសេស ......................................................................................................... ២៣
៨.៤- អ្នកសារព័ត៌មានជាតិ ............................................................................................. ២៤
៨.៥- អ្នកសារព័ត៌មានអន្តរជាតិ ..................................................................................... ២៤
៨.៦- ភ្នាក់ងារគណបក្សនយោបាយ .................................................................................. ២៤
**៩- ការឃោសនាបោះឆ្នោត** ........................................................................................... ២៤
**១០- ការបោះឆ្នោត ការរាប់សន្លឹកឆ្នោត និងការបិទផ្សាយលទ្ធផលនៅការិយាល័យបោះឆ្នោត** ...................... ២៥
១០.១- ការបើកការិយាល័យបោះឆ្នោត .............................................................................. ២៥
១០.២- ការបិទការិយាល័យបោះឆ្នោត ............................................................................... ២៥
១០.៣- ការរាប់សន្លឹកឆ្នោត និងការបិទផ្សាយលទ្ធផលបឋមនៅការិយាល័យបោះឆ្នោត .............. ២៥
១០.៤- ការសម្របសម្រួល ការបញ្ចូល ការបញ្ជូនទិន្នន័យលទ្ធផលបឋមមក គ.ជ.ប ...................... ២៥
១០.៥- ការត្រួតពិនិត្យ និងការបូកសរុបលទ្ធផលបណ្ដោះអាសន្ននៅ គឃ.សប ...........................២៦
១០.៦- ការត្រួតពិនិត្យផ្ទៀងផ្ទាត់លទ្ធផលនៃការបោះឆ្នោតក្នុងឃុំ សង្កាត់ ការបែងចែកអាសនៈ និងការស្រង់ឈ្មោះបេក្ខជនជាប់ឆ្នោតនៅ គធ.ខប .........................................២៧
១០.៧- ការទទួលសម្ភារ ឯកសារ ការត្រួតពិនិត្យផ្ទៀងផ្ទាត់លទ្ធផលឡើងវិញ ការកំណត់បែងចែកអាសនៈនៅ គ.ជ.ប .........................................................២៨
១០.៧.១- ការទទួលសម្ភារ ឯកសារបោះឆ្នោតពី គធ.ខប ..................................... ២៨

១០.៧.២- ការត្រួតពិនិត្យលទ្ធផលឡើងវិញនៅ គ.ជ.ប ........................................ ២៨
១០.៧.៣- ការកំណត់បែងចែកអាសនៈនៅ គ.ជ.ប ........................................២៩
១០.៨- របាយការណ៍ស្តីពីការផ្ទៀងផ្ទាត់ និងការប្រើប្រាស់សន្លឹកឆ្នោត ........................................ ២៩
១០.៩- លទ្ធផលផ្លូវការនៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី៥ ឆ្នាំ២០២២ ...៣០
១០.១០- ការផ្សព្វផ្សាយលទ្ធផលផ្លូវការ........................................ ៣០
**១១- ការដាក់ ការទទួល និងការដោះស្រាយពាក្យបណ្តឹង** ........................................ ៣០
១១.១- ដំណាក់កាលចុះបញ្ជីបេក្ខជននៃគណបក្សនយោបាយ ........................................៣០
ក- ការដាក់ ការទទួល និងការដោះស្រាយពាក្យបណ្តឹងនៅ គឃ.សប ........................................ ៣១
ខ- ការដាក់ ការទទួល និងការដោះស្រាយពាក្យបណ្តឹងនៅ គធ.ខប ........................................ ៣១
គ- ការដាក់ ការទទួល និងការដោះស្រាយពាក្យបណ្តឹងនៅ គ.ជ.ប ........................................ ៣២
១១.២-ដំណាក់កាលឃោសនាបោះឆ្នោត ........................................ ៣២
ក- ការដាក់ ការទទួល និងការដោះស្រាយពាក្យបណ្តឹងនៅ គឃ.សប ........................................៣២
ខ- ការដាក់ ការទទួល និងការដោះស្រាយពាក្យបណ្តឹងនៅ គធ.ខប ........................................៣៣
គ- ការដាក់ ការទទួល និងការដោះស្រាយពាក្យបណ្តឹងនៅ គ.ជ.ប ........................................ ៣៣
១១.៣-ដំណាក់កាលមួយថ្ងៃមុនថ្ងៃបោះឆ្នោត និងក្នុងថ្ងៃបោះឆ្នោត និងរាប់សន្លឹកឆ្នោត និងបិទផ្សាយលទ្ធផលបណ្តោះអាសន្ន ........................................ ៣៣
ក- ពាក្យបណ្តឹងមួយថ្ងៃមុនថ្ងៃបោះឆ្នោត ក្នុងថ្ងៃបោះឆ្នោត និងរាប់សន្លឹកឆ្នោត ........................................៣៣
ក.១- ការដាក់ ការទទួល និងការដោះស្រាយពាក្យបណ្តឹងនៅ គឃ.សប ........................................ ៣៣
ក.២- ការដាក់ ការទទួល និងការដោះស្រាយពាក្យបណ្តឹងនៅ គធ.ខប ........................................ ៣៤
ក.៣- ការដាក់ ការទទួល និងការដោះស្រាយពាក្យបណ្តឹងនៅ គ.ជ.ប ........................................ ៣៤
ខ- ពាក្យបណ្តឹងតវ៉ានឹងការបិទផ្សាយលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោត ........................................ ៣៤
V- **ការថែរក្សាសន្តិសុខ និងសណ្តាប់ធ្នាប់** ........................................៣៤
VI- **ការងាយស្រួល និងការលំបាក** ........................................ ៣៦
**១- ការងាយស្រួល** ........................................៣៦
**២- ការលំបាក** ........................................៣៦
VII- **សំណូមពរ** ........................................៣៨
VIII- **សេចក្តីសន្និដ្ឋាន** ........................................៣៩

# ឧបសម្ព័ន្ធ

**ឧបសម្ព័ន្ធទី១** ប្រតិទិន និងផែនការមេសម្រាប់ការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោត ឆ្នាំ២០២១

**ឧបសម្ព័ន្ធទី២** ប្រតិទិន និងផែនការមេសម្រាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី៥ ឆ្នាំ២០២២

**ឧបសម្ព័ន្ធទី៣** របាយការណ៍ចំណូល-ចំណាយសម្រាប់ការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោត ឆ្នាំ២០២១

**ឧបសម្ព័ន្ធទី៤** របាយការណ៍ចំណូល-ចំណាយសម្រាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី៥ឆ្នាំ២០២២

**ឧបសម្ព័ន្ធទី៥** តារាងបូកសរុបលទ្ធផលនៃការផ្តល់ប័ណ្ណព័ត៌មានអ្នកបោះឆ្នោត

**ឧបសម្ព័ន្ធទី៦** របាយការណ៍ផ្លូវការស្តីពីការចេញឯកសារបញ្ជាក់អត្តសញ្ញាណ

**ឧបសម្ព័ន្ធទី៧** លទ្ធផលផ្លូវការនៃការចុះបញ្ជីបេក្ខជននៃគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត

**ឧបសម្ព័ន្ធទី៨** លទ្ធផលផ្លូវការនៃការចុះឈ្មោះអ្នកសង្កេតការណ៍ជាតិ

**ឧបសម្ព័ន្ធទី៩** លទ្ធផលផ្លូវការនៃការចុះឈ្មោះអ្នកសង្កេតការណ៍អន្តរជាតិ

**ឧបសម្ព័ន្ធទី១០** លទ្ធផលផ្លូវការនៃការចុះឈ្មោះភ្ញៀវពិសេស

**ឧបសម្ព័ន្ធទី១១** លទ្ធផលផ្លូវការនៃការផ្តល់ប័ណ្ណសម្គាល់អ្នកសារព័ត៌មានជាតិ

**ឧបសម្ព័ន្ធទី១២** លទ្ធផលផ្លូវការនៃការផ្តល់ប័ណ្ណសម្គាល់អ្នកសារព័ត៌មានអន្តរជាតិ

**ឧបសម្ព័ន្ធទី១៣** លទ្ធផលផ្លូវការនៃការចុះឈ្មោះភ្នាក់ងារគណបក្សនយោបាយ

**ឧបសម្ព័ន្ធទី១៤** ចំនួនអ្នកទៅបោះឆ្នោត (មាននៅក្នុងតារាងលទ្ធផលផ្លូវការនៃការបោះឆ្នោត)

**ឧបសម្ព័ន្ធទី១៥** លទ្ធផលផ្លូវការនៃការបោះឆ្នោត (តារាងគណបក្សនយោបាយទទួលបានអាសនៈ)។

# អក្សរកាត់

| | | |
|---|---|---|
| ១. | គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត | គ.ជ.ប |
| ២. | គណៈបញ្ជាការសន្តិសុខអចិន្ត្រៃយ៍សម្រាប់ការបោះឆ្នោត | គ.ស.អ |
| ៣. | គណៈកម្មការរាជធានី ខេត្តរៀបចំការបោះឆ្នោត | គធ.ខប |
| ៤. | លេខាធិការដ្ឋាននៃគណៈកម្មការរាជធានី ខេត្តរៀបចំការបោះឆ្នោត | លគធ.ខប |
| ៥. | ក្រុមប្រឹក្សាឃុំ សង្កាត់ | កបឃ.ស |
| ៦. | គណៈកម្មការឃុំ សង្កាត់រៀបចំការបោះឆ្នោត | គឃ.សប |
| ៧. | គណៈកម្មការការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោត | គ.ក.ប/គ.ក.រ |
| ៨. | ច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត | ច.គ.ជ.ប |
| ៩. | ច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ និងច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់នេះ | ច.ប.ឃ.ស |
| ១០. | ច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ និងច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់នេះ | ច.ប.ត.រ |
| ១១. | បទបញ្ជា និងនីតិវិធីសម្រាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ | ប.ន.ឃ.ស |
| ១២. | អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ | អ.ខ |
| ១៣. | ឯកសារបញ្ជាក់អត្តសញ្ញាណបម្រើឱ្យការបោះឆ្នោត | ឯ.អ |
| ១៤. | ទម្រង់បែបបទលេខ | ទ. |

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត**
**លេខ ០០៣ គ.ជ.ប.រ.ង**

# របាយការណ៍
# ស្តីពី
# ការគ្រប់គ្រង និងការប្រព្រឹត្តទៅនៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី ៥ ឆ្នាំ២០២២

## I- សេចក្តីផ្តើម

តាមរដ្ឋធម្មនុញ្ញ និងច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត (ច.គ.ជ.ប) គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត គឺជាអង្គការដែលមានសមត្ថកិច្ចរៀបចំចាត់ចែង និងគ្រប់គ្រងការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា និងការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ព្រមទាំងការបោះឆ្នោតផ្សេងទៀតតាមការកំណត់នៃច្បាប់។

យោងតាមច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ និងច្បាប់ស្តីពីការរៀបចំការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ រាជរដ្ឋាភិបាលបានប្រកាសកំណត់យកថ្ងៃទី៥ ខែមិថុនា ឆ្នាំ២០២២ ជាថ្ងៃបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី៥ និងបានចេញអនុក្រឹត្យជាបន្តបន្ទាប់បង្កើតឃុំ សង្កាត់ថ្មីចំនួន ៦ នៅខេត្តចំនួន ៥ ដែលនាំឱ្យចំនួនឃុំ សង្កាត់ដែលជាមណ្ឌលបោះឆ្នោតសរុបកើនឡើងដល់ ១,៦៥២ និងបានកំណត់ចំនួនក្រុមប្រឹក្សាឃុំ សង្កាត់សរុបចំនួន ១១,៦២២រូប សម្រាប់ឃុំ សង្កាត់ទាំង ១,៦៥២ ពោលគឺសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់កើន ៥០រូប បើប្រៀបធៀបនឹងការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី៤ ឆ្នាំ២០១៧។

ការរៀបចំការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី៥ បានប្រព្រឹត្តទៅក្នុងសភាពការណ៍សង្គមសេដ្ឋកិច្ចកម្ពុជាឆ្លងកាត់ការលំបាកនៃវិបត្តិជំងឺកូវីដ-១៩។ ប៉ុន្តែដោយសារការយកចិត្តទុកដាក់ចាត់វិធានការគ្រប់រូបភាពក្នុងការប្រយុទ្ធប្រឆាំង ការបង្ការ និងទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ ពីសំណាក់រាជរដ្ឋាភិបាលកម្ពុជា ក្រសួង ស្ថាប័នពាក់ព័ន្ធ អាជ្ញាធរគ្រប់លំដាប់ថ្នាក់ក៏ដូចជាប្រជាពលរដ្ឋទូទាំងប្រទេស និងដោយមានកិច្ចសហការឧបត្ថម្ភល្អពីអង្គការអន្តរជាតិ និងប្រទេសជាមិត្ត ស្ថានភាពប្រឈមបានធូរស្រាលជាបន្តបន្ទាប់ កម្ពុជាអាចម្ចាស់ការ និងអាចគ្រប់គ្រងស្ថានការណ៍ឱ្យស្ថិតនៅក្នុងគន្លងប្រក្រតីភាពថ្មី ដែលនេះជាអំណោយផលល្អដល់ដំណើរការរៀបចំការបោះឆ្នោត។

ក្នុងដំណើរការរៀបចំការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី៥ ឆ្នាំ២០២២ រួមទាំងការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោត ឆ្នាំ២០២១ ដើម្បីកសាងបញ្ជីបោះឆ្នោតសម្រាប់ប្រើក្នុងការបោះឆ្នោតផង គ.ជ.ប បានយកចិត្តទុកដាក់ធ្វើការកែលម្អបន្ថែមទៀតលើក្របខ័ណ្ឌបច្ចេកទេស ដោយបានពង្រឹង និងពង្រីកវិសាលភាពនៃការប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានវិទ្យាឱ្យកាន់តែទំនើបក្នុងការគ្រប់គ្រងដំណើរការនៃការបោះឆ្នោតក្នុងនោះមាន

កម្មវិធីគ្រប់គ្រងការចុះបញ្ជីបេក្ខជននៃគណបក្សនយោបាយ កម្មវិធីចេញឯកសារបញ្ជាក់អត្តសញ្ញាណបម្រើឱ្យការបោះឆ្នោត (ឯ.អ) កម្មវិធីត្រួតពិនិត្យផ្ទៀងផ្ទាត់ និងបូកសរុបលទ្ធផលនៃការបោះឆ្នោត។ បន្ថែមលើនោះ ដើម្បីសម្រួលដល់អ្នកបោះឆ្នោត និងភាគីពាក់ព័ន្ធងាយស្រួលក្នុងការស្វែងរកទីតាំងការិយាល័យបោះឆ្នោត ទីតាំងគណៈកម្មការឃុំ សង្កាត់រៀបចំការបោះឆ្នោត (គឃ.សប) ទីតាំងសាលាឃុំ សង្កាត់ និងទីតាំងគណៈកម្មការរាជធានី ខេត្តរៀបចំការបោះឆ្នោត (គធ.ខប) ព្រមទាំងការស្វែងរកឈ្មោះក្នុងបញ្ជីបោះឆ្នោត និងព័ត៌មានផ្សេងៗពាក់ព័ន្ធនឹងការបោះឆ្នោត គ.ជ.ប បានបង្កើតកម្មវិធី App NEC KH និងបានដាក់ឱ្យដំណើរការជាផ្លូវការលើប្រព័ន្ធប្រតិបត្តិការទូរស័ព្ទទំនើប (Smart Phone) ផងដែរ។

## II- ក្របខ័ណ្ឌច្បាប់ និងផែនការ

### ១- ក្របខ័ណ្ឌច្បាប់

ក្របខ័ណ្ឌច្បាប់លិខិតបទដ្ឋាននានា និងផែនការសម្រាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី៥ ឆ្នាំ២០២២ មានដូចខាងក្រោម ៖

- រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- ព្រះរាជក្រមលេខ នស/រកម/០៣១៥/០០២ ចុះថ្ងៃទី២៦ ខែមីនា ឆ្នាំ២០១៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត
- ព្រះរាជក្រមលេខ នស/រកម/០៣១៥/០០៣ ចុះថ្ងៃទី២៦ ខែមីនា ឆ្នាំ២០១៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ
- ព្រះរាជក្រមលេខ នស/រកម/១០១៧/០១០ ចុះថ្ងៃទី២៤ ខែតុលា ឆ្នាំ២០១៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ
- ព្រះរាជក្រមលេខ នស/រកម/០៣០១/០៥ ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់
- ព្រះរាជក្រមលេខ នស/រកម/១២១៥/០១៥ ចុះថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០១៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់
- ព្រះរាជក្រមលេខ នស/រកម/១០១៧/០១២ ចុះថ្ងៃទី២៥ ខែតុលា ឆ្នាំ២០១៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់
- ព្រះរាជក្រមលេខ នស/រកម/១១៩៧/០៧ ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ១៩៩៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីគណបក្សនយោបាយ
- ព្រះរាជក្រមលេខ នស/រកម/០៣១៧/០០៣ ចុះថ្ងៃទី៧ ខែមីនា ឆ្នាំ២០១៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីគណបក្សនយោបាយ
- ព្រះរាជក្រមលេខ នស/រកម/០៧១៧/០០៧ ចុះថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០១៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីគណបក្សនយោបាយ និងច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីគណបក្សនយោបាយ
- ព្រះរាជក្រមលេខ នស/រកម/០១១៩/០០១ ចុះថ្ងៃទី០២ ខែមករា ឆ្នាំ២០១៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មមាត្រា ៤៥ថ្មី (ស្ទួន) នៃច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីគណបក្សនយោបាយ
- ព្រះរាជក្រឹត្យលេខ នស/រកត/០៤១៥/៣២៧ ចុះថ្ងៃទី១០ ខែមេសា ឆ្នាំ២០១៥ ស្តីពីការតែងតាំងគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត
- ព្រះរាជក្រឹត្យលេខ នស/រកត/១២១៧/១១៦៩ ចុះថ្ងៃទី៨ ខែធ្នូ ឆ្នាំ២០១៧ ស្តីពីការតែងតាំងអនុប្រធាន

និងសមាជិកគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតជំនួសអនុប្រធាន និងសមាជិកគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតដែលបានលាឈប់

- ព្រះរាជក្រឹត្យលេខ នស/រកត/០៦២១/៤៩១ ចុះថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០២១ ស្តីពីការតែងតាំងប្រធានគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ជំនួសប្រធានគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតដែលបានលាឈប់
- ព្រះរាជក្រឹត្យលេខ នស/រកត/០៦១៥/៦៤៨ ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០១៥ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីរាជការ នៃគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត
- ព្រះរាជក្រឹត្យលេខ នស/រកត/០១២១/០៤២ ស្តីពីការកែសម្រួលមាត្រា ៩ មាត្រា ១៣ មាត្រា១៨ មាត្រា ២២ មាត្រា ២៤ មាត្រា ៣២ និងមាត្រា ៥១ នៃព្រះរាជក្រឹត្យលេខ នស/រកត/០៦១៥/៦៤៨ ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០១៥ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីរាជការ នៃគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត
- អនុក្រឹត្យលេខ ១១ អនក្រ.បក ចុះថ្ងៃទី២២ ខែមករា ឆ្នាំ២០២១ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃអគ្គលេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត
- អនុក្រឹត្យលេខ ១៥០ អនក្រ.បក ចុះថ្ងៃទី២០ ខែសីហា ឆ្នាំ២០២១ ស្តីពីការបង្កើតឃុំយាយម៉ៅពេជ្រនិល នៃស្រុកភ្នំស្រួច ខេត្តកំពង់ស្ពឺ
- អនុក្រឹត្យលេខ ១៥១ អនក្រ.បក ចុះថ្ងៃទី២០ ខែសីហា ឆ្នាំ២០២១ ស្តីពីការបង្កើតឃុំភ្នំក្រាំងដីមាស នៃស្រុករលាប្អៀរ ខេត្តកំពង់ឆ្នាំង
- អនុក្រឹត្យលេខ ១៥២ អនក្រ.បក ចុះថ្ងៃទី២០ ខែសីហា ឆ្នាំ២០២១ ស្តីពីការបង្កើតឃុំអូរកណ្តៀរសែនជ័យ នៃស្រុកសំបូរ ខេត្តក្រចេះ
- អនុក្រឹត្យលេខ ១៥៣ អនក្រ.បក ចុះថ្ងៃទី២០ ខែសីហា ឆ្នាំ២០២១ ស្តីពីការបង្កើតឃុំបួរិល នៃស្រុកបវេល ខេត្តបាត់ដំបង
- អនុក្រឹត្យលេខ ១៥៦ អនក្រ.បក ចុះថ្ងៃទី២០ ខែសីហា ឆ្នាំ២០២១ ស្តីពីការបង្កើតសង្កាត់អូរជ្រៅ នៃក្រុងប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ
- អនុក្រឹត្យលេខ ១៥៧ អនក្រ.បក ចុះថ្ងៃទី២០ ខែសីហា ឆ្នាំ២០២១ ស្តីពីការបង្កើតសង្កាត់អូរឬស្សី នៃក្រុងប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ
- អនុក្រឹត្យលេខ ១៦៧ អនក្រ.បក ចុះថ្ងៃទី២៦ ខែសីហា ឆ្នាំ២០២១ ស្តីពីការកំណត់ចំនួនសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី៥ ឆ្នាំ២០២២
- សេចក្តីសម្រេចលេខ ៣១ សសរ ចុះថ្ងៃទី១ ខែមីនា ឆ្នាំ២០២១ របស់រាជរដ្ឋាភិបាលកម្ពុជាស្តីពីការប្រកាសកាលបរិច្ឆេទនៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី៥
- សេចក្តីសម្រេចលេខ ០៤៤ គ.ជ.ប.ស.ស.រ ចុះថ្ងៃទី១៩ ខែមេសា ឆ្នាំ២០២១ ស្តីពីការប្រកាសឱ្យប្រើបទបញ្ជាផ្ទៃក្នុងរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត
- សេចក្តីសម្រេចលេខ ០៤៥ គ.ជ.ប.ស.ស.រ ចុះថ្ងៃទី២៩ ខែមេសា ឆ្នាំ២០២១ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃអគ្គនាយកដ្ឋាន នាយកដ្ឋាន និងអង្គភាពផ្សេងៗទៀតចំណុះអគ្គលេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត
- សេចក្តីសម្រេចលេខ ០០៦ គ.ជ.ប.ស.ស.រ ចុះថ្ងៃទី១៣ ខែមករា ឆ្នាំ២០២២ ស្តីពីការដាក់ឱ្យប្រើបទបញ្ជា

និងនីតិវិធីសម្រាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី៥ ឆ្នាំ២០២២

- សេចក្តីណែនាំរួមលេខ ០១៩ ស.ណ.ន ចុះថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០២១ របស់ក្រសួងមហាផ្ទៃ និង គ.ជ.ប ស្តីពីការរៀបចំត្រៀមបម្រើឱ្យការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោតប្រចាំឆ្នាំ
- ផែនការអន្តរស្ថាប័នលេខ ០១០ ផ.ក ចុះថ្ងៃទី២៥ ខែតុលា ឆ្នាំ២០២១ រវាងក្រសួងមហាផ្ទៃ ក្រសួងការពារជាតិ និង គ.ជ.ប ស្តីពីកិច្ចការពារការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោតប្រចាំឆ្នាំ និងការបោះឆ្នោតថ្នាក់ជាតិ ថ្នាក់ក្រោមជាតិចាប់ពីឆ្នាំ២០២២ ដល់ឆ្នាំ២០២៤
- សេចក្តីណែនាំរួមលេខ ០៣៤ ស.ណ.ន ចុះថ្ងៃទី៥ ខែសីហា ឆ្នាំ២០២១ របស់ក្រសួងមហាផ្ទៃ និង គ.ជ.ប ស្តីពីនីតិវិធីនៃការស្នើសុំ និងការចេញឯកសារបញ្ជាក់អត្តសញ្ញាណបម្រើឱ្យការចុះឈ្មោះបោះឆ្នោត និងការបោះឆ្នោត
- សេចក្តីណែនាំរួមលេខ ០០២ សណន ចុះថ្ងៃទី២ ខែមីនា ឆ្នាំ២០២២ របស់ក្រសួងមហាផ្ទៃ និង គ.ជ.ប ស្តីពីការធានានិរន្តរភាពការងាររបស់រដ្ឋបាលឃុំ សង្កាត់ ក្នុងរយៈពេលយុទ្ធនាការឃោសនាបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់
- សេចក្តីណែនាំលេខ ០៣ សណន ចុះថ្ងៃទី២ ខែមិថុនា ឆ្នាំ២០២២ របស់គណៈបញ្ជាការសន្តិសុខអចិន្ត្រៃយ៍ និង គ.ជ.ប ស្តីពីការពង្រឹងសន្តិសុខ សុវត្ថិភាព សម្រាប់ព្រឹត្តិការណ៍បោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី៥ ឆ្នាំ២០២២
- ក្រមសីលធម៌មន្ត្រីបោះឆ្នោត និងភាគីពាក់ព័ន្ធក្នុងដំណើរការបោះឆ្នោត
- សៀវភៅណែនាំសម្រាប់ការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោត និងការបោះឆ្នោត
- សៀវភៅណែនាំសម្រាប់មេភូមិ
- គោលការណ៍នានារបស់ គ.ជ.ប និងលិខិតបទដ្ឋានគតិយុត្តនានា។

គួរកត់សម្គាល់ថា រាល់ការបោះឆ្នោតនីមួយៗ គ.ជ.ប តែងតែរៀបចំតាក់តែងសេចក្តីព្រាងបទបញ្ជា និងនីតិវិធីសម្រាប់ការបោះឆ្នោត ហើយបានផ្ញើជូនទៅគ្រប់ភាគីពាក់ព័ន្ធដូចជា គណបក្សនយោបាយ សមាគម និងអង្គការមិនមែនរដ្ឋាភិបាល និងក្រសួង ស្ថាប័នពាក់ព័ន្ធមួយចំនួន ដើម្បីចូលរួមផ្តល់អនុសាសន៍ ឬមតិយោបល់ដើម្បីកែលម្អនីតិវិធីនៃការបោះឆ្នោតឱ្យកាន់តែល្អប្រសើរឡើង។ ជាក់ស្តែងសេចក្តីព្រាងបទបញ្ជា និងនីតិវិធីសម្រាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី៥ ឆ្នាំ២០២២ ត្រូវបានរៀបចំដោយផ្អែកលើបទបញ្ជា និងនីតិវិធីនៃការបោះឆ្នោត ឆ្នាំ២០១៧ មេរៀនពិសោធន៍កន្លងមក និងច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ ដោយបានបន្ថែមបទប្បញ្ញត្តិស្តីពីការបញ្ចូលប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានវិទ្យាក្នុងដំណើរការរៀបចំ និងការគ្រប់គ្រងការបោះឆ្នោត ដើម្បីជាជំនួយដល់ការអនុវត្តដោយដៃរបស់មន្ត្រីបោះឆ្នោត។ សេចក្តីព្រាងនេះត្រូវបានដាក់ជូនភាគីពាក់ព័ន្ធនានាពិនិត្យ និងផ្តល់អនុសាសន៍មួយជំហានសិន មុននឹងដាក់ជូន គ.ជ.ប សម្រេចអនុម័តជាផ្លូវការនៅថ្ងៃទី៦ ខែមករា ឆ្នាំ២០២២។

## ២- ផែនការ

បន្ថែមលើក្របខ័ណ្ឌច្បាប់ជាធរមាន ក្នុងគោលបំណងធានាឱ្យដំណើរការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី៥ ឆ្នាំ២០២២ ប្រព្រឹត្តទៅដោយរលូន និងទទួលបានជោគជ័យ គ.ជ.ប បានកសាងប្រតិទិន ផែនការ និងបទបញ្ជា និងនិតិវិធីសម្រាប់ជាមូលដ្ឋានក្នុងការអនុវត្តដែលរួមមាន ៖

- ប្រតិទិន និងផែនការមេនៃការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោត ឆ្នាំ២០២១ (ឧបសម្ព័ន្ធ១)
- ប្រតិទិន និងផែនការមេនៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី៥ ឆ្នាំ២០២២ (ឧបសម្ព័ន្ធ២)
- បទបញ្ជា និងនីតិវិធីសម្រាប់ការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោតប្រចាំឆ្នាំ
- បទបញ្ជា និងនីតិវិធីនៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី៥ ឆ្នាំ២០២២
- ផែនការមន្ត្រីក្របខ័ណ្ឌ និងមន្ត្រីជាប់កិច្ចសន្យាសម្រាប់ការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោត ឆ្នាំ២០២១
- ផែនការមន្ត្រីក្របខ័ណ្ឌ និងមន្ត្រីជាប់កិច្ចសន្យាសម្រាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី៥ ឆ្នាំ២០២២
- គម្រោងថវិកាប៉ាន់ស្មានសម្រាប់ការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោត ឆ្នាំ២០២១ (ឧបសម្ព័ន្ធ៣)
- គម្រោងថវិកាប៉ាន់ស្មានសម្រាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី៥ ឆ្នាំ២០២២ (ឧបសម្ព័ន្ធ៤)។

ផ្អែកតាមប្រតិទិន និងផែនការមេរបស់ គ.ជ.ប អគ្គនាយកដ្ឋាន នាយកដ្ឋាន និងអង្គភាពផ្សេងទៀតរួមទាំង គធ.ខប លគធ.ខប និងក្រុមប្រឹក្សាឃុំ សង្កាត់ (កបឃ.ស) បានកសាងផែនការដើម្បីអនុវត្តការងារជាក់ស្តែងក្នុងដំណើរការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី៥ ឆ្នាំ២០២២ ឱ្យបានរលូនស្របតាមច្បាប់បោះឆ្នោត បទបញ្ជា និងនីតិវិធី និងប្រតិទិនការងារដែលបានកំណត់ ។

## III- **រចនាសម្ព័ន្ធរដ្ឋបាល និងការងារមន្ត្រីបុគ្គលិក**

### ១. រចនាសម្ព័ន្ធរដ្ឋបាល គ.ជ.ប

យោងមាត្រា ១៥១ ថ្មី (ពីរ) នៃរដ្ឋធម្មនុញ្ញ សមាសភាព គ.ជ.ប មាន ៩រូប សម្រាប់អាណត្តិប្រាំឆ្នាំ ហើយក្នុងករណីខកខានមិនបានរៀបចំសមាសភាព គ.ជ.ប សមាសភាពដែលមានស្រាប់ ត្រូវអនុវត្តការងាររបស់ខ្លួនបន្តទៀតដើម្បីចាត់ចែងរៀបចំការបោះឆ្នោតតាមច្បាប់។ សមាសភាព គ.ជ.ប ទាំង ៩រូប រួមមាន ៖

#### ១.១. សមាសភាព គ.ជ.ប

សមាសភាព គ.ជ.ប មាន ៩រូប ដែលមានរាយនាមដូចខាងក្រោម ៖

| | | | |
|---|---|---|---|
| ១- | ឯកឧត្តម | **ប្រាជ្ញ ចន្ទ** | ប្រធាន |
| ២- | ឯកឧត្តម | **នុត សុខុម** | អនុប្រធាន |
| ៣- | ឯកឧត្តម | **មាន សតិ** | សមាជិក |
| ៤- | ឯកឧត្តម | **ឌីម សុវណ្ណារុំ** | សមាជិក |
| ៥- | ឯកឧត្តម | **ឌុច សុន** | សមាជិក |
| ៦- | ឯកឧត្តម | **ហ៊ីង ធីឫទ្ធិ** | សមាជិក |
| ៧- | ឯកឧត្តម | **ឯម សូផាត** | សមាជិក |
| ៨- | ឯកឧត្តម | **ហ៊ែល សារ៉ាត់** | សមាជិក |
| ៩- | ឯកឧត្តម | **ហង្ស ពុទ្ធា** | សមាជិក។ |

### ១.២. សមាសភាពអគ្គលេខាធិការ និងអគ្គលេខាធិការរង

១- ឯកឧត្តម **ទេព នីថា** អគ្គលេខាធិការ

២- ឯកឧត្តម **សោម សូរីដា** អគ្គលេខាធិការរង

៣- ឯកឧត្តម **ម៉ៅ សុភារិទ្ធ** អគ្គលេខាធិការរង

៤- ឯកឧត្តម **នី ចរិយា** អគ្គលេខាធិការរង

៥- ឯកឧត្តម **ម៉ុក ដារ៉ា** អគ្គលេខាធិការរង។

## ២. រចនាសម្ព័ន្ធថ្នាក់ក្រោម គ.ជ.ប

ផ្អែកតាម ច.គ.ជ.ប ច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ (ច.ប.ត.រ) ច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ (ច.ប.ឃ.ស) និងបទបញ្ជាផ្ទៃក្នុង គ.ជ.ប រចនាសម្ព័ន្ធថ្នាក់ក្រោមរបស់ គ.ជ.ប មានដូចខាងក្រោម ៖

### ២.១- ដំណាក់កាលនៃការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោត ឆ្នាំ២០២១

- លេខាធិការដ្ឋានរាជធានី ខេត្តរៀបចំការបោះឆ្នោត (លធ.ខប) ជារចនាសម្ព័ន្ធនៃអង្គការលេខអគ្គលេខាធិការដ្ឋាន គ.ជ.ប ត្រូវបំពេញការងារជាជំនួយការ និងសម្របសម្រួលការចុះឈ្មោះបោះឆ្នោតតាមរាជធានី ខេត្ត
- ក្រុមប្រឹក្សាឃុំ សង្កាត់ (កបឃ.ស) ត្រូវបាន គ.ជ.ប ធ្វើប្រតិភូកម្មអំណាចឱ្យបំពេញតួនាទីជាតំណាង គ.ជ.ប ក្នុងការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោត ហើយត្រូវមានគណនេយ្យភាពចំពោះ គ.ជ.ប
- ក្រុមចុះឈ្មោះបោះឆ្នោត (ក.ច.ប) នៃឃុំ សង្កាត់នីមួយៗមានប្រធាន ១រូប ដែលជ្រើសរើសដោយ គ.ជ.ប អនុប្រធាន ១រូប ជាស្មៀនឃុំ សង្កាត់សាមី និងសមាជិក ១រូប ជាការីកុំព្យូទ័រដែលជ្រើសរើសដោយ គ.ជ.ប។

### ២.២- ដំណាក់កាលនៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី៥ ឆ្នាំ២០២២

- គណៈកម្មការរាជធានី ខេត្តរៀបចំការបោះឆ្នោត (គធ.ខប) មានសមាសភាពចំនួន ៧រូប ក្នុងមួយរាជធានី ខេត្ត ដែលត្រូវបាន គ.ជ.ប ជ្រើសរើស និងតែងតាំងឱ្យបម្រើការងារក្នុងដំណាក់កាលបោះឆ្នោត។ គធ.ខប មានលេខាធិការដ្ឋានមួយជាជំនួយការដែលមានឈ្មោះថាលេខាធិការដ្ឋាននៃគណៈកម្មការរាជធានី ខេត្តរៀបចំការបោះឆ្នោត (លគធ.ខប)
- គណៈកម្មការឃុំ សង្កាត់រៀបចំការបោះឆ្នោត (គឃ.សប) មានសមាសភាពចំនួន ៥ ទៅ ៧រូប ក្នុងមួយឃុំ សង្កាត់ ទៅតាមភូមិសាស្ត្រឃុំ តូច ឬធំ នៃរាជធានីខេត្តនីមួយៗ
- គណៈកម្មការការិយាល័យបោះឆ្នោត (គ.ក.ប) មានសមាសភាពចំនួន ៦រូប ក្នុង ១ការិយាល័យ។ នៅពេលរាប់សន្លឹកឆ្នោត គ.ក.ប នឹងក្លាយជាគណៈកម្មការការិយាល័យរាប់សន្លឹកឆ្នោត (គ.ក.រ)។

## ៣. រចនាសម្ព័ន្ធអគ្គលេខាធិការដ្ឋាននៃ គ.ជ.ប

ផ្អែកតាមអនុក្រឹត្យលេខ ១១ អនក្រ.បក ចុះថ្ងៃទី២២ ខែមករា ឆ្នាំ២០២១ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃអគ្គលេខាធិការដ្ឋាន គ.ជ.ប និងបទបញ្ជាផ្ទៃក្នុងរបស់ គ.ជ.ប អគ្គលេខាធិការដ្ឋាន គ.ជ.ប មានអគ្គនាយកដ្ឋានចំនួន ៣ នាយកដ្ឋានចំនួន ៧ មានលេខាធិការដ្ឋានមួយជាជំនួយការ និងលេខាធិការដ្ឋានរាជធានី ខេត្តរៀបចំការបោះឆ្នោត (លធ.ខប) ចំនួន២៥។

អគ្គលេខាធិការដ្ឋាន គ.ជ.ប មានរចនាសម្ព័ន្ធ ដូចខាងក្រោម ៖

**១- អគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ**

- នាយកដ្ឋានរដ្ឋបាល (ន.រ.ប)
- នាយកដ្ឋានហិរញ្ញវត្ថុ (ន.ហ.វ)។

**២- អគ្គនាយកដ្ឋានសេវាកម្មច្បាប់ និងបច្ចេកទេស**

- នាយកដ្ឋានប្រតិបត្តិការ (ន.ប្រ)
- នាយកដ្ឋានគ្រប់គ្រងទិន្នន័យអ្នកបោះឆ្នោត និងបញ្ជីបោះឆ្នោត (ន.គ.ទ.ប)
- នាយកដ្ឋានសេវាកម្មច្បាប់ និងវិវាទកម្ម (ន.ស.ច.វ)។

**៣- អគ្គនាយកដ្ឋានអប់រំ ព័ត៌មាន និងទំនាក់ទំនងសាធារណៈ**

- នាយកដ្ឋានបណ្តុះបណ្តាល និងអប់រំអ្នកបោះឆ្នោត (ន.ប.ប.អ)
- នាយកដ្ឋានព័ត៌មាន និងទំនាក់ទំនងសាធារណៈ (ន.ព.ទ.ស)។

**៤- លេខាធិការដ្ឋាននៃអគ្គលេខាធិការដ្ឋាន គ.ជ.ប (ល.អ.គ)។**

**៥- លេខាធិការដ្ឋានរាជធានី ខេត្តរៀបចំការបោះឆ្នោត (លធ.ខប)។**

ដោយឡែកនាយកដ្ឋានសវនកម្មផ្ទៃក្នុង (ន.ស.ក) និងអង្គភាពលទ្ធកម្ម (អ.ល) ស្ថិតក្រោមការដឹកនាំ និងគ្រប់គ្រងផ្ទាល់ដោយប្រធាន គ.ជ.ប។

## ៤. ការងារមន្ត្រី បុគ្គលិក

តាមប្រតិទិននៃការជ្រើសរើស ការតែងតាំង និងការបណ្តុះបណ្តាលមន្ត្រី បុគ្គលិក សម្រាប់ការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោត ឆ្នាំ២០២១ និងការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី៥ ឆ្នាំ២០២២ គ.ជ.ប បានតែងតាំងអ្នករាជការ គ.ជ.ប (អ.គ.ជ.ប) មន្ត្រីជាប់កិច្ចសន្យារយៈពេលវែង និងតែងតាំងបន្តមន្ត្រីជាប់កិច្ចសន្យារយៈពេលខ្លីមួយចំនួននៅ គ.ជ.ប ព្រមទាំងបានជ្រើសរើស និងតែងតាំងមន្ត្រីជាប់កិច្ចសន្យារយៈពេលខ្លីសម្រាប់បម្រើឱ្យការចុះឈ្មោះបោះឆ្នោត និងការបោះឆ្នោត ដូចខាងក្រោម ៖

### ៤.១- ដំណាក់កាលនៃការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោត ឆ្នាំ២០២១

ក្នុងដំណាក់កាលនេះ គ.ជ.ប មានមន្ត្រីបោះឆ្នោតចំនួន ៦,៣៦៥នាក់ (ស្រី ១,០៩៤នាក់) ដោយក្នុងនោះ ៖

**ក- នៅថ្នាក់ គ.ជ.ប**

- ការតែងតាំង អ.គ.ជ.ប ចំនួន ៣១៩នាក់ (ស្រី ៦៥នាក់)
- ការតែងតាំងមន្ត្រីជាប់កិច្ចសន្យារយៈពេលវែងចំនួន ២០១នាក់ (ស្រី ៧០នាក់)
- ការជ្រើសរើស និងតែងតាំងមន្ត្រីជាប់កិច្ចសន្យារយៈពេលខ្លីចំនួន ១៨២នាក់ (ស្រី ៥៤នាក់)។

**ខ- នៅថ្នាក់ក្រោម**

- ការតែងតាំង អ.គ.ជ.ប ចំនួន ១៤១នាក់ (ស្រី ១៩នាក់) នៅ លធ.ខប
- ការតែងតាំងមន្ត្រីជាប់កិច្ចសន្យារយៈពេលវែងចំនួន ៥៦នាក់ (ស្រី ១៦នាក់) នៅ លធ.ខប
- ការជ្រើសរើស និងតែងតាំងមន្ត្រីជាប់កិច្ចសន្យារយៈពេលខ្លីចំនួន ៥១៦នាក់ (ស្រី ៤៧នាក់) នៅ លធ.ខប
- ការជ្រើសរើស និងតែងតាំង ក.ច.ប ចំនួន ៤,៩៥០នាក់ (ស្រី ៨២៣នាក់) នៅតាម ឃុំ សង្កាត់។

### ៤.២- ដំណាក់កាលនៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី៥ ឆ្នាំ២០២២

ក្នុងដំណាក់កាលនេះ គ.ជ.ប មានមន្ត្រីបោះឆ្នោតចំនួន ១៥១,៨០០នាក់ (ស្រី ៧២,០៦២នាក់) ដោយក្នុងនោះ ៖

ក- នៅថ្នាក់ គ.ជ.ប

- ការតែងតាំង អ.គ.ជ.ប ចំនួន ៣២០នាក់ (ស្រី ៦៥នាក់)
- ការតែងតាំងមន្ត្រីជាប់កិច្ចសន្យារយៈពេលវែងចំនួន ២០១នាក់ (ស្រី ៧២នាក់)
- ការតែងតាំងមន្ត្រីជាប់កិច្ចសន្យារយៈពេលខ្លីចំនួន ១៤៧នាក់ (ស្រី ៥០នាក់)។

ខ- នៅថ្នាក់ក្រោម

- ការតែងតាំង អ.គ.ជ.ប ចំនួន ១៤០នាក់ (ស្រី ១៩នាក់) នៅថ្នាក់រាជធានី ខេត្ត
- ការតែងតាំងមន្ត្រីជាប់កិច្ចសន្យារយៈពេលវែងចំនួន ៥៥នាក់ (ស្រី ១៦នាក់) នៅថ្នាក់រាជធានី ខេត្ត
- ការជ្រើសរើស និងតែងតាំងមន្ត្រីជាប់កិច្ចសន្យារយៈពេលខ្លី គធ.ខប/លគធ.ខប ចំនួន ១,០២៣នាក់ (ស្រី ១៤១នាក់)
- ការជ្រើសរើស និងការតែងតាំងមន្ត្រីជាប់កិច្ចសន្យារយៈពេលខ្លី គឃ.សប ចំនួន ៨,៣០២នាក់ (ស្រី ១,២៤៨នាក់)
- ការជ្រើសរើស និងការតែងតាំង គ.ក.ប ចំនួន ១៤១,៦១២នាក់ (ស្រី ៧០,៤៥១នាក់)។

**៤.៣- ផលប៉ះពាល់ និងវិធានការទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩**

ដំណើរការរៀបចំការបោះឆ្នោតបានប្រព្រឹត្តទៅក្នុងស្ថានភាពដែលជំងឺកូវីដ-១៩ បាននិងកំពុងបន្តឆ្លងរាលដាលក្នុងអត្រាគួរឱ្យកត់សម្គាល់ ប៉ុន្តែដោយមានការគិតគូរ យកចិត្តទុកដាក់ចាត់វិធានការគ្រប់រូបភាពក្នុងការប្រយុទ្ធប្រឆាំង បង្ការ និងទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ពីសំណាក់រាជរដ្ឋាភិបាល និងអាជ្ញាធរពាក់ព័ន្ធគ្រប់លំដាប់ថ្នាក់ ពិសេសយុទ្ធនាការចាក់វ៉ាក់សាំងដូសទី៣ និងដូសជំរុញជាបន្តបន្ទាប់ដែលបានបង្កើតឱ្យមានភាពស៊ាំខ្ពស់នៅក្នុងសហគមន៍។ បន្ថែមលើនេះ គ.ជ.ប ក៏បានចាត់វិធានការសមស្របនានាដើម្បីចូលរួមទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ នៅក្នុងដំណើរការនេះផងដែរ។

យោងតាមរបាយការណ៍របស់ក្រសួងសុខាភិបាលនៅកម្ពុជាពុំមានករណីឆ្លងថ្មីតាំងពីថ្ងៃទី២៨ ខែឧសភា ឆ្នាំ២០២២ រហូតដល់ថ្ងៃបោះឆ្នោតដែលនេះពិតជាអំណោយផលល្អដល់ការបោះឆ្នោតឱ្យប្រព្រឹត្តទៅប្រកបដោយសុវត្ថិភាពខ្ពស់។

## IV- ការគ្រប់គ្រង និងការប្រព្រឹត្តទៅនៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី៥ ឆ្នាំ២០២២

### ១. ការងារហិរញ្ញវត្ថុ

ក្នុងដំណើរការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី៥ ឆ្នាំ២០២២ ត្រូវបានធានាដោយរាជរដ្ឋាភិបាល តាមដំណាក់កាលដូចខាងក្រោម ៖

**១.១. ដំណាក់កាលនៃការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោត ឆ្នាំ២០២១**

**ក- ថវិកាចំណូល**

គ.ជ.ប បានទទួលថវិកាពីរាជរដ្ឋាភិបាលសរុបចំនួន ៦៨,៥៩២,២៣៨,៧០០រៀល (ហុកសិបប្រាំបីប៊ីលាន ប្រាំរយកៅសិបពីរលាន ពីររយសាមសិបប្រាំបីពាន់ ប្រាំពីររយរៀល) ស្មើនឹង ១៦,៩៣៦,៣៥៥.២៣ដុល្លារអាមេរិក (ដប់ប្រាំមួយលាន ប្រាំបួនរយសាមសិបប្រាំមួយពាន់ បីរយហាសិបប្រាំដុល្លារ និងម្ភៃបីសេន)។

ខ- ថវិកាចំណាយ

គ.ជ.ប បានចំណាយថវិកាសម្រាប់ការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោត ឆ្នាំ២០២១ លើប្រាក់បៀវត្សសមាជិក គ.ជ.ប ប្រាក់បៀវត្ស និងប្រាក់កម្រៃមន្ត្រី បុគ្គលិក គ្រប់លំដាប់ថ្នាក់ សម្ភារបរិក្ខារ និងសេវាផ្សេងៗសរុបចំនួន ៦៧,៦០០,៣០៦,២០០រៀល (ហុកសិបប្រាំពីរប៊ីលាន ប្រាំមួយរយលាន បីរយប្រាំមួយពាន់ ពីររយរៀល) ស្មើនឹង ១៦,៦៩១,៤៣៣.៦៣ដុល្លារអាមេរិក (ដប់ប្រាំមួយលាន ប្រាំមួយរយកៅសិបមួយពាន់ បួនរយសាមសិបបីដុល្លារ និងហុកសិបបីសេន)។

## ១.២. ដំណាក់កាលនៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី៥ ឆ្នាំ២០២២

ក- ថវិកាចំណូល

គ.ជ.ប បានទទួលថវិកាពីរាជរដ្ឋាភិបាលសរុបចំនួន ១៧១,៣០៤,៦១៥,៧៨៩រៀល (មួយរយចិតសិបមួយប៊ីលាន បីរយបួនលាន ប្រាំមួយរយដប់ប្រាំពាន់ ប្រាំពីររយប៉ែតសិបប្រាំបួនរៀល) ស្មើនឹង ៤២,២៩៧,៤៣៦ដុល្លារអាមេរិក (សែសិបពីរលាន ពីររយកៅសិបប្រាំពីរពាន់ បួនរយសាមសិបប្រាំមួយដុល្លារ )។

ខ- ថវិកាចំណាយ

គ.ជ.ប បានចំណាយថវិកាសម្រាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី៥ លើប្រាក់បៀវត្សសមាជិក គ.ជ.ប ប្រាក់បៀវត្ស និងប្រាក់កម្រៃមន្ត្រី បុគ្គលិក គ្រប់លំដាប់ថ្នាក់ សម្ភារបរិក្ខារ និងសេវាផ្សេងៗចំនួន ១៧០,១៧២,២៥៩,៨៨៩រៀល (មួយរយចិតសិបប៊ីលាន មួយរយចិតសិបពីរលាន ពីររយហាសិបប្រាំបួនពាន់ ប្រាំបួនរយប៉ែតសិបប្រាំបួនរៀល) ស្មើនឹង ៤២,០១៧,៨៤១.៩៧ដុល្លារអាមេរិក (សែសិបពីរលាន ដប់ប្រាំពីរពាន់ ប្រាំបីរយសែសិបមួយដុល្លារ និងកៅសិបប្រាំពីរសេន)។

## ២- ការងារបណ្តុះបណ្តាល និងអប់រំអ្នកបោះឆ្នោត

### ២.១- ការចុះបញ្ជីបេក្ខជននៃគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត និងការឃោសនាបោះឆ្នោត

ក- នៅថ្នាក់ គ.ជ.ប

- ចាប់ពីថ្ងៃទី៧ ដល់ថ្ងៃទី៩ ខែកុម្ភៈ ឆ្នាំ២០២២ នៅសាលសន្និសីទ គ.ជ.ប បានបើកវគ្គបណ្តុះបណ្តាលដល់ប្រធាន គធ.ខប ប្រធាន លគធ.ខប សមាជិកសេវាកម្មច្បាប់ វិវាទកម្ម និងសន្តិសុខបោះឆ្នោត សមាជិកអប់រំ ព័ត៌មាន និងទំនាក់ទំនងសាធារណៈ តំណាងគណបក្សនយោបាយ សមាគម និងអង្គការមិនមែនរដ្ឋាភិបាលដែលមានសិក្ខាកាមចូលរួមសរុបចំនួន ១៣២នាក់ (ស្រី ១២នាក់)
- ចាប់ពីថ្ងៃទី២៤ដល់ថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០២២ ដោយមានកិច្ចសហការជាមួយអ្នកជំនាញការជប៉ុន (JICA) បានបើកវគ្គសិក្ខាសាលាស្តីពីការអប់រំអ្នកបោះឆ្នោតជាប្រចាំនៅកម្ពុជា ជូនដល់មន្ត្រី គធ.ខប និង $NGO_s$ នៅសណ្ឋាគារកាំបូឌីយ៉ាណា ដែលមានសិក្ខាកាមចូលរួមសរុបចំនួន ៤៣នាក់ (ស្រី ១៦នាក់)
- នៅថ្ងៃទី១៨ ខែមីនា ឆ្នាំ២០២២ បានបើកវគ្គបណ្តុះបណ្តាលស្តីពីការចែកប័ណ្ណព័ត៌មានអ្នកបោះឆ្នោត និងការចេញឯកសារបញ្ជាក់អត្តសញ្ញាណបម្រើឱ្យការបោះឆ្នោត (ឯ.អ) ដល់មន្ត្រី គធ.ខប លគធ.ខប គ្រូបង្គោលក្រុង ស្រុក ខណ្ឌ និងមន្ត្រីពាក់ព័ន្ធទាំង២៥ រាជធានី ខេត្តតាមរយៈប្រព័ន្ធ Microsoft teams ដែលមានសិក្ខាកាមចូលរួមសរុបចំនួន ១២៤នាក់ (ស្រី ៤៩នាក់)។

**ខ- នៅថ្នាក់ គធ.ខប**

- នៅថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ២០២២ បានបើកវគ្គបណ្តុះបណ្តាលដល់មន្ត្រី គធ.ខប ទាំង២៥ រាជធានី ខេត្ត ដែលមានសិក្ខាកាមចូលរួមសរុបចំនួន ១,៣៦៤នាក់ (ស្រី ១៩៧នាក់)។

**គ- នៅថ្នាក់ គឃ.សប**

- ចាប់ពីថ្ងៃទី២៨ ខែកុម្ភៈ ដល់ថ្ងៃទី១ ខែមីនា ឆ្នាំ២០២២ នៅតាមមណ្ឌលប្រមូលផ្តុំ ក្រុង ស្រុក ខណ្ឌ បានបើកវគ្គបណ្តុះបណ្តាលសមាសភាព គឃ.សប។ សម្រាប់ក្រុង ស្រុក ខណ្ឌដែលមានឃុំ សង្កាត់តិចជាង១០ ត្រូវរៀបចំវគ្គបណ្តុះបណ្តាលនៅថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២២ ដោយឡែកសម្រាប់ក្រុង ស្រុក ខណ្ឌ ដែលមានឃុំ សង្កាត់ច្រើនជាង១០ ត្រូវបានរៀបចំវគ្គបណ្តុះ-បណ្តាលចំនួន ២វគ្គគឺ វគ្គទី១ នៅថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២២ និងវគ្គទី២ នៅថ្ងៃទី១ ខែមីនា ឆ្នាំ២០២២ ដោយមានសិក្ខាកាមចូលរួមចំនួន ៨,៣១៥រូប (ស្រី ១,២២១រូប)។

## ២.២- ការបោះឆ្នោត និងការរាប់សន្លឹកឆ្នោត

**ក- នៅថ្នាក់ គ.ជ.ប**

- ចាប់ពីថ្ងៃទី១១ ដល់ថ្ងៃទី១៣ ខែមេសា ឆ្នាំ២០២២ នៅទីស្តីការ គ.ជ.ប បានបើកវគ្គបណ្តុះបណ្តាលដល់គ្រូបង្គោល គ.ជ.ប និងមន្ត្រី គ.ជ.ប មានសិក្ខាកាមចូលរួមសរុបចំនួន ៥៦នាក់ (ស្រី ១៤នាក់)
- ចាប់ពីថ្ងៃទី២ ដល់ថ្ងៃទី៤ ខែឧសភា ឆ្នាំ២០២២ គ.ជ.ប បានបើកវគ្គបណ្តុះបណ្តាលដល់ប្រធាន គធ.ខប ប្រធាន លគធ.ខប សមាជិកអប់រំ ព័ត៌មាន និងទំនាក់ទំនងសាធារណៈ សមាជិកសេវាកម្មច្បាប់ និងវិវាទកម្ម និងសន្តិសុខបោះឆ្នោត សមាជិកប្រតិបត្តិការ បោះឆ្នោត និងបច្ចេកទេស គណបក្សនយោបាយ សមាគម និងអង្គការមិនមែនរដ្ឋាភិបាល ដែលមានសិក្ខាកាមចូលរួមសរុបចំនួន ២៦០នាក់ (ស្រី ៣៥នាក់) នៅវិទ្យាស្ថានគរុកោសល្យរាជធានីភ្នំពេញ។

**ខ- នៅថ្នាក់ គធ.ខប**

- ចាប់ពីថ្ងៃទី៩ ដល់ថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០២២ បានបើកវគ្គបណ្តុះបណ្តាលដល់មន្ត្រី និងគ្រូបង្គោល គធ.ខប គណបក្សនយោបាយ សមាគម និងអង្គការមិនមែនរដ្ឋាភិបាលដោយចែកចេញជាពីរវគ្គគឺ វគ្គទី១ ពីថ្ងៃទី៩ ដល់ថ្ងៃទី១០ ខែឧសភា ឆ្នាំ២០២២ (សម្រាប់ខេត្តទី១) និងវគ្គទី២ ពីថ្ងៃទី១២ ដល់ថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០២២ (សម្រាប់ខេត្តទី២) ដែលមានសិក្ខាកាមចូលរួមសរុបចំនួន ១,៣១៤នាក់ (ស្រី ១៧៥នាក់)
- នៅថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០២២ បានរៀបចំបើកកិច្ចប្រជុំពិគ្រោះយោបល់ស្តីពី "ការងារបណ្តុះបណ្តាល និងអប់រំអ្នកបោះឆ្នោតជាមួយ គធ.ខប ដើម្បីបូកសរុបវាយតម្លៃ និងលើកទិសដៅការងារបន្ត" ដែលមានសិក្ខាកាមចូលរួមសរុបចំនួន ៧០នាក់ (ស្រី ១២នាក់)។

**គ- នៅថ្នាក់ គឃ.សប**

- ចាប់ពីថ្ងៃទី១៧ ដល់ថ្ងៃទី២០ ខែឧសភា ឆ្នាំ២០២២ បានបើកវគ្គបណ្តុះបណ្តាលនៅមណ្ឌលប្រមូលផ្តុំក្រុង ស្រុក ខណ្ឌដល់សមាសភាព គឃ.សប ដោយចែកចេញជាពីរវគ្គគឺ វគ្គទី១ ពីថ្ងៃទី១៧ ដល់ថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០២២ និងវគ្គទី២ ពីថ្ងៃទី១៩ ដល់ថ្ងៃទី២០ ខែឧសភា ឆ្នាំ២០២២ (ដោយឡែកចំពោះខេត្តកែបបានធ្វើការបណ្តុះបណ្តាលពីថ្ងៃទី១៦ ដល់ថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០២២) ដែលមានសិក្ខាកាមចូលរួមសរុបចំនួន៨,៨១៩នាក់ (ស្រី ១,២៥២នាក់)

- ចាប់ពីថ្ងៃទី២ ដល់ថ្ងៃទី៣ ខែមិថុនា ឆ្នាំ២០២២ បានបើកវគ្គបណ្តុះបណ្តាលដល់ គ.ក.ប មានសិក្ខាកាមចូលរួមសរុបចំនួន ១៤១,៦១២នាក់ (ស្រី ៧០,៤៥១នាក់)។

**២.៣- ការថត បញ្ជូន និងបញ្ចូលទិន្នន័យប្រព័ន្ធទីតាំងសកល (GPS) នៃទីតាំងការិយាល័យបោះឆ្នោត**

- ចាប់ពីថ្ងៃទី៥ ដល់ថ្ងៃទី៦ ខែឧសភា ឆ្នាំ២០២២ គ.ជ.ប បានបើកវគ្គបណ្តុះបណ្តាលដល់ប្រធាន និងសមាជិក គធ.ខប ស្តីពី "ការប្រើប្រាស់កម្មវិធីថត បញ្ជូន និងបញ្ចូលទិន្នន័យប្រព័ន្ធទីតាំងសកល GPS នៃទីស្នាក់ការ គឃ.សប ទីតាំងការិយាល័យបោះឆ្នោត សាលាឃុំ សង្កាត់ និងទីតាំង គធ.ខប" ដែលមានសិក្ខាកាមចូលរួមសរុបចំនួន ១១៧នាក់ (ស្រី ១៤នាក់)
- នៅថ្ងៃទី១១ ខែឧសភា ឆ្នាំ២០២២ គធ.ខប បានបើកវគ្គបណ្តុះបណ្តាលស្តីពីការប្រើប្រាស់កម្មវិធីថត បញ្ជូន និងបញ្ចូលទិន្នន័យប្រព័ន្ធទីតាំងសកល GPS នៃទីស្នាក់ការ គឃ.សប ទីតាំងការិយាល័យបោះឆ្នោត ទីតាំងសាលាឃុំ សង្កាត់ និងទីតាំង គធ.ខប ដល់មន្ត្រី គធ.ខប។

ឯកសារបណ្តុះបណ្តាលរួមមាន ច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃ គ.ជ.ប ច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ បទបញ្ជា និងនីតិវិធីសម្រាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី៥ ឆ្នាំ២០២២ សៀវភៅណែនាំ គធ.ខប សៀវភៅណែនាំ គឃ.សប សៀវភៅណែនាំ គ.ក.ប/គ.ក.រ សៀវភៅណែនាំស្តីពីនីតិវិធីនៃការដាក់ ការទទួល និងការដោះស្រាយពាក្យបណ្តឹង សៀវភៅណែនាំស្តីពីការប្រើប្រាស់កម្មវិធីគ្រប់គ្រងការចុះបញ្ជីបេក្ខជនគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត សៀវភៅណែនាំស្តីពីការប្រើប្រាស់កម្មវិធីគ្រប់គ្រងការចេញ ឯ.អ សៀវភៅណែនាំស្តីពីការប្រើប្រាស់កម្មវិធីត្រួតពិនិត្យ ផ្ទៀងផ្ទាត់ បូកសរុបលទ្ធផលនៃការបោះឆ្នោត និងការបែងចែកអាសនៈសម្រាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី៥ ឆ្នាំ២០២២។

## ៣- ការងារអប់រំសាធារណជន

**ក្នុងដំណាក់កាលនេះ គ.ជ.ប បាន ៖**

- **ផលិតបដា**
  - ទំហំ ១មx៦ម ស្តីពីកាលបរិច្ឆេទនៃការបោះឆ្នោតចំនួន ៣,៣០០ផ្ទាំង
  - ទំហំ ១មx៨ម ស្តីពីការអញ្ជើញប្រជាពលរដ្ឋទៅបោះឆ្នោតចំនួន ២,០០០ផ្ទាំង។
- **ផលិតស្ប៉ត និងល្ខោនវិទ្យុ សិល្បៈកំប្លែង**
  - ស្ប៉តវីដេអូអប់រំរឿងខ្លីចំនួន ៣រឿង
  - ស្ប៉តវិទ្យុអប់រំរឿងខ្លីចំនួន ៣រឿង
  - ស្ប៉តចម្រៀងកាយវិការចំនួន ៣បទ
  - ស្ប៉តវីដេអូខ្លីបែបជីវចលចំនួន ៣រឿង
  - ស្ប៉តសេចក្តីជូនដំណឹងចំនួន ៥ឃ្លីប
  - ស្ប៉តវីដេអូអប់រំផ្សព្វផ្សាយដល់អ្នកបោះឆ្នោតនៅកម្ពុជាចំនួន ២រឿង
  - DVD ចំនួន ១៥០បន្ទះ និង CD ចំនួន ៥០បន្ទះ
  - USB Flash ចំនួន ១,៦៧០
  - អត្ថបទស្ប៉តវីដេអូវែងស្តីពីនីតិវិធីនៃការបោះឆ្នោត និងការរាប់សន្លឹកឆ្នោតចំនួន ១រឿង
  - កម្មវិធីសិល្បៈកំប្លែង។
- **បោះពុម្ព Poster និងស្ទិកគ័រ**
  - Poster គំរូប្លង់ការិយាល័យបោះឆ្នោតចំនួន ៤៨,០០០សន្លឹក

- Poster ព្រះរាជសារព្រះមហាក្សត្រចំនួន ៤៨,០០០សន្លឹក
- Poster គំរូឯកសារផ្លូវការចំនួន ៤៨,០០០សន្លឹក
- Poster គំរូសន្លឹកឆ្នោតមិនបានការចំនួន ៤៨,០០០សន្លឹក
- Sticker សារអប់រំចំនួន ១០,០០០សន្លឹក
- Poster ស្តីពីគណបក្សនយោបាយចំនួន ២៥,០០០សន្លឹក
- Sticker ស្តីពីកាលបរិច្ឆេទនៃការបោះឆ្នោតចំនួន ២០,០០០សន្លឹក។

– **បោះពុម្ពខិត្តប័ណ្ណ**
  - ខិត្តប័ណ្ណស្តីពីការបោះឆ្នោតចំនួន ១៦៤,០០០សន្លឹក
  - ខិត្តប័ណ្ណស្តីពីការគូសសញ្ញាគាំទ្រគណបក្សលើសន្លឹកឆ្នោតចំនួន ១០,០០០សន្លឹក។

– **បោះពុម្ពសៀវភៅណែនាំ**
  - សៀវភៅណែនាំ គធ.ខប ចំនួន ២,៥០០ក្បាល
  - សៀវភៅណែនាំ គឃ.សប ចំនួន ១៧,០០០ក្បាល
  - សៀវភៅណែនាំ គ.ក.ប/គ.ក.រ ចំនួន ១៥០,០០០ក្បាល
  - សៀវភៅផ្ទត់ចំនួន ១០,០០០ក្បាល
  - សៀវភៅណែនាំស្តីពីការបោះឆ្នោតចំនួន ២៥,០០០ក្បាល។

– **ផ្សព្វផ្សាយសារអប់រំជូនអ្នកបោះឆ្នោត**
  - ផ្សព្វផ្សាយសារស្វ័យប្រវត្តិស្តីពីការអញ្ជើញប្រជាពលរដ្ឋឱ្យទៅបោះឆ្នោតតាមរយៈប្រព័ន្ធទូរស័ព្ទ ចំនួន ២ប្រព័ន្ធ មាន Smart និង Cellcard ដែលក្នុង ១ប្រព័ន្ធមានសារចំនួន ១០០,០០០លេខ សរុបទាំងអស់ចំនួន ២០០,០០០លេខ
  - ស្ប៉តអប់រំរឿងខ្លី ស្ប៉តចម្រៀងកាយវិការ និងស្ប៉តវីដេអូខ្លីបែបជីវចលតាមផ្ទាំងផ្សព្វផ្សាយ និងទូរទស្សន៍តាមទីសាធារណៈចំនួន ៥ទីតាំងរយៈពេល ៣០ថ្ងៃ នៅតាមផ្លូវសាធារណៈធំៗ ចំនួន ៥ ក្នុងរាជធានីភ្នំពេញ។

– **ផលិតបទយកការណ៍ និងឯកសារបោះពុម្ព**
  - បទយកការណ៍
  - ព្រឹត្តិបត្រគោលនយោបាយចំនួន ២លេខ
  - ព្រឹត្តិបត្រព័ត៌មាន គ.ជ.ប ចំនួន ១០លេខ
  - ប័ណ្ណប្រកាសស្តីពីការបោះឆ្នោត
  - កូនសៀវភៅបត់សម្រាប់ការបោះឆ្នោត
  - កញ្ចប់ព័ត៌មានសម្រាប់អ្នកសារព័ត៌មាន និងអ្នកសង្កេតការណ៍ (Press Kits)
  - សៀវភៅណែនាំស្តីពីការឃោសនាបោះឆ្នោត
  - ប័ណ្ណអ្នកសារព័ត៌មាន
  - សៀវភៅក្រមសីលធម៌។

– **ផលិតកម្មវិធីផ្សេងៗ**
  - កម្មវិធីកិច្ចសម្ភាសន៍តាមប្រព័ន្ធអនឡាញ
  - កម្មវិធីប្រកួតឆ្លើយសំណួរ

- កម្មវិធីស្វែងយល់
- កម្មវិធីស្មើភាព
- កម្មវិធីផ្សព្វផ្សាយ និងបញ្ជ្រាបការយល់ដឹងអំពីសារៈសំខាន់នៃការបោះឆ្នោត។

ដើម្បីចូលរួមគាំទ្រដល់សកម្មភាពផ្សព្វផ្សាយអប់រំសាធារណជន ដែលរៀបចំដោយអង្គការមិនមែនរដ្ឋាភិបាល គ.ជ.ប បានចាត់តាំងតំណាងរបស់ខ្លួនជាថ្នាក់ដឹកនាំ គ.ជ.ប ថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋាន គ.ជ.ប ប្រធាន អនុប្រធាននាយកដ្ឋានពាក់ព័ន្ធដើម្បីចូលរួមជាវាគ្មិនតាមកម្មវិធីផ្សព្វផ្សាយនានា ក៏ដូចជាសិក្ខាសាលានៅតាមក្រសួង ស្ថាប័ន អង្គការ សមាគម ដូចជា ក្រសួងកិច្ចការនារី អង្គការជនពិការកម្ពុជា អង្គការនិចហ្វិច សមាគមស្ត្រីសម្រាប់អភិវឌ្ឍន៍សិទ្ធិមនុស្ស សមាគមនារីកម្ពុជាដើម្បីសន្តិភាព និងការអភិវឌ្ឍន៍ អង្គការខុមហ្វ្រែល អង្គការសិទ្ធិមនុស្សប្រចាំនៅកម្ពុជា សមាគមបញ្ញវ័ន្ត និងយុវជនស្ម័គ្រចិត្ត សហភាពសហព័ន្ធយុវជនកម្ពុជា មជ្ឈមណ្ឌលកម្ពុជាដើម្បីប្រព័ន្ធផ្សព្វផ្សាយ និងនៅតាមគ្រឹះស្ថានសិក្សានានា។

**៤- ការផ្សព្វផ្សាយ និងការបញ្ជ្រាបការយល់ដឹងអំពីសារៈសំខាន់នៃការបោះឆ្នោតនៅតាមរាជធានី ខេត្ត**

បន្ថែមលើការងារអប់រំសាធារណជនខាងលើ គ.ជ.ប បានរៀបចំកម្មវិធីផ្សព្វផ្សាយ និងបញ្ជ្រាបការយល់ដឹងអំពីសារៈសំខាន់នៃការបោះឆ្នោតនៅតាមគ្រឹះស្ថានសិក្សាដល់សិស្ស និស្សិត និងភាគីពាក់ព័ន្ធ ដែលគ្រូឧទ្ទេសជាថ្នាក់ដឹកនាំ គ.ជ.ប អគ្គនាយកដ្ឋាន និងនាយកដ្ឋាន។ កម្មវិធីនេះត្រូវបានធ្វើជាបន្តបន្ទាប់នៅតាមក្រុង ស្រុកចំនួន១០ នៃ គ.ខ.ប តាកែវ កំពង់ចាម និងកំពង់ឆ្នាំង ដែលមានសិក្ខាកាមចូលរួមសរុបចំនួន ១,២៦១នាក់ (ស្រី ៥៨៩នាក់)។

**៥- ការងារព័ត៌មាន និងទំនាក់ទំនងសាធារណៈ**

ការងារព័ត៌មាន និងទំនាក់ទំនងសាធារណៈគឺផ្ដោតសំខាន់លើការផ្ដល់ព័ត៌មានអំពីសកម្មភាពការងាររបស់ គ.ជ.ប ក៏ដូចជាលទ្ធិប្រជាធិបតេយ្យតាមរយៈការបោះឆ្នោត ជូនដល់ប្រជាពលរដ្ឋ និងគ្រប់ភាគីពាក់ព័ន្ធ ក្នុងនោះ គ.ជ.ប បានសហការល្អជាមួយស្ថាប័នព័ត៌មានជាតិ និងអន្តរជាតិ ប្រព័ន្ធផ្សព្វផ្សាយរដ្ឋ និងឯកជនជាដើម ដើម្បីជួយសហការគាំទ្រ និងផ្សព្វផ្សាយអំពីដំណើរការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី៥ ឆ្នាំ២០២២។

**៥.១- ការងារព័ត៌មាន**

គ.ជ.ប បានផ្សព្វផ្សាយយ៉ាងទូលំទូលាយដល់ភាគីពាក់ព័ន្ធ ក៏ដូចជាប្រជាពលរដ្ឋទូទៅបានយល់ដឹង និងទទួលបានព័ត៌មានគ្រប់ជ្រុងជ្រោយដោយប្រើប្រាស់គ្រប់រូបភាព និងមធ្យោបាយមួយចំនួនតាមរយៈទំព័រ Facebook ផ្លូវការរបស់ គ.ជ.ប គេហទំព័រ គ.ជ.ប www.nec.gov.kh Channel Youtube របស់ គ.ជ.ប Channel Telegram របស់ គ.ជ.ប TV Online កម្មវិធីទូរស័ព្ទដៃ (APP) “NEC KH” សារ SMS តាមកាសែត និងប្រព័ន្ធផ្សព្វផ្សាយរបស់រដ្ឋមានស្ថានីយទូរទស្សន៍ វិទ្យុជាតិ និងឯកជនមួយចំនួន។ ព័ត៌មានដែលបានផ្សព្វផ្សាយតាមមធ្យោបាយខាងលើរួមមាន ប្រកាសព័ត៌មាន សេចក្ដីជូនដំណឹង សេចក្ដីបំភ្លឺ ព្រឹត្តិបត្រព័ត៌មាន ប័ណ្ណប្រកាស ខិត្តប័ណ្ណ ស្ទីកគ័រ បទយកការណ៍ កម្មវិធីស្វែងយល់ កម្មវិធីប្រកួតឆ្លើយសំណួរ កម្មវិធីបញ្ជ្រាបសារអប់រំ ស្ប៉តវីដេអូ និងវិទ្យុ កម្មវិធីព័ត៌មានថ្មីពី គ.ជ.ប វីដេអូប្រចាំសប្ដាហ៍ គ.ជ.ប និងម្ចាស់ឆ្នោត កិច្ចសម្ភាសន៍តាមប្រព័ន្ធអនឡាញ ឃ្លីបវីដេអូ កិច្ចសម្ភាសន៍ និងឯកសារផ្លូវការផ្សេងៗរបស់ គ.ជ.ប មួយចំនួនទៀត។

**៥.២- ការងារទំនាក់ទំនងសាធារណៈ**

ទោះបីស្ថិតនៅក្នុងស្ថានភាពនៃការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ គ.ជ.ប បានធ្វើទំនាក់ទំនងល្អជាមួយក្រសួង ស្ថាប័នជាតិ និងអន្តរជាតិ ការងារទំនាក់ទំនងនេះផ្ដោតសំខាន់លើការផ្ដល់ព័ត៌មានអំពីការបោះឆ្នោតតាមរយៈប្រព័ន្ធអនឡាញ ឬជំនួបពិភាក្សាដោយផ្ទាល់ ការចូលរួមវគ្គបណ្ដុះបណ្ដាល សិក្ខាសាលា និងកម្មវិធីផ្សេងៗ ដើម្បីផ្លាស់ប្ដូរយោបល់គ្នាទាក់ទងនឹងការបោះឆ្នោត និងកិច្ចសហការជំរុញការងារផ្សព្វផ្សាយការបោះឆ្នោតឱ្យ

បានទូលំទូលាយដល់សាធារណជនធ្វើយ៉ាងណាឱ្យដំណើរការបោះឆ្នោតប្រព្រឹត្តទៅដោយរលូន មានបរិយាកាសល្អ ប្រកបដោយ សន្តិសុខ និងសុវត្ថិភាព។ ក្រសួង ស្ថាប័នជាតិ និងអន្តរជាតិទាំងនោះមានដូចខាងក្រោម ៖

**ក- ក្រសួង ស្ថាប័នជាតិមាន ៖**

- ក្រសួងព្រះបរមរាជវាំង ព្រឹទ្ធសភា រដ្ឋសភា ក្រុមប្រឹក្សាធម្មនុញ្ញ ក្រសួងយុត្តិធម៌ ក្រសួងមហាផ្ទៃ ក្រសួងការពារជាតិ ក្រសួងព័ត៌មាន ក្រសួងមុខងារសាធារណៈ អាជ្ញាធរ សវនកម្មជាតិ ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ ក្រសួងការបរទេស និងសហ-ប្រតិបត្តិការអន្តរជាតិ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ក្រសួងផែនការ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្រសួងពាណិជ្ជកម្ម អគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម អគ្គស្នងការដ្ឋាននគរបាលជាតិ គណៈបញ្ជាការឯកភាពរដ្ឋបាលរាជធានី ខេត្ត គណបក្សនយោបាយ សមាគម និងអង្គការមិនមែនរដ្ឋាភិបាល។

**ខ- ស្ថាប័នអន្តរជាតិមាន ៖**

- សមាគមអង្គការ A-WEB មាន គ.ជ.ប ឥណ្ឌា គ.ជ.ប រុស្ស៊ី គ.ជ.ប អាហ្វ្រិកខាងត្បូង គ.ជ.ប កៀហ្ស៊ីស៊ីស្ថាន គ.ជ.ប កូសូវ៉ូ គ.ជ.ប ប៉ារ៉ាហ្គាយ គ.ជ.ប ហ្វីលីពីន គ.ជ.ប ថៃ គ.ជ.ប សាធារណរដ្ឋកូរ៉េ គ.ជ.ប ឥណ្ឌូនេស៊ី និង គ.ជ.ប ម៉ុងហ្គោលី
- ប្រតិភូសហភាពអឺរ៉ុបប្រចាំកម្ពុជាមាន ឯកអគ្គរដ្ឋទូតសហភាពអឺរ៉ុបប្រចាំនៅកម្ពុជា មន្ត្រីជាន់ខ្ពស់នៃស្ថានទូតបារាំង ស្ថានទូតសាធារណរដ្ឋឆែក ស្ថានទូតស៊ុយអែត ស្ថានទូតហុងគ្រី ប្រទេសទីម័រខាងកើត ស្ថានទូតនានានៅកម្ពុជា អ្នករាយការណ៍ពិសេសទទួលបន្ទុកសិទ្ធិមនុស្សនៅកម្ពុជា ទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិ JICA មជ្ឈមណ្ឌលសហប្រតិបត្តិការអន្តរជាតិជប៉ុន JICE ។

ក្នុងឆ្នាំ២០២១ គ.ជ.ប បានសហការជាមួយទីភ្នាក់ងារ JICA ក្នុងការផ្តល់ជំនួយ និងបញ្ជូនជំនាញការដើម្បីជួយលើកិច្ចការអប់រំអ្នកបោះឆ្នោត ក្រោមជំនួយឧបត្ថម្ភពីរាជរដ្ឋាភិបាលជប៉ុនរហូតដល់ឆ្នាំ២០២៣។

### ៤.៣- កម្មវិធីស្វែងយល់អំពីការបោះឆ្នោត

កម្មវិធីនេះត្រូវបានផ្សព្វផ្សាយតាមទូរទស្សន៍ជាតិកម្ពុជា ដែលមានវាគ្មិនកិត្តិយសជាថ្នាក់ដឹកនាំ គ.ជ.ប ថ្នាក់ដឹកនាំអគ្គនាយកដ្ឋាន នាយកដ្ឋាន និងអង្គភាពនានានៅ គ.ជ.ប និងផ្សព្វផ្សាយតាមវិទ្យុជាតិកម្ពុជា ដែលមានប្រធានបទដូចខាងក្រោម ៖

**ក- ផ្សព្វផ្សាយតាមទូរទស្សន៍ចំនួន ១០ មាន ៖**

- ការត្រៀមរៀបចំការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី៥ ឆ្នាំ២០២២
- ដំណើរការទូទៅនៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី៥ ឆ្នាំ២០២២
- គោលបំណងនៃការចែកប័ណ្ណព័ត៌មានអ្នកបោះឆ្នោត
- តួនាទី និងភារកិច្ចរបស់ភ្នាក់ងារគណបក្សនយោបាយក្នុងដំណើរការបោះឆ្នោត
- សិទ្ធិ និងករណីយកិច្ចរបស់ប្រជាពលរដ្ឋក្នុងការចូលរួមដំណើរការបោះឆ្នោត
- តួនាទី និងភារកិច្ចរបស់អ្នកសារព័ត៌មានក្នុងដំណើរការបោះឆ្នោត
- បែបបទ និងនីតិវិធីនៃការស្នើសុំ និងការចេញឯកសារបញ្ជាក់អត្តសញ្ញាណបម្រើឱ្យការបោះឆ្នោត

- ការិយាល័យបោះឆ្នោត
- ការឃោសនាបោះឆ្នោត
- ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី៥ ឆ្នាំ២០២២។

**ខ- ផ្សព្វផ្សាយតាមវិទ្យុចំនួន ៦ មាន ៖**

- ដំណើរការទូទៅនៃការបោះឆ្នោត
- សិទ្ធិ និងភារកិច្ចរបស់ភ្នាក់ងារគណបក្សនយោបាយក្នុងដំណើរការបោះឆ្នោត
- គោលបំណងនៃការចែកប័ណ្ណព័ត៌មានអ្នកបោះឆ្នោត
- នីតិវិធីនៃការស្នើសុំ និងការចេញឯកសារបញ្ជាក់អត្តសញ្ញាណបម្រើឱ្យការបោះឆ្នោត
- ការឃោសនាបោះឆ្នោត
- ការបោះឆ្នោត និងការរាប់សន្លឹកឆ្នោត។

### ៤.៤- កម្មវិធីស្មើភាព ផ្សព្វផ្សាយអំពីគោលនយោបាយរបស់គណបក្ស

បន្ថែមលើការងារឃោសនាបោះឆ្នោត គណបក្សនយោបាយទាំង ១៧ ក៏មានឱកាសស្មើភាពគ្នានៅលើប្រព័ន្ធផ្សព្វផ្សាយព័ត៌មានរបស់រដ្ឋ តាមរយៈកម្មវិធីស្មើភាពដែលរៀបចំឡើងដោយ គ.ជ.ប ដើម្បីឱ្យគណបក្សនយោបាយផ្សព្វផ្សាយអំពីគោលនយោបាយ និងកម្មវិធីនយោបាយរបស់ខ្លួនក្នុងការអភិវឌ្ឍឃុំ សង្កាត់ជូនដល់អ្នកបោះឆ្នោត។ កម្មវិធីគោលនយោបាយរបស់គណបក្សនីមួយៗត្រូវបានកំណត់ដោយ គ.ជ.ប មានដូចខាងក្រោម ៖

- **គោលនយោបាយសម្រាប់ការបោះឆ្នោត**
  - គោលនយោបាយរបស់គណបក្សក្នុងការពង្រឹងការគោរពច្បាប់ និងការបម្រើសេវាសាធារណៈ
  - គោលនយោបាយរបស់គណបក្សក្នុងការការពារសន្តិសុខ និងការរក្សាសុវត្ថិភាពក្នុងឃុំ សង្កាត់
  - គោលនយោបាយរបស់គណបក្សក្នុងការអភិវឌ្ឍ និងការពង្រឹងលទ្ធិប្រជាធិបតេយ្យ។
- **គោលនយោបាយក្នុងអំឡុងពេលឃោសនាបោះឆ្នោត**
  - គោលការណ៍ផលិតស្ប៉តរបស់គណបក្សនយោបាយ
  - គោលការណ៍សម្រាប់បោះពុម្ព និងផ្សព្វផ្សាយអត្ថបទឃោសនារបស់គណបក្សនយោបាយក្នុងព្រឹត្តិបត្រគោលនយោបាយរបស់គណបក្ស
  - គោលការណ៍សម្រាប់អង្គការមិនមែនរដ្ឋាភិបាលជាតិ អន្តរជាតិ និងប្រព័ន្ធផ្សព្វផ្សាយព័ត៌មានស្តីពីការរៀបចំកម្មវិធីសំណួរ-ចម្លើយ ឬពិភាក្សាអំពីគោលនយោបាយរបស់គណបក្សនយោបាយ
  - គោលការណ៍សម្រាប់ស្ថានីយវិទ្យុ និងទូរទស្សន៍ ក្នុងការលក់ ឬជួលម៉ោងផ្សព្វផ្សាយឱ្យគណបក្សនយោបាយ ដើម្បីធ្វើការផ្សព្វផ្សាយអំពីគោលនយោបាយ និងកម្មវិធីនយោបាយរបស់គណបក្ស។

### ៤.៥- កម្មវិធីស្វែងយល់អំពីសារៈសំខាន់នៃការបោះឆ្នោតផ្សព្វផ្សាយដោយ គធ.ខប

ដើម្បីលើកកម្ពស់ការយល់ដឹងក្នុងស្រទាប់មហាជននៅទូទាំងប្រទេស អំពីសារៈសំខាន់នៃការបោះឆ្នោត គ.ជ.ប ដោយមានកិច្ចសហការឧបត្ថម្ភពីស្ថានទូតនៃសាធារណរដ្ឋប្រជាមានិតចិនប្រចាំព្រះរាជាណាចក្រកម្ពុជា បានរៀបចំការផ្សាយផ្ទាល់នូវកម្មវិធីស្វែងយល់អំពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី៥ ឆ្នាំ២០២២ ចាប់ពីថ្ងៃទី៣០ ខែមេសា ដល់ថ្ងៃទី៣ ខែមិថុនា ឆ្នាំ២០២២ នៅគ្រប់វិទ្យុ FM ទាំង ២៥រាជធានី ខេត្តរយៈពេល

១ម៉ោង ក្នុង ១ថ្ងៃ។ កម្មវិធីនេះមានការចូលរួមជាវាគ្មិនពីសំណាក់សមាសភាព គធ.ខប ព្រមទាំងបើកឱកាសដល់ប្រជាពលរដ្ឋ និងភាគីពាក់ព័ន្ធ លើកជាសំណួរ ដើម្បីវាគ្មិនធ្វើការបកស្រាយ ឬស្រាយចម្ងល់ជូនផងដែរ។

### ៥.៦- កម្មវិធីកិច្ចសម្ភាសន៍តាមប្រព័ន្ធអនឡាញ

- ការត្រៀមរៀបចំការបោះឆ្នោត
- ការរក្សាសន្តិសុខ សុវត្ថិភាព និងសណ្តាប់ធ្នាប់នៃការបោះឆ្នោត
- ការរៀបចំការបោះឆ្នោតក្នុងបរិបទការរីករាលដាលនៃជំងឺកូវីដ-១៩
- សិទ្ធិ និងតួនាទីរបស់ប្រព័ន្ធផ្សព្វផ្សាយក្នុងដំណើរការបោះឆ្នោត
- ភាពជាអ្នកបម្រើសេវាជូនអ្នកបោះឆ្នោត
- សិទ្ធិ និងតួនាទីរបស់អ្នកសង្កេតការណ៍បោះឆ្នោត
- ការដឹកជញ្ជូន និងបែងចែកសម្ភារ សម្រាប់បម្រើការបោះឆ្នោត
- ការទទួលខុសត្រូវរបស់ គ.ក.ប/គ.ក.រ ក្នុងដំណើរការបោះឆ្នោត
- ការប្រើប្រាស់ទឹកខ្មៅលុបមិនជ្រះសម្រាប់ជ្រលក់ម្រាមដៃ
- ការដាក់ ការទទួល និងការដោះស្រាយពាក្យបណ្តឹងពាក់ព័ន្ធនឹងការបោះឆ្នោត។

## ៦. ការងារប្រតិបត្តិការ និងភស្តុភារ

### ៦.១. ការងារប្រតិបត្តិការ និងបច្ចេកទេស

#### ៦.១.១- ការបិទផ្សាយបញ្ជីឈ្មោះទីតាំងការិយាល័យបោះឆ្នោត

ការកំណត់ចំនួនទីតាំងការិយាល័យបោះឆ្នោតក្នុងឃុំ សង្កាត់ត្រូវផ្អែកលើមូលដ្ឋានស្ថិតិប្រជាពលរដ្ឋប៉ាន់ស្មានសម្រាប់ការចុះឈ្មោះបោះឆ្នោតនៅតាមភូមិក្នុងឃុំ សង្កាត់នីមួយៗ។ ការិយាល័យបោះឆ្នោតដែលបញ្ជីបោះឆ្នោតនៃការិយាល័យទាំងនោះត្រូវបានផ្តល់សុពលភាពជាផ្លូវការចុងក្រោយដោយ គ.ជ.ប និងត្រូវប្រើជាការិយាល័យបោះឆ្នោតសម្រាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី៥ ឆ្នាំ២០២២ មានចំនួន ២៣,៦០២ការិយាល័យ។ ក្នុងស្ថានភាពជាក់ស្តែង គ.ជ.ប អាចកែសម្រួលការិយាល័យបោះឆ្នោត ឬ/និងបង្កើតការិយាល័យបោះឆ្នោតថ្មីបន្ថែមឱ្យស្របតាមស្ថានភាពជាក់ស្តែង និងការចាំបាច់ដោយប្រើប្រាស់លក្ខណៈវិនិច្ឆ័យលើកត្តាប្រជាសាស្ត្រ ចម្ងាយផ្លូវ ភូមិសាស្ត្រ សង្គម និងរដ្ឋបាល។ បញ្ជីឈ្មោះទីតាំងការិយាល័យបោះឆ្នោតសម្រាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី៥ ឆ្នាំ២០២២ ត្រូវបានបិទផ្សាយជាសាធារណៈនៅទីស្នាក់ការ គឃ.សប លើកទី១ នៅថ្ងៃទី២ ខែមីនា ឆ្នាំ២០២២ គឺ២ថ្ងៃមុនការចុះបញ្ជីបេក្ខជននៃគណបក្សនយោបាយ និងលើកទី២ បិទផ្សាយនៅតាមទីតាំងការិយាល័យបោះឆ្នោតនីមួយៗ និងនៅទីស្នាក់ការ គឃ.សប នៅថ្ងៃទី៤ ខែមិថុនា ឆ្នាំ២០២២ គឺ១ថ្ងៃមុនថ្ងៃបោះឆ្នោត។

#### ៦.១.២- ការបញ្ជាទិញ និងការបែងចែងសម្ភារ បរិក្ខារ និងឯកសារផ្សេងៗ

គ.ជ.ប បានផលិត និងបញ្ជាទិញសម្ភារបរិក្ខារសម្រាប់បម្រើឱ្យការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី៥ ឆ្នាំ២០២២ ដែលមានដូចជាបញ្ជីបោះឆ្នោត សន្លឹកឆ្នោត បញ្ជីឈ្មោះទីតាំងការិយាល័យបោះឆ្នោត ប្រដាប់ចោះសន្លឹកឆ្នោតដែលមិនបានប្រើ ត្រាសម្ងាត់ ត្រា គឃ.សប ត្រា គ.ក.ប តាំប៉ុង និងទឹកតាំប៉ុងក្រហម សោឃ្លុំជ័រ ទម្រង់បែបបទផ្សេងៗ ស្បោង និងស្រោមសំបុត្របោះពុម្ពគ្រប់ប្រភេទ ស្លាកសម្គាល់ការិយាល័យបោះឆ្នោត ស្រោមសំបុត្រធំ និងស្រោមសំបុត្រមធ្យម ស្បោងបោះពុម្ពគ្រប់ប្រភេទ ប៊ិកហ្វឺតលុបមិនជ្រះ ប៊ិកហ្វឺតធំ ប៊ិកសរសេរ ប៊ិកមានខ្សែចង ក្រដាសប៊ីល្ល ក្រដាសសរសេរ ក្រដាសទ្រាប់គូសសន្លឹកឆ្នោត ផ្ទាំងក្រដាស

សម្រាប់គូសសំឡេងឆ្នោត (ទំហំ៨០សម x ១២០សម) ជំរការវារដបធំ បន្ទាត់ជំរ និងសម្ភារប្រើប្រាស់ផ្សេងៗ ក្នុងការិយាល័យបោះឆ្នោត អាគុយ វិទ្យុទាក់ទង និងគ្រឿងបរិក្ខារពាក់ព័ន្ធ។

**៦.១.៣- ការបែងចែកសម្ភារបរិក្ខារកុំព្យូទ័រ និងឯកសារផ្សេងៗ**

សម្រាប់ដំណើរបោះឆ្នោត ឆ្នាំ២០២២ នេះ ន.គ.ទ.ប នៃអគ្គនាយកដ្ឋានសេវាកម្មច្បាប់ និងបច្ចេកទេស គ.ជ.ប បានធ្វើការដំឡើងកម្មវិធី និងធ្វើការបែងចែកដូចខាងក្រោម ៖

- បញ្ជីបោះឆ្នោតផ្លូវការ ឆ្នាំ២០២១ ចំនួន ៣ច្បាប់
- សម្ភារបរិក្ខារកុំព្យូទ័រសរុបចំនួន ១,៦៥២ឈុត មានចំនួន ១៥មុខ ដែលក្នុងមួយមុខៗ ចំនួន ១,៦៥២គ្រឿង ក្នុងនោះមាន ៖ Laptop ១set, Camera, Portable Scanner , Photo Background, Finger Print, USB Flash, USB Hub, Power Bank Printer,Type-C Hub,Type-C Converter, ព្រីភ្លើង Printer,Locker+កូនសោ និង កេសអាលុយមីញ៉ូម
- សម្ភារបរិក្ខារកុំព្យូទ័របម្រុងចំនួន ១៣មុខ ក្នុងនោះមាន ៖ Laptop Dell ចំនួន ២០៤គ្រឿង Adaptor ចំនួន ២០៤គ្រឿង Camera ចំនួន ១៦៧គ្រឿង Portable Scanner ចំនួន ១៦៧គ្រឿង Finger Print ចំនួន ១៦៧បន្ទះ Type-C Hub ចំនួន ១៦៧គ្រឿង Type-C Converterចំនួន ១៦១គ្រឿង Printer ចំនួន ១00គ្រឿង Toner ចំនួន ១,៦៥២គ្រឿង Power Bank K2 ចំនួន ៣៦៥គ្រឿង Locker ចំនួន ៤៦គ្រឿង កេសអាលុយមីញ៉ូមចំនួន ៤៦កេស
- សម្ភារបរិក្ខារកុំព្យូទ័រសម្រាប់បណ្តុះបណ្តាលសមាសភាព គឃ.សប សរុបចំនួន ២៥២ឈុតមានចំនួន ១៤មុខ មាន ៖ Laptop HP,Adaptor, Camera, Portable Scanner, Scanner Pad, , Finger Print, Type-C Hub, USB Hub (ក្នុងមួយមុខៗ មានចំនួន ២៥២គ្រឿង) Mouse , Photo Background ព្រីភ្លើង, កាបូប និង Locker កេសអាលុយមីញ៉ូម (ដែលក្នុងមួយមុខៗមានចំនួន ២០៦គ្រឿង)
- សម្ភារបរិក្ខារកុំព្យូទ័របម្រុងសម្រាប់បណ្តុះបណ្តាលសមាសភាព គឃ.សប ចំនួន ៨មុខ ដែលក្នុងមួយមុខៗមានចំនួន ៤៦គ្រឿង ក្នុងនោះមាន ៖
  Laptop HP, Adaptor,Camera, Portable Scanner, Scanner Pad, Finger Print, Type-C Hub, USB Hub។
- សម្ភារបរិក្ខារកុំព្យូទ័រសម្រាប់ គធ.ខប ចំនួន ៨មុខ ដែលក្នុង ១មុខៗមានចំនួន ៥៤គ្រឿង។

**៦.១.៤- ការបញ្ជាទិញទឹកខ្មៅលុបមិនជ្រះ**

គ.ជ.ប បានបញ្ជាទិញទឹកខ្មៅលុបមិនជ្រះពីក្រុមហ៊ុន Mysore pain & Varnish LTD ពីប្រទេសឥណ្ឌាចំនួន ៥២,000ដប ក្នុង ១ដបមានចំណុះ ៧០មីលីលីត្រ ដែលមានកម្រិតសូលុយស្យុងប្រាក់នីត្រាត ២០% ដែលមានតម្លៃ ១,00៦,000ដុល្លារអាមេរិក (មួយលាន ប្រាំមួយពាន់ដុល្លារអាមេរិក)។ ដើម្បីបង្ហាញពីតម្លាភាព និងភាពត្រឹមត្រូវនៃគុណភាពទឹកខ្មៅលុបមិនជ្រះ នៅថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០២២ គ.ជ.ប បានបើកកិច្ចប្រជុំផ្សព្វផ្សាយជាមួយភាគីពាក់ព័ន្ធដើម្បីធ្វើតេស្តទឹកខ្មៅលុបមិនជ្រះ ដែលត្រូវប្រើប្រាស់សម្រាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី៥ ឆ្នាំ២០២២ ដល់ភាគីពាក់ព័ន្ធដែលបានចូលរួមសរុបចំនួន ៦០នាក់ មកពីក្រុមប្រឹក្សាធម្មនុញ្ញ

ព្រឹទ្ធសភា ក្រសួងមហាផ្ទៃ ក្រសួងព័ត៌មាន អគ្គស្នងការដ្ឋាននគរបាលជាតិ ក្រុមប្រឹក្សាសកម្មភាពជនពិការ តំណាងស្ថានទូតឥណ្ឌា តំណាងគណបក្សនយោបាយ តំណាងអង្គការមិនមែនរដ្ឋាភិបាល និងអ្នកសារព័ត៌មាន ក្នុងនោះភាគីពាក់ព័ន្ធចំនួន ១៧នាក់បានឡើងមកធ្វើតេស្តសាកល្បងគុណភាពទឹកខ្មៅលុបមិនជ្រះ ហើយបានបង្ហាញពីទំនុកចិត្ត និងទទួលស្គាល់ថាទឹកខ្មៅជ្រលក់ដៃនេះពិតជាមានគុណភាពល្អលុបលាងមិនជ្រះពិតប្រាកដមែន។ ទឹកខ្មៅលុបមិនជ្រះទាំងនោះត្រូវបាន គ.ជ.ប ធ្វើការបែងចែកដូចខាងក្រោម ៖

- ផ្តល់ជូនក្នុងមួយការិយាល័យបោះឆ្នោតចំនួន ២ដប
- រក្សាទុកនៅ គធ.ខប ទាំង២៥ ចំនួន ៨០០ដប និង
- រក្សាទុកនៅ គ.ជ.ប មួយចំនួន។

### ៦.១.៥- ការបោះពុម្ពសន្លឹកឆ្នោត

យោងតាមលទ្ធផលផ្លូវការនៃការពិនិត្យឈ្មោះ និងការចុះឈ្មោះបោះឆ្នោត ឆ្នាំ២០២១ ដែលមានអ្នកបោះឆ្នោតសរុបចំនួន ៩,២០៥,៦៨១រូប នៃការិយាល័យបោះឆ្នោតសរុបចំនួន ២៣,៦០២ ទូទាំងប្រទេស ដើម្បីធានាឱ្យមានសន្លឹកឆ្នោតគ្រប់គ្រាន់សម្រាប់ប្រើប្រាស់ក្នុងការបោះឆ្នោត គ.ជ.ប បានកំណត់ចំនួនសន្លឹកឆ្នោតដែលត្រូវផលិតចំនួន ១៣,០២៦,០០០សន្លឹក ក្នុងនោះសន្លឹកឆ្នោតសម្រាប់ផ្តល់ឱ្យការិយាល័យបោះឆ្នោតមានចំនួន ១១,៦១១,៤០០សន្លឹក ស្មើនឹង ២៣២,២២៨ក្បាល កិបជាសៀវភៅដែលក្នុង ១ក្បាលមាន ៥០សន្លឹក។ សន្លឹកឆ្នោតបម្រុងសម្រាប់រាជធានី ខេត្តចំនួន ១,២៣៩,០០០សន្លឹក ស្មើនឹង ២៤,៧៨០ក្បាល ព្រមទាំងមានសន្លឹកឆ្នោតគំរូចំនួន ១៧៥,៦០០សន្លឹក សម្រាប់បម្រើការបណ្តុះបណ្តាល ដែលត្រូវបានផលិតជាសន្លឹកឆ្នោតរាយ។

យោងតាមការប្រគល់សិទ្ធិរបស់ គ.ជ.ប ជូនក្រុមហ៊ុន **ណាទីនព្រីនធីង ឯ.ក** ដែលជាភាគីជាប់កិច្ចសន្យាមានកាតព្វកិច្ចត្រូវបោះពុម្ព និងផ្គត់ផ្គង់សន្លឹកឆ្នោត ដើម្បីឱ្យដំណើរការផលិតសន្លឹកឆ្នោតត្រឹមត្រូវតាមលក្ខណៈបច្ចេកទេសដែលបានកំណត់ គ.ជ.ប បានសហការជាមួយក្រុមហ៊ុនដើម្បីត្រួតពិនិត្យផ្ទៀងផ្ទាត់ភាពត្រឹមត្រូវ និងបានរៀបចំវេចខ្ចប់សន្លឹកឆ្នោតសម្រាប់ការិយាល័យបោះឆ្នោតចំនួន ២៣,៦០២កញ្ចប់ និងដាក់បញ្ចូលគ្នាក្នុងឃុំ សង្កាត់ចំនួន ១,៨៣២កេស។ កញ្ចប់សន្លឹកឆ្នោតសម្រាប់ការិយាល័យបោះឆ្នោតក្នុងឃុំ សង្កាត់ ត្រូវបានវេចខ្ចប់តែ ១កេស សម្រាប់ឃុំ សង្កាត់ដែលមានចំនួនការិយាល័យបោះឆ្នោតតិច ហើយឃុំ សង្កាត់ដែលមានការិយាល័យបោះឆ្នោតច្រើនត្រូវបានវេចខ្ចប់ ២ ឬ ៣កេស។

ដើម្បីបង្ហាញពីតម្លាភាព និងភាពត្រឹមត្រូវ ក្នុងការបោះពុម្ពសន្លឹកឆ្នោត នៅថ្ងៃទី៦ ខែឧសភា ឆ្នាំ២០២២ គ.ជ.ប បានរៀបចំកម្មវិធីបង្ហាញអំពីដំណើរការបោះពុម្ពសន្លឹកឆ្នោត ដោយបានអញ្ជើញតំណាងគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត អ្នកសង្កេតការណ៍ ព្រមទាំងអ្នកសារព័ត៌មានសរុបចំនួន ៤០នាក់ ក្នុងនោះមានតំណាងគណបក្សនយោបាយចំនួន ៨ និងតំណាងអង្គការ សមាគមចំនួន ៩ បានចូលរួមពិនិត្យមើលដំណើរការបោះពុម្ពសន្លឹកឆ្នោតដែលមានទីតាំងនៅរោងពុម្ព **ណាទីនព្រីនធីង ឯ.ក** ផ្ទះលេខ ៩ ផ្លូវលេខ ៣៤៥ សង្កាត់បឹងកក់ ១ ខណ្ឌទួលគោក រាជធានីភ្នំពេញ។

### ៦.១.៦- ការផលិត និងការចែកប័ណ្ណព័ត៌មានអ្នកបោះឆ្នោត

ការផលិត និងការចែកប័ណ្ណព័ត៌មានគឺក្នុងគោលបំណងផ្តល់ព័ត៌មានដល់អ្នកបោះឆ្នោតអំពីលេខរៀងឈ្មោះ និងទិន្នន័យពាក់ព័ន្ធក្នុងបញ្ជីបោះឆ្នោត ទីតាំងការិយាល័យបោះឆ្នោត កាលបរិច្ឆេទ ពេលវេលានៃការបោះឆ្នោត និងប្រភេទឯកសារដែលត្រូវប្រើប្រាស់ក្នុងពេលបោះឆ្នោត។ ប័ណ្ណព័ត៌មានអ្នកបោះឆ្នោតត្រូវបាន គ.ជ.ប ផលិតសរុបចំនួន ៩,២០៥,៦៨១សន្លឹក ដើម្បីផ្តល់ជូនអ្នកបោះឆ្នោតដែលមានឈ្មោះក្នុងបញ្ជីបោះឆ្នោតផ្លូវការ ឆ្នាំ២០២១។

ផ្អែកតាមប្រតិទិនដំណើរការនៃការចែកប័ណ្ណព័ត៌មានអ្នកបោះឆ្នោតមានពីរដំណាក់កាល គឺដំណាក់កាលទី១ ចែកនៅតាមភូមិក្នុងឃុំ សង្កាត់ចាប់ពីថ្ងៃទី១៧ ខែមេសា ដល់ថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០២២ បានចំនួន ៨,៤៩៨,៧៩៣សន្លឹក ស្មើនឹង ៩២.៣២% នៅសល់ចំនួន ៧០៦,៨៨៨សន្លឹក។ ហើយដំណាក់កាលទី២ គឺបន្តចែកប័ណ្ណព័ត៌មានអ្នកបោះឆ្នោតដែលនៅសល់ពីការចែកតាមភូមិក្នុងឃុំ សង្កាត់ នៅទីស្នាក់ការ គឃ.សប ចាប់ពីថ្ងៃទី១៨ ខែឧសភា ដល់ថ្ងៃទី៣ ខែមិថុនា ឆ្នាំ២០២២ បានចំនួន ១០១,៤២១សន្លឹក ស្មើនឹង ១៤.៣៥% ។ ជាលទ្ធផលប័ណ្ណព័ត៌មានអ្នកបោះឆ្នោតដែលបានចែកជូនប្រជាពលរដ្ឋទាំងពីរដំណាក់កាលសរុបចំនួន ៨,៦០០,២១៤សន្លឹក ស្មើនឹង ៩៣,៤២% ហើយចំនួនប័ណ្ណព័ត៌មានដែលនៅសល់ចំនួន ៦០៥,៤៦៧សន្លឹកត្រូវបានប្រគល់ឱ្យ កបឃ.ស ដើម្បីរក្សាទុក។ (ឧបសម្ព័ន្ធ៥)

### ៦.១.៧- ការបង្កើតកម្មវិធីគ្រប់គ្រងការចេញ ឯ.អ

ដើម្បីបង្កលក្ខណៈងាយស្រួលដល់ គឃ.សប និងប្រជាពលរដ្ឋអ្នកបោះឆ្នោត និងកាត់បន្ថយការសរសេរដោយដៃ ការស្នើសុំ ឯ.អ មិនតម្រូវឱ្យមានរូបថត និងសាក្សី ដូចពេលមុនៗទៀតទេ ដោយ គ.ជ.ប បានសហការជាមួយក្រសួងមហាផ្ទៃក្នុងការចេញ ឯ.អ ជូនប្រជាពលរដ្ឋតាមប្រព័ន្ធកុំព្យូទ័រ។ ការចេញ ឯ.អ គឺក្នុងគោលបំណងធានាសិទ្ធិក្នុងការបោះឆ្នោតរបស់ប្រជាពលរដ្ឋខ្មែរដែលមិនទាន់មាន អ.ខ ឬ អ.ខ របស់ខ្លួនអស់សុពលភាព ឬមិនទាន់ទទួលបាន ឬបាត់ ឬខូច ឬកែតម្រូវ។ សម្រាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី៥ ឆ្នាំ២០២២ ការចេញ ឯ.អ ជូនប្រជាពលរដ្ឋមានរយៈពេល ៣០ថ្ងៃ គឺចាប់ពីថ្ងៃទី៥ ខែឧសភា ដល់ថ្ងៃទី៣ ខែមិថុនា ឆ្នាំ២០២២ ត្រឹមវេលាម៉ោង ៥:៣០នាទីល្ងាច។

តាមនីតិវិធីអ្នកស្នើសុំ ឯ.អ ត្រូវបង្ហាញខ្លួនដោយផ្ទាល់នៅចំពោះមុខ គឃ.សប និងមានឈ្មោះក្នុងបញ្ជីបោះឆ្នោតផ្លូវការនៅក្នុងឃុំ សង្កាត់នោះ ដោយត្រូវបំពេញពាក្យស្នើសុំ និងផ្តិតស្នាមម្រាមដៃនៅចំពោះមុខប្រធាន គឃ.សប។ ជាមួយគ្នានោះដែរអ្នកស្នើសុំត្រូវផ្តល់ស្នាមម្រាមដៃតាមការណែនាំរបស់សមាជិក គឃ.សប និងថតរូបសម្រាប់ផ្ទៀងផ្ទាត់ និងទាញទិន្នន័យពីបញ្ជីបោះឆ្នោតផ្លូវការក្នុងប្រព័ន្ធគ្រប់គ្រងទិន្នន័យអ្នកបោះឆ្នោត និងបញ្ជីបោះឆ្នោត។ បន្ទាប់ពីទទួលបានទម្រង់ ឯ.អ អ្នកស្នើសុំត្រូវទៅជួបមេឃុំ ចៅសង្កាត់ដើម្បីចុះហត្ថលេខា និងបោះត្រាផ្តល់សុពលភាពសម្រាប់យកទៅប្រើប្រាស់ក្នុងការបោះឆ្នោត។ ជាលទ្ធផលក្នុងដំណើរការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី៥ ឆ្នាំ២០២២ គឃ.សប បានចេញ ឯ.អ ជូនប្រជាពលរដ្ឋសរុបចំនួន ២៤៣,៤២៩នាក់ (ស្រី ១២៧,៥២១នាក់)។ (ឧបសម្ព័ន្ធ៦)

### ៦.១.៨- ការបង្កើតកម្មវិធីគ្រប់គ្រងការចុះបញ្ជីបេក្ខជននៃគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត

តាមរយៈបទពិសោធន៍ដែលទទួលបានពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់កន្លងមក គ.ជ.ប បានជួបបញ្ហាប្រឈមក្នុងការចុះបញ្ជីបេក្ខជននៃគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត ដោយសារគណបក្សនយោបាយ ឬ/និងបេក្ខជនមួយចំនួនមិនបានអនុវត្តឱ្យបានត្រឹមត្រូវតាមស្មារតីនៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ និងបទបញ្ជា និងនីតិវិធី។ ម្យ៉ាងទៀតដោយសារយន្តការនៃការត្រួតពិនិត្យនៅ គឃ.សប គឺត្រូវធ្វើឡើងដោយដៃ ដែលជាហេតុនាំឱ្យមានឈ្មោះ ឬទិន្នន័យបេក្ខជនមួយចំនួនមិនត្រឹមត្រូវ បេក្ខជនមិនទាន់គ្រប់អាយុ ឬឈរឈ្មោះក្នុងបញ្ជីបេក្ខជនលើសពីមួយគណបក្ស ឬលើសពីមួយឃុំ សង្កាត់។

ផ្តើមចេញពីបញ្ហាប្រឈមនេះ ដើម្បីបង្កលក្ខណៈងាយស្រួលដល់គណបក្សនយោបាយដែលមានបំណងឈរឈ្មោះបោះឆ្នោត ក្នុងការរៀបចំបញ្ជីបេក្ខជននៃគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត និងដើម្បីសម្រួលដល់ គឃ.សប ក្នុងការពិនិត្យលក្ខខណ្ឌរបស់បេក្ខជននៃគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត និងធានាបាននូវភាពត្រឹមត្រូវនៃបញ្ជីបេក្ខជនឈរឈ្មោះបោះឆ្នោត គ.ជ.ប បានដាក់ឱ្យប្រើប្រាស់កម្មវិធីគ្រប់គ្រងការចុះបញ្ជី

បេក្ខជននៃគណបក្សនយោបាយឈរឈ្មោះបោះឆ្នោតតាមប្រព័ន្ធកុំព្យូទ័រ ដែលត្រូវបានអនុវត្តដោយ គឃ.សប និង គណបក្សនយោបាយផ្ទាល់។

### ៦.១.៩- ការបង្កើតកម្មវិធីត្រួតពិនិត្យ ផ្ទៀងផ្ទាត់ និងបូកសរុបលទ្ធផលនៃការបោះឆ្នោត

ដើម្បីកាត់បន្ថយនូវកំហុសឆ្គងក្នុងការត្រួតពិនិត្យ ផ្ទៀងផ្ទាត់លទ្ធផលនៃការបោះឆ្នោត និងការបែងចែកអាសនៈដែលគណនាដោយដៃ ដោយសរសេរ និងដើម្បីឱ្យការងារត្រួតពិនិត្យ ផ្ទៀងផ្ទាត់ និងបែងចែកអាសនៈមានតម្លាភាព ប្រកបដោយភាពត្រឹមត្រូវ គ.ជ.ប បានបង្កើតកម្មវិធីត្រួតពិនិត្យ ផ្ទៀងផ្ទាត់លទ្ធផលនៃការបោះឆ្នោត ដោយប្រើប្រាស់ប្រព័ន្ធកុំព្យូទ័រ ដែលប្រព័ន្ធនេះបានផ្ទុកនូវទម្រង់សំខាន់ៗនៃការបោះឆ្នោត និងការរាប់សន្លឹកឆ្នោត រូបមន្ត និងលទ្ធផលនៃការបែងចែកអាសនៈ ដោយគ្រាន់តែតម្រូវឱ្យអ្នកអនុវត្តប្រើប្រាស់កម្មវិធីទៅតាមលំដាប់លំដោយ និងតាមការណែនាំដែលមាននៅក្នុងកម្មវិធីកុំព្យូទ័រក៏ដូចជាសៀវភៅណែនាំអំពីរបៀបប្រើប្រាស់កម្មវិធីនេះ។

### ៦.១.១០- ការប្រើប្រាស់កម្មវិធីថត បញ្ជូន និងបញ្ចូលទិន្នន័យប្រព័ន្ធទីតាំងសកល GPS នៃទីស្នាក់ការ (គឃ.សប) សាលាឃុំ សង្កាត់ ទីតាំងការិយាល័យបោះឆ្នោត និងទីតាំង (គធ.ខប)

ក្នុងគោលបំណងផ្តល់ភាពងាយស្រួល ឆាប់រហ័ស ចំណេញពេលវេលាដល់អ្នកបោះឆ្នោត និងភាគីពាក់ព័ន្ធក្នុងការស្វែងរកទីតាំង សម្រាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី៥ ឆ្នាំ២០២២ គ.ជ.ប បាននិងបន្តពង្រឹង និងពង្រីកវិសាលភាពនៃការប្រើប្រាស់បច្ចេកវិទ្យាទំនើប ដើម្បីជំនួយដល់ដំណើរការរៀបចំការបោះឆ្នោត ដោយបានបង្កើតកម្មវិធីក្នុងទូរស័ព្ទដៃស្តីពីការប្រើប្រាស់កម្មវិធីថត បញ្ជូន និងបញ្ចូលទិន្នន័យប្រព័ន្ធទីតាំងសកល GPS មានជាអាទិ៍ ទីស្នាក់ការ គឃ.សប សាលាឃុំ សង្កាត់ ទីតាំងការិយាល័យបោះឆ្នោត និងទីតាំង គធ.ខប ទៅក្នុងប្រព័ន្ធប្រតិបត្តិការទូរស័ព្ទដៃទំនើប (APP) “NEC KH”។ កម្មវិធី “NEC KH” ក៏មានប្រមូលផ្តុំនូវឯកសារសំខាន់ៗ ដូចជា អត្ថបទ កម្រងឯកសារ រូបភាព វីដេអូ បញ្ជីឈ្មោះបេក្ខជនឈរឈ្មោះបោះឆ្នោត ព័ត៌មានអំពីលទ្ធផលនៃការបោះឆ្នោត និងទីតាំងដូចមានខាងលើ។

## ៦.២. ការងារឃ្លាំង និងដឹកជញ្ជូនសម្ភារបរិក្ខារ

គ.ជ.ប បានដឹកជញ្ជូនសម្ភារបរិក្ខារពី គ.ជ.ប ទៅ គធ.ខប ពី គធ.ខប ទៅ គឃ.សប និងពី គឃ.សប ទៅ គ.ក.ប/គ.ក.រ ដូចខាងក្រោម ៖

- លើកទី១ ៖ ចាប់ពីថ្ងៃ២៤ ដល់ថ្ងៃទី៣១ ខែមីនា ឆ្នាំ២០២២ ដឹកជញ្ជូនហិបឆ្នោត បន្ទប់សម្ងាត់ ត្រា គឃ.សប ស្លាកសម្គាល់ គឃ.សប ខ្សែអង់តែន អង់តែន អាគុយ កេសកុំព្យូទ័រ និងម៉ាស៊ីនព្រីនធឺ។ សម្ភារមួយចំនួនត្រូវរក្សាទុកនៅ គធ.ខប និងមួយចំនួនទៀត គធ.ខប បានដឹកជញ្ជូនបន្តទៅ គឃ.សប
- លើកទី២ ៖ ចាប់ពីថ្ងៃទី១២ ដល់ថ្ងៃទី១៩ ខែឧសភា ឆ្នាំ២០២២ មានកេសបណ្តុះបណ្តាល កេស គធ.ខប កេស គឃ.សប និង កេស គ.ក.ប/គ.ក.រ ដែលនៅក្នុងនោះមានទម្រង់បែបបទ សោឃ្លុំ ស្បោង កញ្ចប់សុវត្ថិភាព ស្រោមសំបុត្រ សម្ភារទាំងនោះត្រូវបាន គធ.ខប ដឹកជញ្ជូនបន្តទៅ គឃ.សប ចន្លោះពីថ្ងៃទី១៦ ដល់ថ្ងៃទី ២២ ខែឧសភា ឆ្នាំ២០២២
- លើកទី៣ ៖ ចន្លោះពីថ្ងៃទី២៩ ខែឧសភា ដល់ថ្ងៃទី១ ខែមិថុនា ឆ្នាំ២០២២ មានបញ្ជីបោះឆ្នោត សន្លឹកឆ្នោត ត្រាសម្ងាត់ និងទឹកខ្មៅលុបមិនជ្រះ សម្ភារទាំងនេះត្រូវបាន គធ.ខប ដឹកជញ្ជូនបន្តទៅ គឃ.សប និងពី គឃ.សប ទៅ គ.ក.ប ចន្លោះពីថ្ងៃទី២ ដល់ថ្ងៃទី៤ ខែមិថុនា ឆ្នាំ២០២២។

ក្រោយពីថ្ងៃបោះឆ្នោត គធ.ខប បានដឹកជញ្ជូនសម្ភារសេសសល់ពីការបោះឆ្នោតមក គ.ជ.ប ស្របពេលគ្នានឹងការដឹកជញ្ជូនរាល់ស្បោង “ឃ” និងកញ្ចប់ “ឃ ពិសេស”។

## ៧- ការចុះបញ្ជីបេក្ខជននៃគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត

អនុលោមតាម ច.ប.ឃ.ស ប.ន.ឃ.ស និងប្រតិទិនសម្រាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី៥ ដើម្បីឱ្យដំណើរការនៃការចុះបញ្ជីបេក្ខជននៃគណបក្សនយោបាយ ប្រព្រឹត្តទៅត្រឹមត្រូវ ទាន់ពេលវេលា ហើយគណបក្សនយោបាយមានការយល់ដឹង ជាទូទៅមុនដំណើរការអនុវត្តការចុះបញ្ជីបេក្ខជន គ.ជ.ប បានធ្វើការផ្សព្វផ្សាយការងារនេះដល់ភាគីពាក់ព័ន្ធជាពិសេស គណបក្សនយោបាយទាំងអស់ តាមរយៈការផ្សព្វផ្សាយសេចក្តីជូនដំណឹង សេចក្តីប្រកាស ការបណ្តុះបណ្តាលជាដើម ធ្វើយ៉ាងណាឱ្យគណបក្សនយោបាយបានត្រៀមលក្ខណៈសម្បត្តិជាមុនក្នុងការរៀបចំបញ្ជីបេក្ខជនរបស់ខ្លួន ព្រមទាំងសំណុំឯកសារពាក់ព័ន្ធនានាដែលច្បាប់បោះឆ្នោត ក៏ដូចជាបទបញ្ជា និងនីតិវិធីតម្រូវ ក្នុងការដាក់ពាក្យសុំចុះបញ្ជីបេក្ខជននៃគណបក្សនយោបាយទៅ គឃ.សបឱ្យបានទាន់ពេលវេលា និងត្រឹមត្រូវ។ ដំណាក់កាលចុះបញ្ជីបេក្ខជននៃគណបក្សនយោបាយ ត្រូវបានចែកជា ២ ធំៗ គឺដំណាក់កាលត្រៀមរៀបចំបញ្ជីបេក្ខជននៃគណបក្សនយោបាយ និងដំណាក់កាលចុះបញ្ជីបេក្ខជននៃគណបក្សនយោបាយ។

### ៧.១- ការត្រៀមរៀបចំបញ្ជីបេក្ខជននៃគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត

ការរៀបចំបញ្ជីបេក្ខជននៃគណបក្សនយោបាយឈរឈ្មោះបោះឆ្នោតមាន ២របៀប គឺគណបក្សនយោបាយអាចរៀបចំបញ្ជីបេក្ខជននៃគណបក្សនយោបាយដោយដៃ និងគណបក្សនយោបាយអាចស្នើសុំបង្កើតគណនីប្រើប្រាស់កម្មវិធីរៀបចំបញ្ជីបេក្ខជននៃគណបក្សនយោបាយតាមកម្មវិធី។

ការទទួលពាក្យសុំបង្កើតគណនីប្រើប្រាស់កម្មវិធីរៀបចំបញ្ជីបេក្ខជននៃគណបក្សនយោបាយ គឺចាប់ពីថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ២០២២ និងបញ្ចប់ត្រឹមថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០២២។ កម្មវិធីរៀបចំបញ្ជីបេក្ខជននេះ ត្រូវបិទនៅថ្ងៃទី១ ខែមីនា ឆ្នាំ២០២២។

គណបក្សនយោបាយដែលមានបំណងរៀបចំបញ្ជីបេក្ខជននៃគណបក្សនយោបាយតាមកម្មវិធី ត្រូវដាក់ពាក្យស្នើសុំបង្កើតគណនីមក គ.ជ.ប។ បន្ទាប់ពីបានទទួលគណនីពី គ.ជ.ប គណបក្សនយោបាយអាចបង្កើតគណនីប្រើប្រាស់ ដោយធ្វើការបង្កើតគណនីតាមរាជធានី ខេត្ត និងក្រុង ស្រុក ខណ្ឌ តាមការចាំបាច់ និងថ្នាក់រាជធានី ខេត្ត អាចបង្កើតគណនីតាមក្រុង ស្រុក ខណ្ឌ ដើម្បីជួយរៀបចំបញ្ជីបេក្ខជន ឈរឈ្មោះបោះឆ្នោតតាមមណ្ឌលឈរឈ្មោះតាមការកំណត់។

បន្ទាប់ពីរៀបចំបញ្ជីបេក្ខជនតាមកម្មវិធីរួចហើយ គណបក្សនយោបាយ ត្រូវបោះពុម្ពចេញពីកម្មវិធីនូវបញ្ជីរាយនាមបេក្ខជនឈរឈ្មោះបោះឆ្នោត សម្រាប់ភ្ជាប់ជាមួយនឹងពាក្យសុំចុះបញ្ជីបេក្ខជនឈរឈ្មោះបោះឆ្នោត និងសេចក្តីសម្រេចរបស់ គឃ.សប (ទ.១០០៨) និងបោះពុម្ពលិខិតបញ្ជាក់ពីមេឃុំ ចៅសង្កាត់ថា ពិតជាបានចុះឈ្មោះ និងមានឈ្មោះក្នុងបញ្ជីឈ្មោះអ្នកបោះឆ្នោតក្នុងឃុំ សង្កាត់ ដែលត្រូវយកទៅជូនមេឃុំ ចៅសង្កាត់បញ្ជាក់សម្រាប់ភ្ជាប់ជាមួយនឹង ទ.១០០៨។ ដល់កាលបរិច្ឆេទកំណត់នៃការដាក់ពាក្យសុំចុះបញ្ជីបេក្ខជននៃគណបក្សនយោបាយ គណបក្សនយោបាយ ត្រូវយកសំណុំឯកសារពាក់ព័ន្ធសម្រាប់ភ្ជាប់ជាមួយ ទ.១០០៨ ដើម្បីយកទៅដាក់នៅ គឃ.សប។

ជាលទ្ធផលដំណាក់កាលរៀបចំបញ្ជីបេក្ខជននៃគណបក្សនយោបាយតាមកម្មវិធី មានគណបក្សនយោបាយចំនួន ១១ បានដាក់ពាក្យសុំរៀបចំបញ្ជីបេក្ខជន រួមមាន គណបក្សប្រជាជនកម្ពុជា គណបក្សឆន្ទៈខ្មែរ គណបក្សកម្ពុជានិយម គណបក្សសំបុកឃ្មុំសង្គមប្រជាធិបតេយ្យ គណបក្សសញ្ជាតិកម្ពុជា គណបក្សឯកភាពជាតិខ្មែរ គណបក្សជនជាតិដើមប្រជាធិបតេយ្យកម្ពុជា គណបក្សភ្លើងទៀន គណបក្សហ្វ៊ុនស៊ិនប៉ិច គណបក្សខ្មែរតែមួយ និងគណបក្សប្រជាធិបតេយ្យមូលដ្ឋាន។

### ៧.២. ដំណាក់កាលចុះបញ្ជីបេក្ខជននៃគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត

កាលបរិច្ឆេទនៃការចុះបញ្ជីបេក្ខជននៃគណបក្សនយោបាយ សម្រាប់ការបោះឆ្នោតជ្រើសរើស

ក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី៥ ឆ្នាំ២០២២ មានរយៈពេល ៣ថ្ងៃ គឺចាប់ពីថ្ងៃទី ៤ដល់ថ្ងៃទី៦ ខែមីនា ឆ្នាំ២០២២ គណបក្សនយោបាយដែលបានចុះបញ្ជីត្រឹមត្រូវនៅក្រសួងមហាផ្ទៃ ហើយដែលមានបំណងសុំចុះបញ្ជីបេក្ខជននៃគណបក្សនយោបាយ ត្រូវដាក់ពាក្យសុំចុះបញ្ជីបេក្ខជននៅ គឃ.សប។ ក្នុងអំឡុងពេលកំណត់នៃការដាក់ពាក្យសុំចុះបញ្ជីបេក្ខជននៃគណបក្សនយោបាយ មានគណបក្សនយោបាយចំនួន **១៧** (ដប់ប្រាំពីរ) បានដាក់ពាក្យសុំចុះបញ្ជីបេក្ខជននៃគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត។ ផ្អែកតាម ច.ប.ឃ.ស និង ប.ន.ឃ.ស ព្រមទាំងប្រតិទិនការងារដែលបានកំណត់ បន្ទាប់ពីថ្ងៃទទួលពាក្យសុំចុះបញ្ជីបេក្ខជន គឃ.សប ត្រូវពិនិត្យពាក្យសុំចុះបញ្ជីបេក្ខជនទាំងនោះក្នុងរយៈពេល ១ថ្ងៃ និងបិទផ្សាយជាសាធារណៈនៅទីស្នាក់ការរបស់ខ្លួននូវបញ្ជីបេក្ខជននៃគណបក្សនយោបាយទាំងអស់ ដែលបានទទួលពាក្យសុំចុះបញ្ជីបេក្ខជនក្នុងរយៈពេលយ៉ាងយូរ ៣ថ្ងៃ បន្ទាប់ពីថ្ងៃពិនិត្យពាក្យសុំចុះបញ្ជីបេក្ខជនដើម្បីឱ្យប្រជាពលរដ្ឋដែលមានសិទ្ធិបោះឆ្នោតក្នុងឃុំ សង្កាត់ផ្ដល់មតិយោបល់ចំពោះបញ្ជីបេក្ខជនមក គឃ.សប។ ទោះបី គ.ជ.ប បានផ្សព្វផ្សាយ និងជូនដំណឹងដល់គណបក្សនយោបាយជាមុនដើម្បីត្រៀមលក្ខណសម្បត្តិយ៉ាងណាក្ដីក៏ដំណើរការចុះបញ្ជីបេក្ខជននៅតាមឃុំ សង្កាត់នីមួយៗមានជួបបញ្ហាមួយចំនួនដូចជា គណបក្សនយោបាយដាក់បេក្ខជនមិនគ្រប់ចំនួនតាមច្បាប់កំណត់ ហើយបេក្ខជនសុំលាលែងនៅពេលបិទផ្សាយឱ្យប្រជាពលរដ្ឋផ្ដល់មតិយោបល់ ករណីនេះតម្រូវឱ្យ គឃ.សប ធ្វើការជូនដំណឹងឱ្យគណបក្សនយោបាយសាមីធ្វើការកែតម្រូវចំណុចខ្វះខាត ក្នុងរយៈពេលយ៉ាងយូរ ៥ថ្ងៃ បន្ទាប់ពីថ្ងៃទទួលបានលិខិតជូនដំណឹង។ បន្ទាប់ពីការកែតម្រូវរបស់គណបក្សនយោបាយលើចំណុចខ្វះខាតបានត្រឹមត្រូវហើយបណ្ដឹងតវ៉ាទាក់ទងនឹងការសុំចុះបញ្ជីបេក្ខជនត្រូវបានដោះស្រាយរួចរាល់ គឃ.សប បានបិទផ្សាយជាសាធារណៈនូវបញ្ជីបេក្ខជនដំបូងក្នុងរយៈពេល ៣ថ្ងៃ នៅទីស្នាក់ការរបស់ខ្លួន ដើម្បីឱ្យប្រជាពលរដ្ឋមានសិទ្ធិបោះឆ្នោតក្នុងឃុំ សង្កាត់ពិនិត្យមើល និងអាចប្ដឹងជំទាស់ជាលាយលក្ខណ៍អក្សរមក គ.ជ.ប អំពីបេក្ខជន ឬបញ្ជីបេក្ខជនដំបូងដែលមិនបានបំពេញលក្ខខណ្ឌគ្រប់គ្រាន់តាមការកំណត់របស់ច្បាប់បោះឆ្នោត។ នៅក្នុងដំណាក់កាលនៃការបិទផ្សាយបញ្ជីបេក្ខជនដំបូងនេះ ពិនិត្យឃើញថា មានពាក្យបណ្ដឹងជំទាស់មក គ.ជ.ប អំពីការយកឈ្មោះរបស់ខ្លួនមកធ្វើជាបេក្ខជនដោយខ្លួនពុំបានដឹង បំពេញប្រវត្តិរូបជូនបេក្ខជនដែលផ្ទុយពី ច.ប.ឃ.ស និង ប.ន.ឃ.ស កំណត់ ការប្រព្រឹត្តផ្ទុយពីច្បាប់បែបបទនេះ ត្រូវបាន គ.ជ.ប បើកសវនាការសម្រេចលុបបេក្ខភាពឈរឈ្មោះរបស់បេក្ខជន ឬ/និងលុបបញ្ជីបេក្ខជននៃគណបក្សនយោបាយ។ បញ្ជីបេក្ខជនដំបូងនឹងក្លាយជាបញ្ជីបេក្ខជនផ្លូវការប្រសិនបើគ្មានបណ្ដឹងជំទាស់មកលើបញ្ជីនេះ ឬបណ្ដឹងជំទាស់ត្រូវបានដោះស្រាយចប់ជាស្ថាពរ។

លទ្ធផលផ្លូវការនៃការចុះបញ្ជីបេក្ខជននៃគណបក្សនយោបាយ មានគណបក្សនយោបាយចំនួន **១៧** ត្រូវបាន គឃ.សប សម្រេចយល់ព្រមឱ្យចុះបញ្ជីបេក្ខជនឈរឈ្មោះ មានបេក្ខជនឈរឈ្មោះសរុបចំនួន **៨៦,០៩២**នាក់ (ស្រី **២៧,៨១៣**នាក់)។ (ឧបសម្ព័ន្ធ៧)

ក្នុងចំណោមគណបក្សនយោបាយឈរឈ្មោះទាំង ១៧ ខាងលើ គណបក្សប្រជាជនកម្ពុជា បានដាក់បញ្ជីបេក្ខជនឈរឈ្មោះគ្រប់ឃុំ សង្កាត់ទាំង ១,៦៥២។ ចំណែកឯគណបក្សដែលបានដាក់បេក្ខជនឈរឈ្មោះនៅឃុំ សង្កាត់តិចជាងគេ គឺគណបក្សខ្មែរអភិវឌ្ឍន៍សេដ្ឋកិច្ចចំនួន ៤ឃុំ។

បញ្ជីបេក្ខជននៃគណបក្សនយោបាយបានទទួលស្គាល់ផ្លូវការរួចហើយ មានបេក្ខជនឈរឈ្មោះនៃគណបក្សនយោបាយមួយចំនួនបានលាលែង ឬមរណភាព ឬប្រាសចាកសមាជិកភាពពីគណបក្សនយោបាយ ដោយករណីត្រូវបានតម្រូវឱ្យគណបក្សនយោបាយសាមីធ្វើលិខិតជូនដំណឹងជាបន្ទាន់មក គធ.ខប ពាក់ព័ន្ធឱ្យបានមុនថ្ងៃ គធ.ខប ស្រង់ឈ្មោះបេក្ខជនជាប់ឆ្នោត។ នៅមុនពេល គធ.ខប ស្រង់ឈ្មោះបេក្ខជនជាប់ឆ្នោត គណបក្សភ្លើងទៀននៅសង្កាត់អូរបែកក្អម បេក្ខជនរបស់ខ្លួនទាំងអស់ បានលាលែង ហើយត្រូវបានដាក់បេក្ខជនបម្រុងបន្ថែមជាថ្មី ដើម្បី

ទទួលបានអាសនៈ។ ចំណែកឯបេក្ខជននៃគណបក្សនយោបាយផ្សេងទៀត មានបេក្ខជនលាលែង ឬមរណភាព ឬប្រាសចាកសមាជិកភាព មិនប៉ះពាល់ដល់ការខ្វះបេក្ខជនទទួលបានអាសនៈទេ គឺត្រូវរំកិលបេក្ខជនបន្ទាប់ដើម្បីទទួលបានអាសនៈ។

### ៧.៣. ការចាប់ឆ្នោតដើម្បីកំណត់លំដាប់លេខរៀងបញ្ជីបេក្ខជន

បន្ទាប់ពីបញ្ជីបេក្ខជនក្លាយជាបញ្ជីផ្លូវការ គឃ.សប បានអនុវត្តការចាប់ឆ្នោតដើម្បីកំណត់លំដាប់លេខរៀងបញ្ជីបេក្ខជនដែលត្រូវដាក់លើសន្លឹកឆ្នោតជាបន្តបន្ទាប់តាមឃុំ សង្កាត់នីមួយៗ ដោយឡែកពីគ្នាដោយផ្អែកលើបញ្ជីបេក្ខជនផ្លូវការនៃឃុំ សង្កាត់នោះ។ កម្មវិធីចាប់ឆ្នោតបានប្រព្រឹត្តទៅជាសាធារណៈតាមកាលបរិច្ឆេទ និងទីកន្លែងដែលកំណត់ដោយ គឃ.សប និងដោយមានការចូលរួមពីតំណាងគណបក្សនយោបាយដែលបានចុះបញ្ជីបេក្ខជនឈរឈ្មោះបោះឆ្នោតក្នុងឃុំ សង្កាត់ អ្នកសង្កេតការណ៍ ព្រមទាំងអ្នកសារព័ត៌មានផងដែរ។ ក្នុងគោលបំណងបង្កលក្ខណងាយស្រួលដល់ដំណើរការនៃការបញ្ចូល និងបញ្ជូនលទ្ធផលនៃការចាប់ឆ្នោត គឃ.សប ត្រូវបានអនុញ្ញាតឱ្យប្រើប្រាស់កម្មវិធីដោយតម្រូវឱ្យសមាជិក គឃ.សប ទទួលបន្ទុកលើការងាររដ្ឋបាល ត្រូវបញ្ចូលទិន្នន័យលទ្ធផលលំដាប់លេខរៀងទៅក្នុងប្រព័ន្ធកុំព្យូទ័រ ហើយបោះពុម្ពកំណត់ហេតុនៃការចាប់ឆ្នោតលំដាប់លេខរៀងបញ្ជីបេក្ខជននៃគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត (ទ.១១២១) ដោយត្រូវដាក់ភ្ជាប់ជាមួយនូវសន្លឹកឆ្នោតរបស់គណបក្សនយោបាយដែលបានចុះលេខរៀងហើយតំណាងគណបក្សនយោបាយអាចចូលរួមចុះហត្ថលេខាលើកំណត់ហេតុនេះ។ បន្ទាប់មកត្រូវស្កេន ទ.១១២១ ដែលបានចុះហត្ថលេខាចូលក្នុងប្រព័ន្ធកុំព្យូទ័រទុកសម្រាប់បម្រើឱ្យការត្រួតពិនិត្យ និងផ្ទៀងផ្ទាត់។ លំដាប់លេខរៀងគណបក្សនយោបាយនៅលើសន្លឹកឆ្នោតមានភាពខុសគ្នាតាមឃុំ សង្កាត់នីមួយៗទូទាំងប្រទេសដោយផ្អែកលើលទ្ធផលនៃការចាប់ឆ្នោត។ លទ្ធផលនៃការចាប់ឆ្នោត និងបញ្ជីបេក្ខជនផ្លូវការត្រូវបាន គឃ.សប បញ្ជូនមក គ.ជ.ប តាមរយៈ គធ.ខប ជាបន្តបន្ទាប់តាមប្រតិទិនការងាររបស់ គ.ជ.ប។ ទន្ទឹមនេះ គ.ជ.ប ក៏បានបង្ហោះអំពីលំដាប់លេខរៀងគណបក្សនយោបាយនៅលើសន្លឹកឆ្នោតតាមរាជធានី ខេត្តនីមួយៗនៅលើគេហទំព័រ និងកម្មវិធីទូរស័ព្ទដៃ NEC KH របស់ គ.ជ.ប ជូនសាធារណជនជ្រាប។

## ៨- ការចុះឈ្មោះអ្នកសង្កេតការណ៍ អ្នកសារព័ត៌មាន និងភ្នាក់ងារគណបក្សនយោបាយ

### ៨.១- អ្នកសង្កេតការណ៍ជាតិ

ដំណើរការនៃការចុះឈ្មោះអ្នកសង្កេតការណ៍ជាតិ ត្រូវបានអនុវត្តចាប់ពីថ្ងៃទី១៥ ខែកុម្ភៈ ដល់ថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០២២ ក្នុងគោលបំណងឱ្យសមាគម និងអង្គការមិនមែនរដ្ឋាភិបាលមានឱកាសបានដាក់អ្នកសង្កេតការណ៍របស់ខ្លួនចូលរួមសង្កេតការណ៍ គ.ជ.ប បានសម្រេចពន្យារពេលនៃការដាក់ និងការទទួលពាក្យសុំចុះឈ្មោះអ្នកសង្កេតការណ៍ជាតិ រហូតដល់ថ្ងៃទី២៨ ខែឧសភា ឆ្នាំ២០២២។ គ.ជ.ប បានទទួលស្គាល់អ្នកសង្កេតការណ៍ជាតិចំនួន ៧២ សមាគម អង្គការមិនមែនរដ្ឋាភិបាលជាតិ ដែលមានចំនួនសរុប ៧៤,៨៨៥នាក់ (ស្រី ៤៥,៤៧១នាក់) ក្នុងនោះអ្នកសង្កេតការណ៍ចល័តចំនួន ៨៨នាក់ (ស្រី ២៩នាក់) និងបានបដិសេធចំនួន ២៣នាក់ (ស្រី ១០នាក់)។ (ឧបសម្ព័ន្ធ៨)

### ៨.២- អ្នកសង្កេតការណ៍អន្តរជាតិ

ដំណើរការនៃការចុះឈ្មោះអ្នកសង្កេតការណ៍អន្តរជាតិ ត្រូវបានអនុវត្តចាប់ពីថ្ងៃទី១៥ ខែកុម្ភៈ ដល់ថ្ងៃទី១ ខែមិថុនា ឆ្នាំ២០២២។ គ.ជ.ប បានទទួលស្គាល់ជាផ្លូវការអ្នកសង្កេតការណ៍អន្តរជាតិចំនួន ១៩សមាគម អង្គការអន្តរជាតិ ដែលមានចំនួនសរុប ១១០នាក់ (ស្រី ៥០នាក់)។ (ឧបសម្ព័ន្ធ៩)

### ៨.៣- ភ្ញៀវពិសេស

គ.ជ.ប បានទទួលភ្ញៀវពិសេសមកពីប្រតិភូនៃស្ថានទូត ឬស្ថានតំណាងបរទេសប្រចាំនៅព្រះរាជាណាចក្រកម្ពុជា ដែលចូលរួមពិនិត្យមើលដំណើរការបោះឆ្នោតមិនមែនក្នុងនាមជាអ្នកសង្កេតការណ៍ និងមិនតម្រូវឱ្យចុះវត្តមានទេ ដែលមានចំនួន ៥ស្ថាប័ន សរុបចំនួន ២៣នាក់ (ស្រី ៦នាក់)។ (ឧបសម្ព័ន្ធ១០)

### ៨.៤- អ្នកសារព័ត៌មានជាតិ

ដំណើរការនៃការចុះឈ្មោះអ្នកសារព័ត៌មានជាតិ ត្រូវបានអនុវត្តចាប់ពីថ្ងៃទី១៥ ខែកុម្ភៈ ដល់ថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០២២។ គ.ជ.ប បានទទួលស្គាល់អ្នកសារព័ត៌មានជាតិចំនួន ៨០ ដែលមានចំនួនសរុប ៧៧៥នាក់ (ស្រី ១០២នាក់)។ (ឧបសម្ព័ន្ធ១១)

### ៨.៥- អ្នកសារព័ត៌មានអន្តរជាតិ

ដំណើរការនៃការចុះឈ្មោះអ្នកសារព័ត៌មានអន្តរជាតិ ត្រូវបានអនុវត្តចាប់ពីថ្ងៃទី១៥ ខែកុម្ភៈ ដល់ថ្ងៃទី១ ខែមិថុនា ឆ្នាំ២០២២។ គ.ជ.ប បានទទួលស្គាល់អ្នកសារព័ត៌មានអន្តរជាតិចំនួន ២០ ដែលមានចំនួនសរុប ៣៩នាក់ (ស្រី ៨នាក់)។ (ឧបសម្ព័ន្ធ១២)

### ៨.៦- ភ្នាក់ងារគណបក្សនយោបាយ

គណបក្សនយោបាយដែលមានបញ្ជីបេក្ខជនឈរឈ្មោះបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី៥ ឆ្នាំ២០២២ ត្រូវដាក់ពាក្យសុំចុះឈ្មោះជាភ្នាក់ងាររបស់ខ្លួនទៅ គឃ.សប ក្នុងរយៈពេលយ៉ាងយូរ ៧ថ្ងៃ បន្ទាប់ពីកាលបរិច្ឆេទនៃការបិទផ្សាយបញ្ជីបេក្ខជនផ្លូវការ។ គឃ.សប បានទទួលស្គាល់ជាផ្លូវការភ្នាក់ងារគណបក្សនយោបាយចំនួន ១៧គណបក្ស ដែលមានចំនួនភ្នាក់ងារសរុប ៨៨,០៥០នាក់ (ស្រី ២៦,១៥៥នាក់) ក្នុងនោះភ្នាក់ងារពេញសិទ្ធិសរុបចំនួន ៥៣,៤១១នាក់ (ស្រី ១៤,៨៣៩នាក់) និងភ្នាក់ងារបម្រុងសរុបចំនួន ៣៤,៦៣៩នាក់ (ស្រី ១១,៣១៦នាក់)។ (ឧបសម្ព័ន្ធ១៣)

## ៩. ការឃោសនាបោះឆ្នោត

ការឃោសនាបោះឆ្នោតមានរយៈពេល ១៤ថ្ងៃ ចាប់ផ្តើមពីថ្ងៃទី២១ ខែឧសភា ដល់ថ្ងៃទី៣ ខែមិថុនា ឆ្នាំ២០២២ និងមានបំណងឱ្យគណបក្សនយោបាយដែលបានអនុញ្ញាតឱ្យចុះបញ្ជីបេក្ខជន និងបេក្ខជន ធ្វើការផ្សព្វផ្សាយអំពីគោលនយោបាយ និងកម្មវិធីនយោបាយរបស់ខ្លួនក្នុងការអភិវឌ្ឍឃុំ សង្កាត់ ដល់អ្នកបោះឆ្នោត ហើយគ្រប់សកម្មភាពនៃការឃោសនាបោះឆ្នោតត្រូវបញ្ចប់ ២៤ម៉ោងមុនថ្ងៃបោះឆ្នោត។ សកម្មភាពឃោសនាបោះឆ្នោតដោយឧបករណ៍គ្រឿងបំពងសំឡេង ត្រូវបានហាមឃាត់ចាប់ពីម៉ោង១២ថ្ងៃត្រង់ ដល់ម៉ោង ២រសៀល ហាមឃាត់នៅក្បែរមន្ទីរពេទ្យ សាលារៀន ឬគ្រឹះស្ថានសិក្សានានាក្នុងម៉ោងសិក្សាលើកលែងតែនៅក្រៅម៉ោងសិក្សា។ ការហែក្បួនឃោសនាបោះឆ្នោតតាមឃុំ សង្កាត់នីមួយៗ ត្រូវបានកំណត់យ៉ាងច្រើនតែ ២លើកប៉ុណ្ណោះនៅក្នុងឃុំ សង្កាត់ សម្រាប់គណបក្សដែលមានបេក្ខជនឈរឈ្មោះបោះឆ្នោត។

យុទ្ធនាការឃោសនាបោះឆ្នោតនេះ គណបក្សនយោបាយចំនួន ១៧ បានធ្វើការឃោសនារកសំឡេងឆ្នោតតាមមធ្យោបាយផ្សេងៗ ជាទ្រង់ទ្រាយធំ និងទ្រង់ទ្រាយតូចនៅតាមបណ្តាឃុំ សង្កាត់ទូទាំងប្រទេសទៅតាមលទ្ធភាពរបស់ខ្លួនដោយបានធ្វើការជួបជុំ ចែកខិត្តប័ណ្ណ និងចាក់មេក្រូផ្សព្វផ្សាយនៅទីស្នាក់របស់របស់ខ្លួន និងចល័តតាមភូមិក្នុងឃុំ សង្កាត់ដែលគណបក្សខ្លួនបានឈរឈ្មោះបោះឆ្នោត។ នៅថ្ងៃចុងក្រោយនៃការឃោសនាបោះឆ្នោតគណបក្សនយោបាយបានធ្វើសកម្មភាពឃោសនាយ៉ាងផុលផុសជាទ្រង់ទ្រាយធំ ដូចជានៅរាជធានីភ្នំពេញមានគណបក្សនយោបាយចំនួន ៣ មានអ្នកចូលរួមសរុបប្រមាណ ៥៣,៨០០នាក់ ខេត្តសៀមរាបមានគណបក្សនយោបាយចំនួន ៣ ដែលមានអ្នកចូលរួមសរុបប្រមាណ ៧២,០៦៤នាក់ ដោយឡែកនៅខេត្តស្វាយរៀងមានគណបក្សនយោបាយចំនួន ៤ ដែលមានអ្នកចូលរួមសរុបប្រមាណ ៣១,៣៦២នាក់។

ក្នុងនោះដែរ គ.ជ.ប បានបង្កើតកម្មវិធីស្មើភាព ដើម្បីផ្សព្វផ្សាយនៅលើទូរទស្សន៍ជាតិកម្ពុជា និងបានចេញគោលការណ៍សម្រាប់អង្គការមិនមែនរដ្ឋាភិបាលជាតិ និងអន្តរជាតិ និងប្រព័ន្ធផ្សព្វផ្សាយព័ត៌មានស្តីពីការ

រៀបចំកម្មវិធីសំណួរ-ចម្លើយ ឬពិភាក្សាអំពីគោលនយោបាយរបស់គណបក្សនយោបាយ និងសម្រាប់ស្ថានីយវិទ្យុ និងទូរទស្សន៍ ក្នុងការលក់ ឬជួលម៉ោងផ្សព្វផ្សាយឱ្យគណបក្សនយោបាយ ធ្វើការផ្សព្វផ្សាយអំពីគោលនយោបាយ និងកម្មវិធីនយោបាយក្នុងអំឡុងពេលឃោសនាបោះឆ្នោត ដើម្បីឱ្យគណបក្សនយោបាយមានឱកាសស្មើគ្នាក្នុងការផ្សព្វផ្សាយកម្មវិធីនយោបាយតាមវិទ្យុ និងទូរទស្សន៍ឯកជន ជូនដល់អ្នកបោះឆ្នោត។

ដោយមានកិច្ចសហការល្អពីគ្រប់ភាគីពាក់ព័ន្ធគ្រប់លំដាប់ថ្នាក់ ពិសេសគណបក្សនយោបាយទាំងអស់គោរពបានល្អនូវនីតិវិធីនៃការឃោសនាបោះឆ្នោត បានធ្វើឱ្យដំណើរការនៃការឃោសនាបោះឆ្នោតរបស់គណបក្សនយោបាយនៅតាមឃុំ សង្កាត់ទូទាំងប្រទេសប្រព្រឹត្តទៅក្នុងបរិយាកាសល្អ គ្មានអំពើហិង្សា គ្មានការគំរាមកំហែង មានសន្តិសុខ និងសណ្តាប់ធ្នាប់ល្អ។

## ១០. ការបោះឆ្នោត ការរាប់សន្លឹកឆ្នោត និងការបិទផ្សាយលទ្ធផលនៅការិយាល័យបោះឆ្នោត

### ១០.១- ការបើកការិយាល័យបោះឆ្នោត

នៅវេលាម៉ោង ៧:០០នាទីព្រឹក ថ្ងៃអាទិត្យទី៥ ខែមិថុនា ឆ្នាំ២០២២ ការិយាល័យបោះឆ្នោតទាំង ២៣,៦០២ នៃរាជធានី ខេត្តទាំង ២៥ នៅទូទាំងប្រទេសបានបើកដំណើរការស្របតាមការកំណត់។ ប្រធាន គ.ក.ប បានប្រកាសអញ្ជើញភ្នាក់ងារគណបក្សនយោបាយ អ្នកសង្កេតការណ៍ សមាសភាព គ.ក.ប ឱ្យបោះឆ្នោតមុនគេប្រសិនបើពួកគាត់មានឈ្មោះក្នុងបញ្ជីបោះឆ្នោតនៃការិយាល័យនោះ។ អ្នកសង្កេតការណ៍បានចុះវត្តមានលើបញ្ជីវត្តមានអ្នកសង្កេតការណ៍ក្នុងអំឡុងពេលបោះឆ្នោត និងរាប់សន្លឹកឆ្នោត ទ.១១២០ ដោយមានបញ្ជាក់ពីម៉ោងចូល និងម៉ោងចេញ។ ការបោះឆ្នោតបានប្រព្រឹត្តទៅដោយរលូន ស្របតាមច្បាប់ បទបញ្ជា និងនីតិវិធី ដោយបានអនុវត្តយ៉ាងខ្ជាប់ខ្ជួននូវវិធានការការពារ និងទប់ស្កាត់ការឆ្លងរាលដាលជំងឺកូវីដ-១៩ នៅក្នុងការិយាល័យបោះឆ្នោត។

### ១០.២- ការបិទការិយាល័យបោះឆ្នោត

បន្ទាប់ពីអ្នកបោះឆ្នោតបានទៅបោះឆ្នោតរួចរាល់ គណៈកម្មការការិយាល័យបោះឆ្នោតនៅទូទាំងប្រទេសបានប្រកាសបិទការិយាល័យបោះឆ្នោតនៅម៉ោង ៣:០០នាទីរសៀលតាមការកំណត់។ បន្ទាប់មកគណៈកម្មការការិយាល័យបានអនុវត្តនីតិវិធីត្រួតពិនិត្យផ្ទៀងផ្ទាត់ចំនួនអ្នកបោះឆ្នោត និងសន្លឹកឆ្នោតស្របតាមបទបញ្ជា និងនីតិវិធី និងប្រកាសជូនភ្នាក់ងារគណបក្សនយោបាយ និងអ្នកសង្កេតការណ៍ដែលមានវត្តមាន។

ជាលទ្ធផលក្នុងចំណោមអ្នកមានឈ្មោះក្នុងបញ្ជីបោះឆ្នោតសរុបចំនួន ៩,២០៥,៦៨១នាក់ មានអ្នកទៅបោះឆ្នោតមានចំនួន ៧,៣៩៤,៤២៧នាក់ ស្មើនឹង ៨០.៣២%។ (ឧបសម្ព័ន្ធទី១៤)

### ១០.៣- ការរាប់សន្លឹកឆ្នោត និងការបិទផ្សាយលទ្ធផលបឋមនៅការិយាល័យបោះឆ្នោត

ការរាប់សន្លឹកឆ្នោតធ្វើនៅតាមការិយាល័យបោះឆ្នោតនីមួយៗ បន្ទាប់ពីបិទការិយាល័យបោះឆ្នោត។ គណៈកម្មការការិយាល័យបោះឆ្នោតក្លាយជាគណៈកម្មការការិយាល័យរាប់សន្លឹកឆ្នោត (គ.ក.រ) ហើយបានអនុវត្តនីតិវិធីនៃការរាប់សន្លឹកឆ្នោតចន្លោះពីម៉ោង ១៥:២០នាទីល្ងាច ដល់ម៉ោង ១៩:៥០នាទីយប់។ ការរាប់សន្លឹកឆ្នោតត្រូវបានប្រព្រឹត្តទៅដោយរលូន ស្របតាមច្បាប់ បទបញ្ជា និងនីតិវិធី ក្រោមការសង្កេតការណ៍ពីភ្នាក់ងារគណបក្សនយោបាយ និងអ្នកសង្កេតការណ៍។ លទ្ធផលនៃការរាប់សន្លឹកឆ្នោតនេះត្រូវបានកត់ត្រាចូលក្នុងកំណត់ហេតុនៃការរាប់សន្លឹកឆ្នោតតាមការិយាល័យ (ទ.១១០២) និងត្រូវដាក់បង្ហាញនៅចំពោះមុខភ្នាក់ងារគណបក្សនយោបាយ និងអ្នកសង្កេតការណ៍ឱ្យចូលរួមចុះហត្ថលេខាជាសាក្សី ហើយត្រូវបានបិទផ្សាយនៅមុខទីតាំងការិយាល័យបោះឆ្នោត។

### ១០.៤- ការសម្របសម្រួល ការបញ្ចូល ការបញ្ជូនទិន្នន័យលទ្ធផលបឋមមក គ.ជ.ប

បន្ទាប់ពីបញ្ចប់ការរាប់សន្លឹកឆ្នោតនៅគ្រប់ការិយាល័យបោះឆ្នោតក្នុងឃុំ សង្កាត់ គឃ.សប បានទទួលលទ្ធផលបឋមនៃការបោះឆ្នោតពីគ្រប់ការិយាល័យបោះឆ្នោតក្នុងឃុំ សង្កាត់ ដោយធ្វើការត្រួតពិនិត្យ ផ្ទៀងផ្ទាត់

បូកសរុបលទ្ធផលបឋមនៃការបោះឆ្នោតដោយផ្អែកលើទ.១១០១ ទ.១១០២ និងទ.១១០៨ ដែលទទួលបានពីគ្រប់ការិយាល័យបោះឆ្នោតក្នុងឃុំ សង្កាត់។ ទ.១១០២ ត្រូវបាន គឃ.សប បោះពុម្ព ដើម្បីបិទផ្សាយនៅមុខទីស្នាក់ការ គឃ.សប។ រូបភាព និងទិន្នន័យកំណត់ហេតុនៃការបោះឆ្នោត ទ.១១០១ តារាងកត់ត្រាសំឡេងឆ្នោត ទ.១១០៨ និងកំណត់ហេតុនៃការរាប់សន្លឹកឆ្នោត ទ.១១០២ ត្រូវបាន គឃ.សប នៃរាជធានី ខេត្តនីមួយៗបញ្ជូនមកជាបន្តបន្ទាប់នៅវេលាល្ងាចនៃថ្ងៃបោះឆ្នោតមក គ.ជ.ប តាមប្រព័ន្ធអ៊ីនធឺណិតដើម្បីធ្វើការផ្សព្វផ្សាយជូនដល់សាធារណជន និងភាគីពាក់ព័ន្ធ។

ដើម្បីឱ្យការគ្រប់គ្រង ក៏ដូចជាការផ្សព្វផ្សាយលទ្ធផលបឋមនៃការបោះឆ្នោតប្រព្រឹត្តទៅដោយរលូន ត្រឹមត្រូវ តម្លាភាព និងទាន់ពេលវេលា គ.ជ.ប បានបង្កើតគណៈកម្មការគ្រប់គ្រងលទ្ធផលបឋមនៃការបោះឆ្នោតដោយមានអនុគណៈកម្មការចំនួន ៣គឺ អនុគណៈកម្មការសម្របសម្រួល អនុគណៈកម្មការត្រួតពិនិត្យ និងផ្ទៀងផ្ទាត់ និងអនុគណៈកម្មការផ្សព្វផ្សាយ។ ដំណើរការផ្សព្វផ្សាយលទ្ធផលបឋមនៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី៥ ឆ្នាំ២០២២ ត្រូវបានកំណត់ និងរៀបចំក្នុងគោលបំណង ផ្តល់ជំនឿទុកចិត្តដល់ភាគីពាក់ព័ន្ធទៅលើលទ្ធផលនៃការបោះឆ្នោត ផ្សព្វផ្សាយលទ្ធផលបឋមបានឆាប់រហ័ស ត្រឹមត្រូវ ច្បាស់លាស់ ទូលំទូលាយ តម្លាភាព ពង្រឹងប្រសិទ្ធភាព និងពង្រីកវិសាលភាពប្រព័ន្ធបច្ចេកវិទ្យាក្នុងដំណើរការត្រួតពិនិត្យផ្ទៀងផ្ទាត់ និងបូកសរុបលទ្ធផលនៃការបោះឆ្នោត។

ដោយមានកិច្ចសហការជាមួយស្ថានីយទូរទស្សន៍ និងវិទ្យុជាតិកម្ពុជា (វិទ្យុ AM 918 $KH_Z$ វិទ្យុ FM 96 $MH_Z$ និងវិទ្យុវត្តភ្នំ FM 105.70 $MH_Z$) គ.ជ.ប បានរៀបចំកម្មវិធីផ្សព្វផ្សាយលទ្ធផលបឋមនៅវេលាល្ងាចថ្ងៃទី៥ ខែមិថុនា ឆ្នាំ២០២២ រហូតដល់ម៉ោង ១២:០០យប់ក្នុងថ្ងៃបោះឆ្នោតតាមការកំណត់របស់ គ.ជ.ប ដោយមានឃុំ សង្កាត់មួយចំនួនត្រូវបានផ្សព្វផ្សាយ។ ដោយឡែកលទ្ធផលបឋមនៃការបោះឆ្នោតនៅតាមឃុំ សង្កាត់ដែលបានបញ្ជូនមក គ.ជ.ប ក្រោយម៉ោង ១២:០០ អធ្រាត្រត្រូវបាន គ.ជ.ប ធ្វើការផ្សព្វផ្សាយបន្តនៅព្រឹកថ្ងៃ៦ ខែមិថុនា ឆ្នាំ២០២២ រហូតដល់ម៉ោង ១២:០០ថ្ងៃត្រង់។ ផ្អែកតាមលទ្ធផលបឋមបង្ហាញថា ក្នុងចំណោមគណបក្សនយោបាយចំនួន ១៧ មានគណបក្សនយោបាយចំនួន ៤ មានសំឡេងឆ្នោតគាំទ្រច្រើនជាងគេ គឺគណបក្សប្រជាជនកម្ពុជា គណបក្សភ្លើងទៀន គណបក្សហ៊្វុនស៊ិនប៉ិច និងគណបក្សខ្មែររួបរួមជាតិ រីឯគណបក្សផ្សេងទៀតទទួលបានសំឡេងឆ្នោតគាំទ្រតិចតួចបំផុត។

ការផ្សព្វផ្សាយលទ្ធផលបឋមនៃការបោះឆ្នោតនេះក៏ត្រូវបានធ្វើឡើងតាមគេហទំព័ររបស់ គ.ជ.ប ដែលមានអាសយដ្ឋាន electresult.nec.gov.kh កម្មវិធីទូរស័ព្ទដៃ App-NEC KH និង CamNEC News Facebook និង YouTube។

### ១០.៥. ការត្រួតពិនិត្យ និងការបូកសរុបលទ្ធផលបណ្តោះអាសន្ននៅ គឃ.សប

បន្ទាប់ពី គឃ.សប បានទទួលកញ្ចប់សម្ភារឯកសារពីគ្រប់ការិយាល័យបោះឆ្នោត តាំងពីល្ងាចថ្ងៃបោះឆ្នោត ក្នុងចំណោម ១,៦៥២ ឃុំ សង្កាត់ នៃរាជធានី ខេត្តទាំង២៥។ ប្រតិបត្តិការរបស់ គឃ.សប ក្នុងការត្រួតពិនិត្យបូកសរុបលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតក្នុងឃុំ សង្កាត់នីមួយៗ បានប្រព្រឹត្តទៅដោយរលូនតាម ប.ន.ឃ.ស និងគោលការណ៍ណែនាំ នៅចំពោះមុខភ្នាក់ងារគណបក្សនយោបាយ អ្នកសង្កេតការណ៍ និងអ្នកសារព័ត៌មាន ដែលមានវត្តមានជាក់ស្តែង ។ គឃ.សប បានត្រួតពិនិត្យបូកសរុបលទ្ធផលបណ្តោះអាសន្នតាមការិយាល័យបោះឆ្នោតនានាចំណុះឃុំ សង្កាត់បញ្ចូលគ្នាឱ្យទៅជាលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតក្នុងឃុំ សង្កាត់ តាមការកំណត់របស់ ច.ប.ឃ.ស ប.ន.ឃ.ស ដោយផ្អែកលើ ទ.១១០១ ទ១១០២ និង ទ.១១០៨ ដើម្បីស្រង់យកទិន្នន័យមកគណនារួចបំពេញតារាងបូកសរុបលទ្ធផលនៃការបោះឆ្នោតក្នុងឃុំ សង្កាត់ (ទ.១១០៩) និងកំណត់ហេតុបូកសរុបលទ្ធផលនៃការ

បោះឆ្នោតក្នុងឃុំ សង្កាត់ (ទ.១១០៣) ដោយបានដាក់បង្ហាញតំណាងគណបក្សនយោបាយ និងអង្គការមិនមែនរដ្ឋាភិបាល ដែលមានវត្តមានហើយជាទូទៅតំណាងគណបក្សនយោបាយបានចូលរួមចុះហត្ថលេខាជាសាក្សី។ ក្រោយពីបានអនុវត្ត នីតិវិធីរួចរាល់ហើយ គឃ.សប បានបិទផ្សាយ ទ.១១០៣ មួយច្បាប់ អមជាមួយកំណត់ហេតុនៃការបិទផ្សាយនេះ មួយច្បាប់ដោយមានបញ្ជាក់ពីពេលវេលា និងកាលបរិច្ឆេទនៃការបិទផ្សាយនៅមុខទីស្នាក់ការ។ បន្ទាប់មកបាន រៀបចំវេចខ្ចប់កញ្ចប់ " គ ពិសេស " និងស្បោង " គ " និងសម្ភារឯកសារបោះឆ្នោតផ្សេងៗទៀតដើម្បីបញ្ជូនទៅ គធ.ខប ដោយអញ្ជើញភ្នាក់ងារគណបក្សនយោបាយ អ្នកសង្កេតការណ៍ដែលមានវត្តមានឱ្យចូលរួមដំណើរផង។

### ១០.៦- ការត្រួតពិនិត្យ ផ្ទៀងផ្ទាត់លទ្ធផលនៃការបោះឆ្នោតក្នុងឃុំ សង្កាត់ ការបែងចែកអាសនៈ និងការស្រង់ឈ្មោះបេក្ខជនជាប់ឆ្នោតនៅ គធ.ខប

នៅតាមរាជធានី ខេត្ត គធ.ខប បានបង្កើតមជ្ឈមណ្ឌលមួយសម្រាប់ត្រួតពិនិត្យលទ្ធផល បណ្ដោះអាសន្ននៃការបោះឆ្នោតតាមឃុំ សង្កាត់ក្នុងរាជធានី ខេត្ត ការកំណត់បែងចែកអាសនៈដែលបញ្ជីបេក្ខជននៃ គណបក្សនយោបាយត្រូវទទួលបាន និងស្រង់ឈ្មោះបេក្ខជនជាប់ឆ្នោត។ ក្រុមត្រួតពិនិត្យលទ្ធផលនៃ គធ.ខប បានត្រួតពិនិត្យលទ្ធផលបណ្ដោះអាសន្ននៃការបោះឆ្នោតក្នុងឃុំ សង្កាត់ ដោយឡែកៗទៅតាមករណីមាន ឬគ្មានបណ្ដឹង មិនឱ្យហួសរយៈពេល ៥ថ្ងៃ បន្ទាប់ពីថ្ងៃទទួលបានស្បោង " គ ពិសេស " និងស្បោង " គ "។ ក្រុមត្រួតពិនិត្យលទ្ធផល នៃ គធ.ខប បានធ្វើការត្រួតពិនិត្យ និងផ្ទៀងផ្ទាត់លទ្ធផលបណ្ដោះអាសន្ននៃការបោះឆ្នោតក្នុងឃុំ សង្កាត់ ដោយផ្អែកលើ កំណត់ហេតុបូកសរុបលទ្ធផលបណ្ដោះអាសន្ននៃការបោះឆ្នោតក្នុងឃុំ សង្កាត់ (ទ.១១០៣) តារាងបូកសរុបលទ្ធផល បណ្ដោះអាសន្ននៃការបោះឆ្នោតក្នុងឃុំ សង្កាត់ (ទ.១១០៩) កំណត់ហេតុនៃការបោះឆ្នោត (ទ.១១០១) កំណត់ហេតុ នៃការរាប់សន្លឹកឆ្នោត (ទ.១១០២) និងតារាងកំណត់ត្រាសំឡេងឆ្នោត (ទ.១១០៨) និងទិន្នន័យដែល គឃ.សប បាន បញ្ជូនតាមប្រព័ន្ធអ៊ីនធឺណិត ឬទាំងហ្គាស់ (USD Drive) ដែលមានរក្សាទុកទិន្នន័យ ទ.១១០១ ទ.១១០២ ទ.១១០៨ ទ.១១០៣ និង ទ.១១០៩ ផងដែរ។ ប្រធានក្រុមត្រួតពិនិត្យលទ្ធផលត្រូវចាត់ចែងសមាជិកក្រុមត្រួតពិនិត្យ និង គណនាផ្ទៀងផ្ទាត់ និងបូកសរុបលទ្ធផលបណ្ដោះអាសន្ននៃការបោះឆ្នោតតាមប្រតិបត្តិការកម្មវិធីកុំព្យូទ័រដោយធៀប នឹង ទ.១១០៣ និង ទ.១១០៩ ក្នុងករណីមានភាពមិនច្បាស់លាស់ត្រូវផ្ទៀងផ្ទាត់បន្ថែមជាមួយ ទ.១១០១ ទ.១១០២ និង ទ.១១០៨។ ប្រសិនបើរកឃើញកំហុសឆ្គងក្នុងការគណនាត្រូវកែតម្រូវកំហុសព្រមទាំងហេតុផលនៃការកែតម្រូវ នេះចំពោះមុខភ្នាក់ងារគណបក្សនយោបាយ និងអ្នកសង្កេតការណ៍ បន្ទាប់មកធ្វើការស្កេន ទ.១១០៣ និង ទ.១១០៩ ដែលបានកែតម្រូវចូលក្នុងប្រព័ន្ធកុំព្យូទ័រ។ បន្ទាប់ពីបានត្រួតពិនិត្យ ឬកែតម្រូវរួច ត្រូវបោះពុម្ពតារាងត្រួតពិនិត្យលទ្ធផល នៃការបោះឆ្នោតក្នុងឃុំ សង្កាត់ (ទ.១១១៦គ៣) ចំនួន ២ច្បាប់ ចេញពីប្រព័ន្ធកម្មវិធីដោយ ទ.១១១៦គ៣ នេះត្រូវបញ្ជាក់ ខ្លឹមសារថាតួលេខ និងលទ្ធផលមានភាពត្រឹមត្រូវ ហើយសមាសភាពក្រុមត្រូវចុះហត្ថលេខាលើ ទ.១១១៦គ៣ បន្ទាប់មកដាក់ ទ.១១១៦គ៣ ភ្ជាប់ជាមួយ ទ.១១០៣ និង ទ.១១០៩ ដាក់ជូន គធ.ខប ពិនិត្យសម្រេចតាមរយៈប្រធាន អនុគណៈកម្មការបច្ចេកទេស។ ប្រសិនបើត្រឹមត្រូវហើយប្រធាន គធ.ខប ចារយល់ព្រម និងដាក់បង្ហាញជូនភ្នាក់ងារ គណបក្ស និងអ្នកសង្កេតការណ៍ ហើយត្រូវចាត់ចែងប្រគល់ជូនក្រុមត្រួតពិនិត្យ ១ច្បាប់ ដាក់ក្នុងកញ្ចប់ "គ ពិសេស" រក្សាទុកនៅ គធ.ខប និង ១ច្បាប់ទៀតជូនក្រុមបែងចែកអាសនៈ និងស្រង់ឈ្មោះបេក្ខជនជាប់ឆ្នោត។ ប្រធានក្រុម កំណត់បែងចែកអាសនៈ និងស្រង់ឈ្មោះបេក្ខជនត្រូវត្រួតពិនិត្យលើ ទ.១១១៦គ៣ និងរបាយការណ៍ពាក់ព័ន្ធដែល គធ.ខប ព្រមទទួលយកលទ្ធផលនៃការបោះឆ្នោត ដោយចាត់ចែងសមាជិកក្រុមឱ្យប្រតិបត្តិការផ្ទេរទិន្នន័យពី ទ.១១០៣ បញ្ចូល ក្នុង ទ.១១១០ និង ទ.១១០៥ធខ ដើម្បីបោះពុម្ព ដោយត្រូវពិនិត្យ ផ្ទៀងផ្ទាត់បន្ថែមរវាងតួលេខ ទ.១១០៥ធខ និង ទ.១១១០ ព្រមទាំងចុះហត្ថលេខាដោយសមាជិកក្រុមទាំងអស់ បន្ទាប់មកត្រូវបោះពុម្ពលទ្ធផលបណ្ដោះអាសន្ននៃការបោះឆ្នោត ក្រុមប្រឹក្សាឃុំ សង្កាត់ ទ.១១១១ ដោយមានបញ្ជាក់ពីចំនួនអាសនៈ និងឈ្មោះបេក្ខជនជាប់ឆ្នោត។ សមាជិកក្រុម

បច្ចេកទេសត្រូវដាក់ ទ.១១១០ ទ.១១០៥ធខ និង ទ.១១១១ ជូនប្រធាន គធ.ខប ចុះហត្ថលេខា។ លទ្ធផលនេះត្រូវដាក់បង្ហាញជូនភ្នាក់ងារគណបក្សនយោបាយ និងអ្នកសង្កេតការណ៍ និងអាចផ្ដល់ជូនជាច្បាប់ថតចម្លង ទ.១១១១ និង ទ.១១០៥ធខ តាមការស្នើសុំ ព្រមទាំងបិទផ្សាយផងដែរនៅ គធ.ខប នូវ ទ.១១០៥ធខ និង ទ.១១១១។ ជាមួយគ្នានោះដែរ គធ.ខប បានរក្សាទុក (Backup) ទិន្នន័យ ទ.១១០១ ទ.១១០២ ទ.១១០៨ ទ.១១០៣ ទ.១១០៩ ទ.១១១០ ទ.១១១៦តព ទ.១១០៥ធខ និង ទ.១១១១ ក្នុងហ្គាស់។ បន្ទាប់ពីបានអនុវត្តចប់សព្វគ្រប់លើការត្រួតពិនិត្យ និងបូកសរុបលទ្ធផលបណ្ដោះអាសន្ននៃការបោះឆ្នោត ការកំណត់ចំនួនអាសនៈដែលគណបក្សនយោបាយត្រូវទទួលបាន និងការស្រង់បេក្ខជនជាប់ឆ្នោតនៅតាមរាជធានី ខេត្ត គធ.ខប បានរៀបចំវេចខ្ចប់នូវរាល់សម្ភារ ឯកសារបោះឆ្នោតដាក់ក្នុងកញ្ចប់ “ឃ ពិសេស” និងស្បោង “ឃ” ដើម្បីប្រគល់ជូន គ.ជ.ប។

### ១០.៧-ការទទួលសម្ភារ ឯកសារ ការត្រួតពិនិត្យផ្ទៀងផ្ទាត់លទ្ធផលឡើងវិញ ការកំណត់បែងចែកអាសនៈនៅ គ.ជ.ប

ក្នុងគោលបំណងត្រួតពិនិត្យ និងផ្ទៀងផ្ទាត់ឡើងវិញនូវលទ្ធផលនៃការបោះឆ្នោត ក៏ដូចជាសម្ភារបរិក្ខារបម្រើឱ្យការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី៥ ឆ្នាំ២០២២ គ.ជ.ប បានបង្កើតក្រុមទទួលសម្ភារ ឯកសារបោះឆ្នោត ក្រុមត្រួតពិនិត្យលទ្ធផលឡើងវិញ និងក្រុមបែងចែកអាសនៈ ដើម្បីត្រៀមលក្ខណសម្បត្តិជាមុនបម្រើឱ្យការត្រួតពិនិត្យ និងផ្ទៀងផ្ទាត់។

#### ១០.៧.១- ការទទួលសម្ភារ ឯកសារបោះឆ្នោតពី គធ.ខប

ចាប់ពីថ្ងៃទី១០ ដល់ថ្ងៃទី ១៥ខែមិថុនា ឆ្នាំ២០២២ ក្រុមទទួលសម្ភារ ឯកសារនៃ គ.ជ.ប បានទទួលជាបណ្ដើរៗនូវកញ្ចប់ “ ឃ ពិសេស ” ដាក់សំណុំឯកសារលទ្ធផលបណ្ដោះអាសន្ននៃការបោះឆ្នោតជ្រើសរើស កបឃ.ស និងស្បោង “ឃ” ដាក់សម្ភារ ឯកសារពាក់ព័ន្ធដែលទទួលបានពី គធ.ខប។ ក្រុមត្រួតពិនិត្យសម្ភារ ឯកសារបានរាយការណ៍ជាប្រចាំជូន គ.ជ.ប តាមរយៈអគ្គលេខាធិការ គ.ជ.ប អំពីដំណើរការនៃការត្រួតពិនិត្យនេះ។

#### ១០.៧.២- ការត្រួតពិនិត្យលទ្ធផលឡើងវិញនៅ គ.ជ.ប

ការត្រួតពិនិត្យ និងផ្ទៀងផ្ទាត់ឡើងវិញធ្វើឡើងបន្ទាប់ពី គ.ជ.ប បានទទួលស្បោង “ឃ” និងកញ្ចប់ “ឃ ពិសេស” ព្រមទាំងឯកសារពាក់ព័ន្ធពី គធ.ខប ទាំង២៥។ ទាក់ទងនឹងការងារត្រួតពិនិត្យនេះ គ.ជ.ប បានបែងចែកការងារជា ៥ក្រុម ហើយការអនុវត្តនៃការត្រួតពិនិត្យត្រូវធ្វើឡើងដោយដៃផង និងតាមរយៈកុំព្យូទ័រផង ការផ្ទៀងផ្ទាត់តាមពីរជម្រើសនេះគឺជាការល្អបំផុត ដើម្បីធានាអំពីភាពត្រឹមត្រូវនូវលទ្ធផលបោះឆ្នោតជូនប្រជាពលរដ្ឋដែលជាម្ចាស់ឆ្នោតនឹងទទួលយកបានពីគ្រប់ភាគីពាក់ព័ន្ធ។ ក្រុមត្រួតពិនិត្យលទ្ធផលនៃ គ.ជ.ប បានត្រួតពិនិត្យ និងផ្ទៀងផ្ទាត់ឡើងវិញនូវលទ្ធផលនៃការបោះឆ្នោតក្នុងឃុំ សង្កាត់ទាំងអស់ ដើម្បីបញ្ជាក់ជាចុងក្រោយអំពីភាពត្រឹមត្រូវ ឬភាពមិនត្រឹមត្រូវក្នុងការបូកសរុបលទ្ធផលនៃការបោះឆ្នោតពីគ្រប់ឃុំ សង្កាត់ចំណុះរាជធានី ខេត្ត នៅចំពោះមុខតំណាងគណបក្សនយោបាយ អ្នកសង្កេតការណ៍ និងអ្នកសារព័ត៌មាន ។ ក្រុមត្រួតពិនិត្យលទ្ធផលបានត្រួតពិនិត្យ និងគណនាផ្ទៀងផ្ទាត់លទ្ធផលនៃការបោះឆ្នោតក្នុងរាជធានី ខេត្ត ដែលខ្លួនទទួលបន្ទុក ដោយផ្អែកលើ ទ.១១១០ ទ.១១០៥ធខ ទ.១១១១ និង ទ.១១១៦ត.ព ព្រមទាំង ទ.១១០៣ និង ទ.១១០៩ ដែល គធ.ខប បានបញ្ជូនមក។ គ្រប់សកម្មភាពនៃការបំពេញភារកិច្ចរបស់ក្រុមការងារខាងលើសុទ្ធតែមានវត្តមានតំណាងគណបក្សនយោបាយ និងអ្នកសង្កេតការណ៍ចូលរួមសង្កេតមើលយ៉ាងយកចិត្តទុកដាក់។

ជាលទ្ធផលក្រុមត្រួតពិនិត្យលទ្ធផលឡើងវិញមិនបានរកឃើញកំហុស និងភាពមិនប្រក្រតីណាមួយពាក់ព័ន្ធនឹងការគណនាតួលេខលទ្ធផលសំឡេងឆ្នោតគាំទ្រគណបក្សនយោបាយនីមួយៗដែល គធ.ខប បានបញ្ជាក់ក្នុងក្រដាសលទ្ធផលបណ្ដោះអាសន្ននៃការបោះឆ្នោតក្នុងឃុំ សង្កាត់ ទ.១១០៥ធខ តារាងលទ្ធផលនៃការបោះឆ្នោតតាមឃុំ

សង្កាត់ក្នុងរាជធានី ខេត្ត ទ.១១១០ និងលទ្ធផលបណ្ដោះអាសន្ននៃការបោះឆ្នោត ទ.១១១១ ឡើយ ហើយភាគីដែលចូលរួមជាសាក្សីទាំងអស់បានឯកភាព និងពុំមានការតវ៉ា ឬជំទាស់នោះទេ។

ក្រុមត្រួតពិនិត្យលទ្ធផលបានសរសេររបាយការណ៍ដោយដៃ និងបំពេញតារាងត្រួតពិនិត្យលទ្ធផលនៃការបោះឆ្នោតក្នុងឃុំ សង្កាត់ (ទ.១១១៧គព) ដាក់ជូន គ.ជ.ប តាមរយៈអគ្គលេខាធិការ ដើម្បីពិនិត្យសម្រេច។ ផ្អែកតាម ទ.១១១៧គព ដែល គ.ជ.ប បានចារយល់ព្រម ហើយសំណុំឯកសារ និងលទ្ធផលដែលបានសម្រេចនេះ គ.ជ.ប បានបញ្ជូនទៅក្រុមបែងចែកអាសនៈដើម្បីអនុវត្តបន្ត។

### ១០.៧.៣- ការកំណត់បែងចែកអាសនៈនៅ គ.ជ.ប

បន្ទាប់ពីទទួលបានលទ្ធផលផ្លូវការពីក្រុមត្រួតពិនិត្យលទ្ធផលឡើងវិញ ក្រុមបែងចែកអាសនៈបានធ្វើការត្រួតពិនិត្យលទ្ធផលនៃការបោះឆ្នោតទូទាំងប្រទេស ដោយបានអនុវត្តការផ្ទៀងផ្ទាត់ការបែងចែកអាសនៈតាមឃុំ សង្កាត់រួចធ្វើការផ្ទៀងផ្ទាត់លទ្ធផលជាមួយនឹងលទ្ធផលបណ្ដោះអាន្ននៃការបោះឆ្នោតក្នុងឃុំ សង្កាត់ (ទ.១១១១) បន្ទាប់មកក្រុមបែងចែកអាសនៈបានបោះពុម្ពតារាងលទ្ធផលនៃការបោះឆ្នោតតាមឃុំ សង្កាត់ក្នុងរាជធានី ខេត្ត ដោយផ្អែកតាមតារាងបូកសរុបលទ្ធផលបណ្ដោះអាសន្ននៃការបោះឆ្នោតតាមឃុំ សង្កាត់ក្នុងរាជធានី ខេត្ត ទ.១១១០ ទ.១១០៥ធខ ដែល គធ.ខប បញ្ជូនមក គ.ជ.ប តាមរយៈ (Server) ហើយត្រូវផ្ទៀងផ្ទាត់លទ្ធផលនៃការបោះឆ្នោតតាមឃុំ សង្កាត់ទៅនឹងក្រដាសលទ្ធផលបណ្ដោះអាសន្ននៃការបោះឆ្នោតតាមឃុំ សង្កាត់ផ្ទៀងផ្ទាត់ដោយ គធ.ខប ទ.១១០៥ធខ និងតារាងត្រួតពិនិត្យលទ្ធផលនៃការបោះឆ្នោតក្នុងឃុំ សង្កាត់ ទ.១១១៧គព របស់ក្រុមត្រួតពិនិត្យលទ្ធផលដែល គ.ជ.ប បានសម្រេចរួចហើយ។ ការងារប្រតិបត្តិការនៃការបែងចែកអាសនៈនេះត្រូវអនុវត្តតាមរូបមន្តដែលកំណត់ដោយច្បាប់ដោយគណនាតាមការធ្វើប្រមាណវិធីដោយដៃ និងដោយប្រើកម្មវិធីក្នុងប្រព័ន្ធកុំព្យូទ័រដោយយោងទៅតាមតារាងលទ្ធផលផ្លូវការនៃការបោះឆ្នោតតាមឃុំ សង្កាត់ទូទាំងប្រទេស។ បន្ទាប់ពីពិនិត្យ និងផ្ទៀងផ្ទាត់ឃើញថាត្រឹមត្រូវហើយក្រុមបែងបែងចែកអាសនៈ បានបោះពុម្ពសេចក្ដីព្រាងសេចក្ដីប្រកាសលទ្ធផលនៃការបោះឆ្នោត តារាងលទ្ធផលនៃការផ្ទៀងផ្ទាត់ ការបែងចែកអាសនៈ សម្រាប់បញ្ជីបេក្ខជននៃគណបក្សនយោបាយឈរឈ្មោះបោះឆ្នោតនិងបេក្ខជនជាប់ឆ្នោតជាសមាជិក កបឃ.ស និងជាមេឃុំ ចៅសង្កាត់ ឬជំទប់ ឬចៅសង្កាត់រង ហើយបានដាក់ជូន គ.ជ.ប តាមរយៈអគ្គលេខាធិការ គ.ជ.ប ពិនិត្យសម្រេច និងផ្សព្វផ្សាយជាផ្លូវការ។

## ១០.៨- របាយការណ៍ស្ដីពីការផ្ទៀងផ្ទាត់ និងការប្រើប្រាស់សន្លឹកឆ្នោត

ផ្អែកតាមការបូកសរុប និងការធ្វើតុល្យការលើចំនួនសន្លឹកឆ្នោតដែល គ.ក.ប ទាំង ២៣,៦០២ បានទទួលជាក់ស្ដែង និងចំនួនសន្លឹកឆ្នោតដែលបានប្រើប្រាស់ ដោយយោងតាមតារាងបូកសរុប និងកំណត់ហេតុពីគណៈកម្មការរៀបចំការបោះឆ្នោតគ្រប់លំដាប់ថ្នាក់ (ទ.១១០១ ទ.១១០៨ ទ.១១០២ ទ.១១០៩ ទ.១១០៣ ទ.១១១០ និងទ.១១០៥ធខ) គ.ជ.ប បានត្រួតពិនិត្យ បូកសរុប និងរកឃើញតួលេខពាក់ព័ន្ធនឹងចំនួនសន្លឹកឆ្នោតមានដូចខាងក្រោម ៖

- សន្លឹកឆ្នោតទទួលជាក់ស្ដែងសរុប ចំនួន ១១,៦១០,៤៩២សន្លឹក
- សន្លឹកឆ្នោតក្នុងហិប ចំនួន ៧,៣៩៤,៤២៧សន្លឹក
- សន្លឹកឆ្នោតបានការសរុប ចំនួន ៧,២៣៧,០៣៧សន្លឹក
- សន្លឹកឆ្នោតមិនបានការសរុប ចំនួន ១៥៧,៣៩០សន្លឹក
- សន្លឹកឆ្នោតខូចសរុប ចំនួន ១៣,២២៧សន្លឹក
- សន្លឹកឆ្នោតមិនបានប្រើសរុប ចំនួន ៤,២០២,៨៣៨សន្លឹក។

## ១០.៩- លទ្ធផលផ្លូវការនៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី៥ ឆ្នាំ២០២២

តាមប្រតិទិនកំណត់ នៅថ្ងៃទី២៦ ខែមិថុនា ឆ្នាំ២០២២ គ.ជ.ប បានប្រកាសផ្សាយលទ្ធផលផ្លូវការនៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី៥ ឆ្នាំ២០២២ នៅទូទាំង ២៥រាជធានី ខេត្ត។ ក្នុងចំណោមគណបក្សនយោបាយចំនួន ១៧ មានគណបក្សនយោបាយចំនួន ៩ ទទួលបានអាសនៈ ក្នុងនោះមាន ៖

- គណបក្សប្រជាជនកម្ពុជា ទទួលបាន ៩,៣៧៦អាសនៈ
- គណបក្សភ្លើងទៀន ទទួលបាន ២,១៩៨អាសនៈ
- គណបក្សហ្វ៊ុនស៊ិនប៉ិច ទទួលបាន ១៩អាសនៈ
- គណបក្សខ្មែររួបរួមជាតិ ទទួលបាន ១៣អាសនៈ
- គណបក្សប្រជាធិបតេយ្យមូលដ្ឋាន ទទួលបាន ៦អាសនៈ
- គណបក្សខ្មែរស្រឡាញ់ជាតិ ទទួលបាន ៥អាសនៈ
- គណបក្សយុវជនកម្ពុជា ទទួលបាន ៣អាសនៈ
- គណបក្សកម្ពុជានិយម ទទួលបាន ១អាសនៈ
- គណបក្សសំបុកឃ្មុំសង្គមប្រជាធិបតេយ្យ ទទួលបាន ១អាសនៈ។

ចំណែកឯគណបក្សផ្សេងៗទៀតពុំទទួលបានអាសនៈឡើយ (ឧបសម្ព័ន្ធទី១៥)។

## ១០.១០- ការផ្សព្វផ្សាយលទ្ធផលផ្លូវការ

គ.ជ.ប បានធ្វើការផ្សព្វផ្សាយលទ្ធផលផ្លូវការនៃការបោះឆ្នោតតាមរយៈស្ថានីយទូរទស្សន៍ និងវិទ្យុជាតិកម្ពុជា (វិទ្យុ AM ៩១៨ $KH_Z$ វិទ្យុ FM 96 $MH_Z$ និងវិទ្យុវត្តភ្នំ FM 105.70 $MH_Z$) ទីភ្នាក់ងារសារព័ត៌មាន AKP គេហទំព័រ គ.ជ.ប www.nec.gov.kh និង electresult.nec.kh កម្មវិធីទូរស័ព្ទដៃ NEC KH និង CamNec News Facebook National Election Committee និង YouTube National Election Committee ផងដែរ។

យោងបទបញ្ញា និងនីតិវិធីនៃការបោះឆ្នោត លទ្ធផលផ្លូវការសម្រាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី៥ ឆ្នាំ២០២២ គ.ជ.ប បានផ្ញើជូន ៖

- រាជរដ្ឋាភិបាល ចំនួន ១ច្បាប់
- ក្រសួងមហាផ្ទៃ ចំនួន ១ច្បាប់
- គធ.ខប ទាំង២៥ ចំនួន ១ច្បាប់
- បណ្ណសារដ្ឋានជាតិ ចំនួន ១ច្បាប់
- គណបក្សនយោបាយឈរឈ្មោះបោះឆ្នោត ចំនួន ១ច្បាប់
- រក្សាទុកជាឯកសារនៅ គ.ជ.ប ចំនួន ១ច្បាប់។

# ១១- ការដាក់ ការទទួល និងការដោះស្រាយពាក្យបណ្ដឹង

ការដាក់ ការទទួល និងការដោះស្រាយពាក្យបណ្ដឹងពាក់ព័ន្ធនឹងការបោះឆ្នោត ត្រូវបានអនុវត្តតាម ច.ប.ឃ.ស និង ប.ន.ឃ.ស ស្របតាមដំណាក់កាលនីមួយៗ ដូចខាងក្រោម ៖

## ១១.១- ដំណាក់កាលចុះបញ្ជីបេក្ខជននៃគណបក្សនយោបាយ

ដំណាក់កាលចុះបញ្ជីបេក្ខជននៃគណបក្សនយោបាយឈរឈ្មោះបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំសង្កាត់ អាណត្តិទី៥ ឆ្នាំ២០២២ គឃ.សប គធ.ខប និង គ.ជ.ប បានទទួលពាក្យបណ្ដឹងសរុបចំនួន **៣២៩**បណ្ដឹង ក្នុងចំណោមពាក្យបណ្ដឹងទាំង **៣២៩** នោះ មាន ៖

- ១៤៨បណ្ដឹង ត្រូវបានប្ដឹងទៅ គឃ.សប (ករណីប្ដឹងសុំបដិសេធមិនឈរឈ្មោះជាបេក្ខជនក្នុងដំណាក់កាលបិទផ្សាយឱ្យប្រជាពលរដ្ឋផ្ដល់មតិ ១៤៤បណ្ដឹង និងករណីសុំឱ្យផ្ដន្ទាទោស ៤បណ្ដឹង)
- ៤៤បណ្ដឹង ប្ដឹងផ្ទាល់ទៅ គធ.ខប (ករណីប្ដឹងសមាសភាព គឃ.សប ៨បណ្ដឹង ករណីប្ដឹងតវ៉ាការបដិសេធការសុំចុះបញ្ជីបេក្ខជននៃគណបក្សនយោបាយ ៣៥បណ្ដឹង និងករណីស្នើសុំចាប់ឆ្នោតកំណត់លំដាប់លេខរៀងរបស់គណបក្សនយោបាយចំនួន ១បណ្ដឹង)
- នៅ គ.ជ.ប បានទទួលពាក្យបណ្ដឹងសរុបចំនួន ១៤៧បណ្ដឹង មាន៖
  - ៩បណ្ដឹង ករណីប្ដឹងតវ៉ាការបដិសេធសុំចុះបញ្ជីបេក្ខជននៃគណបក្សនយោបាយ
  - ១២បណ្ដឹង ករណីប្ដឹងជំទាស់សុំលុបបញ្ជីបេក្ខជនដំបូងនៃគណបក្សនយោបាយ
  - ១៨បណ្ដឹង ករណីប្ដឹងជំទាស់បេក្ខជននៃគណបក្សនយោបាយមិនបានបំពេញគ្រប់លក្ខខណ្ឌ
  - ១០៧បណ្ដឹង ករណីប្ដឹងសុំដកបេក្ខជនភាពចេញពីគណបក្សនយោបាយ
  - ១បណ្ដឹង ករណីប្ដឹងបន្តពី គធ.ខប ប្ដឹងសុំឱ្យផ្ដន្ទាទោស។

ជារួមពាក្យបណ្ដឹងទាំងអស់ត្រូវបានដោះស្រាយ ដូចខាងក្រោម ៖

### ក- ការដាក់ ការទទួល និងការដោះស្រាយពាក្យបណ្ដឹងនៅ គឃ.សប

គឃ.សប បានទទួលពាក្យបណ្ដឹងសរុបចំនួន **១៤៨**បណ្ដឹង (ករណីប្ដឹងតវ៉ាបដិសេធមិនឈរឈ្មោះជាបេក្ខជន **១៤៤**បណ្ដឹង និងករណីប្ដឹងសុំឱ្យផ្ដន្ទាទោស **៤**បណ្ដឹង)។ ក្នុងនោះមាន ប្រជាពលរដ្ឋ **១៤៤**បណ្ដឹង និងមន្ត្រីគណបក្សភ្លើងទៀន **៤**បណ្ដឹង នៃខេត្តចំនួន ៣ (ខេត្តកំពត ខេត្តព្រះវិហារ និងខេត្តប៉ៃលិន)។ ជារួមពាក្យបណ្ដឹងទាំង **១៤៨** នេះ ត្រូវបាន គឃ.សប សម្រេច ដូចខាងក្រោម ៖

- លិខិតជូនដំណឹងបដិសេធ ចំនួន ១៤៦បណ្ដឹង
- ផ្សះផ្សាសះជា ចំនួន ១បណ្ដឹង
- ចារបដិសេធ ចំនួន ១បណ្ដឹង។

### ខ- ការដាក់ ការទទួល និងការដោះស្រាយពាក្យបណ្ដឹងនៅ គធ.ខប

គធ.ខប បានទទួលពាក្យបណ្ដឹងសរុបចំនួន **៤៤**បណ្ដឹង ប្ដឹងផ្ទាល់ទៅ គធ.ខប (ករណីបដិសេធការសុំចុះបញ្ជីបេក្ខជនចំនួន **៣៥**បណ្ដឹង **៨**បណ្ដឹង ករណីសុំឱ្យផ្ដន្ទាទោសសមាសភាព គឃ.សប និងករណីស្នើសុំចាប់លំដាប់លេខរៀងគណបក្សនយោបាយឡើងវិញ **១**បណ្ដឹង)។ ក្នុងនោះមាន គណបក្សភ្លើងទៀនចំនួន **២១**បណ្ដឹង មន្ត្រីគណបក្សភ្លើងទៀនចំនួន **៣**បណ្ដឹង គណបក្សហ៊្វុនស៊ិនប៉ិចចំនួន **៧**បណ្ដឹង គណបក្សខ្មែររួបរួមជាតិចំនួន **៤**បណ្ដឹង គណបក្សខ្មែរស្រឡាញ់ជាតិចំនួន **៨**បណ្ដឹង និងគណបក្សប្រជាធិបតេយ្យមូលដ្ឋានចំនួន **១**បណ្ដឹង។ ជារួមពាក្យបណ្ដឹងទាំង **៤៤** នេះ ត្រូវបាន គធ.ខប សម្រេច ដូចខាងក្រោម ៖

- យល់ព្រមតាមពាក្យបណ្ដឹង ចំនួន ១៧បណ្ដឹង
- បដិសេធពាក្យបណ្ដឹង ចំនួន ១៧បណ្ដឹង
- ចារបដិសេធ ចំនួន ៦បណ្ដឹង
- លិខិតជូនដំណឹងបដិសេធ ចំនួន ៣បណ្ដឹង
- ដើមបណ្ដឹងសុំដកពាក្យបណ្ដឹង ចំនួន ១បណ្ដឹង។

### គ- ការដាក់ ការទទួល និងការដោះស្រាយពាក្យបណ្តឹងនៅ គ.ជ.ប

គ.ជ.ប បានទទួលពាក្យបណ្តឹងសរុបចំនួន **១៤៧**បណ្តឹង (ករណីប្តឹងជំទាស់បញ្ជីបេក្ខជនដំបូងមិនគ្រប់លក្ខខណ្ឌចំនួន **៣០**បណ្តឹង ករណីប្តឹងបញ្ជីបេក្ខជនដំបូងសុំដកបេក្ខភាពចំនួន **១០៧**បណ្តឹង ករណីបដិសេធការសុំចុះបញ្ជីបេក្ខជនចំនួន **៩**បណ្តឹង និង **១**បណ្តឹង ជាបណ្តឹងសុំឱ្យផ្តន្ទាទោស) ។ ក្នុងនោះមានប្រជាពលរដ្ឋចំនួន **១៣៧**បណ្តឹង តំណាងគណបក្សភ្លើងទៀន **៩**បណ្តឹង និងមន្ត្រីគណបក្សភ្លើងទៀនចំនួន **១**បណ្តឹង។ ជារួមពាក្យបណ្តឹងទាំង **១៤៧** នេះ ត្រូវបាន គ.ជ.ប សម្រេច ដូចខាងក្រោម ៖

- យល់ព្រមមួយផ្នែក និងសម្រេចបដិសេធមួយផ្នែក ចំនួន ១បណ្តឹង
- យល់ព្រមតាមពាក្យបណ្តឹង ចំនួន ១១៧បណ្តឹង
- បដិសេធពាក្យបណ្តឹង ចំនួន ១០បណ្តឹង
- ចារបដិសេធ ចំនួន ៤បណ្តឹង
- លិខិតជូនដំណឹង ចំនួន ១៥បណ្តឹង។

ជាលទ្ធផល ក្រុមប្រឹក្សាជុំនុំជម្រះនៃ គ.ជ.ប បានសម្រេចលុបបេក្ខជនចំនួន **៩៧**រូប ចេញពីបញ្ជីបេក្ខជននៃគណបក្សនយោបាយចំនួន **៣** លុបបញ្ជីបេក្ខជនគណបក្សនយោបាយចំនួន **៧** នៃគណបក្សនយោបាយចំនួន **៣** និងបដិសេធការសុំចុះបញ្ជីគណបក្សនយោបាយចំនួន **៦** នៃគណបក្សនយោបាយចំនួន **១** ដូចខាងក្រោម ៖

- ករណីលុបបេក្ខជន ចំនួន ៩៧រូប ចេញពីបញ្ជីបេក្ខជននៃគណបក្សនយោបាយចំនួន ៣គឺ៖
  - គណបក្សភ្លើងទៀន ចំនួន ៦៨រូប
  - គណបក្សឆន្ទៈខ្មែរ ចំនួន ១៩រូប
  - គណបក្សខ្មែររួបរួមជាតិ ចំនួន ១០រូប។
- ករណីលុបបញ្ជីបេក្ខជននៃគណបក្សនយោបាយ ចំនួន ៧ បញ្ជីនៃគណបក្សនយោបាយ ចំនួន ៣គឺ ៖
  - គណបក្សភ្លើងទៀន ចំនួន ៥បញ្ជី
  - គណបក្សឆន្ទៈខ្មែរ ចំនួន ១បញ្ជី
  - គណបក្សសំបុកឃ្មុំសង្គមប្រជាធិបតេយ្យ ចំនួន ១បញ្ជី។
- ករណីបដិសេធការសុំចុះបញ្ជីនៃគណបក្សនយោបាយចំនួន ៦បញ្ជី នៃគណបក្សនយោបាយរបស់គណបក្សភ្លើងទៀន។

## ១១.២- ដំណាក់កាលឃោសនាបោះឆ្នោត

ដំណាក់កាលឃោសនាបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី៥ ឆ្នាំ២០២២ គឃ.សប បានទទួលពាក្យបណ្តឹងសរុបចំនួន **៥៣**បណ្តឹង (ករណីសុំឱ្យផ្តន្ទាទោស)។ ក្នុងចំណោមពាក្យបណ្តឹងទាំង **៥៣** នោះ មាន **២២**បណ្តឹង បានប្តឹងបន្តទៅ គធ.ខប និង **១៥**បណ្តឹង បន្តប្តឹងមក គ.ជ.ប។ ជារួមពាក្យបណ្តឹងទាំងអស់ត្រូវបានដោះស្រាយដូចខាងក្រោម ៖

### ក- ការដាក់ ការទទួល និងការដោះស្រាយពាក្យបណ្តឹងនៅ គឃ.សប

គឃ.សប បានទទួលពាក្យបណ្តឹងសរុបចំនួន **៥៣**បណ្តឹង (ករណីប្តឹងសុំឱ្យផ្តន្ទាទោស **៥៣** បណ្តឹង) ក្នុងនោះមាន គណបក្សប្រជាជនកម្ពុជា **៣៥**បណ្តឹង គណបក្សភ្លើងទៀន **៧**បណ្តឹង គណបក្សហ៊្វុនស៊ិនប៉ិច **១**បណ្តឹង អាជ្ញាធរ **៤**បណ្តឹង និងប្រជាពលរដ្ឋ **៦**បណ្តឹង។ ជារួមពាក្យបណ្តឹងទាំង **៥៣** នេះ ត្រូវបាន គឃ.សប សម្រេច ៖

- ធ្វើលិខិតជូនដំណឹង ចំនួន ៨បណ្តឹង

- ផ្សះផ្សាសះជា ចំនួន ១៧បណ្តឹង
- ផ្សះផ្សាមិនសះជា ចំនួន ២៤បណ្តឹង
- ដើមបណ្តឹងសុំដកពាក្យបណ្តឹង ចំនួន ៣បណ្តឹង
- ចារបដិសេធ ចំនួន ១បណ្តឹង។

### ខ- ការដាក់ ការទទួល និងការដោះស្រាយពាក្យបណ្តឹងនៅ គធ.ខប

គធ.ខប បានទទួលពាក្យបណ្តឹងសរុបចំនួន ២២បណ្តឹង (ករណីប្តឹងសុំឱ្យផ្តន្ទាទោស) ក្នុងនោះមានគណបក្សប្រជាជនកម្ពុជា **១៣**បណ្តឹង គណបក្សភ្លើងទៀន **២**បណ្តឹង ប្រជាពលរដ្ឋ **១**បណ្តឹង និងមេធាវីតំណាង **៦**បណ្តឹង។ ជារួមពាក្យបណ្តឹងទាំង **២២** នេះ ត្រូវបាន គធ.ខប សម្រេច ៖

- ផាកពិន័យ ៥លានរៀល ចំនួន ២បណ្តឹង
- ព្រមាន ចំនួន ១បណ្តឹង
- ក្រើនរំលឹក ចំនួន ១១បណ្តឹង
- ធ្វើលិខិតជូនដំណឹង ចំនួន ៦បណ្តឹង
- ផ្សះផ្សាសះជា ចំនួន ២បណ្តឹង។

### គ- ការដាក់ ការទទួល និងការដោះស្រាយពាក្យបណ្តឹងនៅ គ.ជ.ប

គ.ជ.ប បានទទួលពាក្យបណ្តឹងសរុបចំនួន **១៥**បណ្តឹង (ករណីប្តឹងសុំឱ្យផ្តន្ទាទោស) ក្នុងនោះមានគណបក្សប្រជាជនកម្ពុជា **៦**បណ្តឹង គណបក្សភ្លើងទៀន **២** បណ្តឹង ប្រជាពលរដ្ឋ **១**បណ្តឹង និងមេធាវីតំណាង **៦**បណ្តឹង។ ជារួមពាក្យបណ្តឹងទាំង **១៥** នេះ ត្រូវបាន គ.ជ.ប សម្រេច ៖

- លុបចោលការផាកពិន័យ ចំនួន ២បណ្តឹង
- តម្កល់សេចក្តីសម្រេច ចំនួន ១បណ្តឹង
- ដើមបណ្តឹងសុំដកពាក្យបណ្តឹង ចំនួន ១បណ្តឹង
- ធ្វើលិខិតជូនដំណឹង ចំនួន ១១បណ្តឹង។

## ១១.៣-ដំណាក់កាលមួយថ្ងៃមុនថ្ងៃបោះឆ្នោត និងក្នុងថ្ងៃបោះឆ្នោត រាប់សន្លឹកឆ្នោត និងបិទផ្សាយលទ្ធផលបណ្តោះអាសន្ន

### ក- ពាក្យបណ្តឹងមួយថ្ងៃមុនថ្ងៃបោះឆ្នោត ក្នុងថ្ងៃបោះឆ្នោត និងរាប់សន្លឹកឆ្នោត

ក្នុងដំណាក់កាលមួយថ្ងៃមុនថ្ងៃបោះឆ្នោត និងក្នុងថ្ងៃបោះឆ្នោត និងរាប់សន្លឹកឆ្នោត បានទទួលពាក្យបណ្តឹងសរុបចំនួន **១៤២**បណ្តឹង។ ក្នុងចំណោមពាក្យបណ្តឹងទាំង **១៤២**បណ្តឹងនេះ នៅ គឃ.សប បានទទួលពាក្យបណ្តឹងសរុបចំនួន **៨៥**បណ្តឹង (ករណីសុំឱ្យផ្តន្ទាទោស **៥៣**បណ្តឹង និងករណីបណ្តឹងទាក់ទងនឹងភាពមិនប្រក្រតី **៣២**បណ្តឹង) នៅ គធ.ខប បានទទួលពាក្យបណ្តឹងសរុបចំនួន ៨៨បណ្តឹង (ប្តឹងផ្ទាល់ **៥៦**បណ្តឹង និងបន្តប្តឹងពី គឃ.សប **៣២**បណ្តឹង) និងនៅ គ.ជ.ប បានទទួលពាក្យបណ្តឹងសរុបចំនួន **១៨**បណ្តឹង ( ប្តឹងផ្ទាល់ **១**បណ្តឹង និងបន្តប្តឹងពី គធ.ខប **១៧**បណ្តឹង)។ ជារួមពាក្យបណ្តឹងទាំងអស់ត្រូវបានដោះស្រាយដូចខាងក្រោម ៖

#### ក.១- ការដាក់ ការទទួល និងការដោះស្រាយពាក្យបណ្តឹងនៅ គឃ.សប

នៅ គឃ.សប បានទទួលពាក្យបណ្តឹងសរុបចំនួន **៨៥**បណ្តឹង (ករណីសុំឱ្យផ្តន្ទាទោស **៥៣**បណ្តឹង និងករណីបណ្តឹងទាក់ទងនឹងភាពមិនប្រក្រតី **៣២**បណ្តឹង) ក្នុងនោះមាន គណបក្សប្រជាជនកម្ពុជា **៩**បណ្តឹង គណបក្សភ្លើងទៀន **៧០**បណ្តឹង គណបក្សប្រជាធិបតេយ្យមូលដ្ឋាន **៥**បណ្តឹង និងអនុភូមិ **១**បណ្តឹង។ ជារួមពាក្យបណ្តឹងទាំង **៨៥** ត្រូវបាន គឃ.សប សម្រេច ៖

- ផ្សះផ្សាសះជា ចំនួន ១៧បណ្តឹង

- ផ្សះផ្សាមិនសះជា ចំនួន ១៩បណ្តឹង
- ដើមបណ្តឹងសុំដកពាក្យបណ្តឹង ចំនួន ១៦បណ្តឹង
- ច្រានចោល ចំនួន ៥បណ្តឹង
- លើកបណ្តឹងចោល ចំនួន ២បណ្តឹង
- លិខិតជូនដំណឹង ចំនួន ២៦បណ្តឹង។

**ក.២- ការដាក់ ការទទួល និងការដោះស្រាយពាក្យបណ្តឹងនៅ គធ.ខប**

នៅ គធ.ខប បានទទួលពាក្យបណ្តឹងសរុបចំនួន ៨៨បណ្តឹង (ករណីប្តឹងផ្ទាល់ **៥៦**បណ្តឹង និងបន្តប្តឹងពី គឃ.សប **៣២**បណ្តឹង) ក្នុងនោះមាន គណបក្សប្រជាជនកម្ពុជា **១**បណ្តឹង, គណបក្សភ្លើងទៀន **៨៤**បណ្តឹង គណបក្សប្រជាធិបតេយ្យមូលដ្ឋាន **៣**បណ្តឹង។ ជារួមពាក្យបណ្តឹងទាំង **៨៨** ត្រូវបាន គធ.ខប សម្រេច ៖

- លិខិតជូនដំណឹង ចំនួន ៤៩បណ្តឹង
- ច្រានចោល ចំនួន ៣៨បណ្តឹង
- លិខិតជូនដំណឹង និងក្រើនរំលឹក ចំនួន ១បណ្តឹង។

**ក.៣- ការដាក់ ការទទួល និងការដោះស្រាយពាក្យបណ្តឹងនៅ គ.ជ.ប**

នៅ គ.ជ.ប បានទទួលពាក្យបណ្តឹងសរុបចំនួន **១៨**បណ្តឹង (ករណីសុំឱ្យផ្តន្ទាទោស **១៨**) ក្នុងនោះមានគណបក្សប្រជាជនកម្ពុជា **១**បណ្តឹង គណបក្សភ្លើងទៀន **១៦**បណ្តឹង គណបក្សប្រជាធិបតេយ្យមូលដ្ឋាន **១**បណ្តឹង។ ជារួមពាក្យបណ្តឹងទាំង **១៨** ត្រូវបាន គ.ជ.ប សម្រេចធ្វើលិខិតជូនដំណឹង។

**ខ- ពាក្យបណ្តឹងតវ៉ានឹងការបិទផ្សាយលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោត**

ក្នុងដំណាក់កាលបិទផ្សាយលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោត គធ.ខប បានទទួលពាក្យបណ្តឹងសរុបចំនួន **៥០**បណ្តឹង (គណបក្សភ្លើងទៀន)។ ជារួមពាក្យបណ្តឹងទាំង **៥០** ត្រូវបាន គធ.ខប សម្រេចធ្វើលិខិតជូនដំណឹង។

ក្នុងដំណាក់កាលនេះ ពុំមានបណ្តឹងតវ៉ា និងជំទាស់បន្តមក គ.ជ.ប ទេ។

## V- ការធានាសន្តិសុខ សណ្តាប់ធ្នាប់

ក្នុងគោលបំណងធានាឱ្យដំណើរការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី៥ ឆ្នាំ២០២២ ប្រព្រឹត្តទៅដោយសេរី ត្រឹមត្រូវ និងយុត្តិធម៌ ប្រកបដោយសន្តិសុខ សុវត្ថិភាព បរិយាកាសល្អប្រសើរ និងគ្មានការគំរាមកំហែង ការបំភិតបំភ័យ និងអំពើហិង្សា គ.ជ.ប បានស្នើសុំការអនុញ្ញាតគោលការណ៍ពីរាជរដ្ឋាភិបាល ដើម្បីឱ្យក្រសួងមហាផ្ទៃ ក្រសួងការពារជាតិ និង គ.ជ.ប បានចេញនូវផែនការអន្តរស្ថាប័នលេខ ០១០ ផ.ក ចុះថ្ងៃទី២៥ ខែតុលា ឆ្នាំ២០២១ ស្តីពីកិច្ចការពារការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោតប្រចាំឆ្នាំ និងការបោះឆ្នោតថ្នាក់ជាតិ-ថ្នាក់ក្រោមជាតិ ចាប់ពីឆ្នាំ២០២២ ដល់ឆ្នាំ២០២៤។

រាជរដ្ឋាភិបាលកម្ពុជាបានសម្រេចបង្កើត គណៈបញ្ជាការសន្តិសុខអចិន្ត្រៃយ៍សម្រាប់ការបោះឆ្នោត (គ.ស.អ) ជាក្បាលម៉ាស៊ីនដឹកនាំយន្តការថ្នាក់ជាតិការពារសន្តិសុខបោះឆ្នោត និងបានបង្កើតលេខាធិការដ្ឋាននៃ គ.ស.អ ដើម្បីធ្វើជាសេនាធិការតាមដាន ត្រួតពិនិត្យ និងស្នើសុំវិធានការផ្សេងៗ ព្រមទាំងរៀបចំកម្លាំងក្នុងការការពារសន្តិសុខសណ្តាប់ធ្នាប់សម្រាប់ការរៀបចំការបោះឆ្នោត។ ចំណែករចនាសម្ព័ន្ធសន្តិសុខបោះឆ្នោតថ្នាក់ក្រោមជាតិ បានកំណត់យកគណៈបញ្ជាការឯកភាពរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ជាអ្នកទទួលខុសត្រូវរៀបចំការងារការពារដោយផ្ទាល់នៅតាមភូមិសាស្ត្រ និងដែនសមត្ថកិច្ចរៀងៗខ្លួន។ បន្ថែមពីលើនេះក៏មានកម្លាំងអន្តរាគមន៍ក្នុងករណីមាន

សភាពការណ៍មិនប្រក្រតីណាមួយ ដោយមានការចូលរួមពីកម្លាំងនៅអគ្គស្នងការដ្ឋាននគរបាលជាតិ កងរាជអាវុធហត្ថលើផ្ទៃប្រទេស និងបណ្ដាយោធភូមិភាគនៃកងយោធពលខេមរភូមិន្ទបន្ថែមទៀត។

ជាមួយនេះ គ.ជ.ប ក៏បានរៀបចំយន្តការរបស់ខ្លួន ដោយបានបង្កើតលេខាធិការដ្ឋានសន្តិសុខបោះឆ្នោតនៃ គ.ជ.ប ដើម្បីទំនាក់ទំនង សហការចាត់ចែងកិច្ចការពារសន្តិសុខ ជាមួយគណៈកម្មការរៀបចំការបោះឆ្នោតគ្រប់លំដាប់ថ្នាក់។

ដោយមានកិច្ចសហការរវាង គ.ជ.ប និង គ.ស.អ បានបើកកិច្ចប្រជុំចំនួន ២លើក គឺលើកទី១ នៅថ្ងៃទី២៨ ខែមីនា ឆ្នាំ២០២២ ដើម្បីផ្សព្វផ្សាយផែនការអន្តរស្ថាប័ន ដល់រចនាសម្ព័ន្ធសន្តិសុខបោះឆ្នោត និងភាគីពាក់ព័ន្ធទាំងអស់ និង លើកទី២ នៅថ្ងៃទី២៩ ខែមេសា ឆ្នាំ២០២២ ដើម្បីត្រួតពិនិត្យឡើងវិញ និងជំរុញការងារនៅមុនដំណាក់កាលឃោសនាបោះឆ្នោត។ គ.ជ.ប គ.ស.អ បានចេញសេចក្តីណែនាំ និងសេចក្តីណែនាំរួមដោយឡែកៗពីគ្នា សំដៅជំរុញកិច្ចសហការការងារសន្តិសុខ ឱ្យបានរលូនល្អ និងមានប្រសិទ្ធភាព គណៈបញ្ជាការឯកភាពរដ្ឋបាលរាជធានី ខេត្ត និងគណៈកម្មការរៀបចំការបោះឆ្នោតគ្រប់លំដាប់ថ្នាក់ បានកសាងផែនការដាក់ស្តែងសម្រាប់កិច្ចការពារសន្តិសុខ សណ្តាប់ធ្នាប់ និងសុវត្ថិភាពការបោះឆ្នោតក្នុងដែនសមត្ថកិច្ចរបស់ខ្លួន និងការអប់រំ ផ្សព្វផ្សាយដល់ភ្នាក់ងារសន្តិសុខបោះឆ្នោត អំពីច្បាប់ បទបញ្ញា និងនីតិវិធី ក្រមសីលធម៌ ព្រមទាំងគោលការណ៍ណែនាំផ្សេងៗ។

ផ្អែកតាមផែនការ គោលការណ៍ណែនាំរបស់ គ.ជ.ប និង គ.ស.អ យន្តការសន្តិសុខអចិន្ត្រៃយ៍របស់រាជរដ្ឋាភិបាល និង គ.ជ.ប បានសហការជាមួយគ្នាបានល្អ ជាពិសេសលើការរៀបចំឱ្យមានកិច្ចប្រជុំចម្រុះក្នុងគោលដៅជួបពិភាក្សាស្វែងរកដំណោះស្រាយសមស្របតាមរយៈកិច្ចប្រជុំប្រចាំសប្តាហ៍រវាង លធ.ខប ឬ គធ.ខប គណៈបញ្ជាការឯកភាពរដ្ឋបាលគ្រប់លំដាប់ថ្នាក់ និងកងកម្លាំងប្រដាប់អាវុធគ្រប់ប្រភេទ តំណាងគណបក្សនយោបាយ និងអង្គការមិនមែនរដ្ឋាភិបាលនៅក្នុងរាជធានី ខេត្ត។ សមាជិកកងកម្លាំងនគរបាលជាតិ កងយោធពលខេមរភូមិន្ទ និងកងរាជអាវុធហត្ថ ត្រូវបានចាត់តាំងឱ្យបំពេញភារកិច្ចជាភ្នាក់ងារសន្តិសុខបោះឆ្នោត តាមចំនួនដែលបានកំណត់ ដើម្បីការពារសន្តិសុខ និងសណ្តាប់ធ្នាប់សាធារណៈ និងតាមគោលដៅកំណត់ក្នុងដំណើរការបោះឆ្នោតនីមួយៗ។ គោលដៅសំខាន់ៗមានដូចជា ទីកន្លែងបិទផ្សាយបញ្ជីបោះឆ្នោត បញ្ជីទីតាំងការិយាល័យចុះឈ្មោះបោះឆ្នោត និងការិយាល័យបោះឆ្នោត បញ្ជីបេក្ខជនឈរឈ្មោះ និងលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោត ទីតាំងការិយាល័យចុះឈ្មោះបោះឆ្នោតនៅតាមសាលាឃុំ សង្កាត់ និងការិយាល័យចុះឈ្មោះចល័តតាមភូមិ ទីស្នាក់ការ គធ.ខប គឃ.សប ទីតាំងការិយាល័យបោះឆ្នោត និង ការិយាល័យរាប់សន្លឹកឆ្នោត ទីកន្លែងធ្វើសកម្មភាពឃោសនាបោះឆ្នោត ក្បួនឃោសនាបោះឆ្នោតរបស់គណបក្សនយោបាយ និងក្បួនដឹកជញ្ជូនសម្ភារៈ ឯកសារបោះឆ្នោតពីគោលដៅមួយទៅគោលដៅមួយទៀត។

គ.ស.អ បានប្រើប្រាស់កម្លាំងសន្តិសុខ ដូចខាងក្រោម ៖

- ដំណាក់កាលចុះឈ្មោះបោះឆ្នោត មានកម្លាំងសរុបចំនួន ១១,៤៦៤នាក់ ក្នុងនោះ នគរបាលជាតិចំនួន ៣,៣០៤ នាក់ កងរាជអាវុធហត្ថចំនួន ៤,០៨០នាក់ និងកងយោធពលខេមរភូមិន្ទចំនួន ៤,០៨០នាក់
- ដំណាក់កាលឃោសនាបោះឆ្នោត មានកម្លាំងសរុបចំនួន ១៩,៧២៤នាក់ ក្នុងនោះនគរបាលជាតិចំនួន ១៥,៦៤៤ នាក់ កងរាជអាវុធហត្ថចំនួន ៤,០៨០នាក់ និងកងយោធពលខេមរភូមិន្ទចំនួន ៤,០៨០នាក់
- ដំណាក់កាលបោះឆ្នោត និងរាប់សន្លឹកឆ្នោត មានកម្លាំងសរុបចំនួន ៨០,៣៥៦នាក់ ក្នុងនោះ នគរបាលជាតិចំនួន ៧៤,៣១០ នាក់ កងរាជអាវុធហត្ថចំនួន ២,២៤០នាក់ កងយោធពលខេមរភូមិន្ទចំនួន ២,៨៤០នាក់ និង គណៈបញ្ជាការឯកភាពរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ចំនួន ៩៦៦នាក់។

ម្យ៉ាងទៀតក្នុងគោលបំណងទប់ស្កាត់ និងកាត់បន្ថយការប្រើប្រាស់អំពើហិង្សា គ្រោះថ្នាក់ចរាចរណ៍ គ្រោះថ្នាក់សង្គម និងការប្រព្រឹត្តបទល្មើសនានា រាជរដ្ឋាភិបាលបានដាក់ចេញនូវសេចក្តីណែនាំលេខ ០២ សណន ចុះថ្ងៃទី២០ ខែឧសភា ឆ្នាំ២០២២ ដើម្បីផ្អាកការលក់ដូរ និងពិសាគ្រឿងស្រវឹងមួយថ្ងៃមុនថ្ងៃបោះឆ្នោត និងថ្ងៃបោះឆ្នោតជ្រើសរើស

ក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី៥ ឆ្នាំ២០២២ គឺថ្ងៃទី៤ និងថ្ងៃទី៥ ខែមិថុនា ឆ្នាំ២០២២។

ដំណើរការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី៥ ឆ្នាំ២០២២ ប្រព្រឹត្តទៅដោយរលូនតាមប្រតិទិនដែលបានកំណត់ ក្នុងបរិយាកាសប្រកបដោយសន្តិសុខ សុវត្ថិភាពល្អ និងមានលក្ខណៈល្អប្រសើរជាងការបោះឆ្នោតលើកមុនៗ ដោយពុំមានអំពើហិង្សា ឬសភាពការណ៍ អសន្តិសុខ ឬបាតុភាពណាមួយកើងឡើងធ្វើឱ្យជះឥទ្ធិពលដល់ដំណើរការបោះឆ្នោតឡើយ។ ភ្នាក់ងារសន្តិសុខបោះឆ្នោត បានខិតខំបំពេញភារកិច្ចរបស់ខ្លួនយ៉ាងខ្ជាប់ខ្ជួនប្រកបដោយវិជ្ជាជីវៈ និងសីលធម៌ ចាប់ពីដំណាក់កាលចុះឈ្មោះបោះឆ្នោត ចុះបញ្ជីបេក្ខជន ឃោសនាបោះឆ្នោត បោះឆ្នោត និងរាប់សន្លឹកឆ្នោត រួមទាំងការដឹកជញ្ជូនសម្ភារ ឯកសារបោះឆ្នោតទៅតាមគោលដៅនីមួយៗបានទាន់ពេលវេលា។

## VI- ភាពងាយស្រួល និងការលំបាក

### ១- ការងាយស្រួល

- គ.ជ.ប មានប្រតិទិន និងផែនការមេ និងបទបញ្ជា និងនីតិវិធីសម្រាប់ការបោះឆ្នោត ដែលជាឯកសារសំខាន់សម្រាប់កិច្ចប្រតិបត្តិការការងាររបស់ខ្លួន
- ជាទូទៅមន្ត្រីបោះឆ្នោតគ្រប់ថ្នាក់មានសមត្ថភាព យកចិត្តទុកដាក់បំពេញការងារ និងមានការទទួលខុសត្រូវខ្ពស់
- ភាគីពាក់ព័ន្ធពិសេសអាជ្ញាធរមានកិច្ចសហការល្អគ្រប់ដំណាក់កាលនៃការបោះឆ្នោត
- បញ្ជីបោះឆ្នោតមានទិន្នន័យត្រឹមត្រូវ ពេញលេញ និងមានរូបថតអ្នកបោះឆ្នោត ដែលងាយស្រួលដល់លេខាធិការ គ.ក.ប និងអ្នកបោះឆ្នោតក្នុងការផ្ទៀងផ្ទាត់ទិន្នន័យ និងអត្តសញ្ញាណអ្នកបោះឆ្នោតក្នុងពេលបោះឆ្នោត
- ការបំពេញកំណត់ហេតុនៃការរាប់សន្លឹកឆ្នោតរបស់ គ.ក.រ មានចំនួនតិច ដែលបានកាត់បន្ថយកំហុសឆ្គងក្នុងការបំពេញ និងគណនាតួលេខ
- ភ្នាក់ងារគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត ដែលមានវត្តមាននៅក្នុងការិយាល័យរាប់សន្លឹកឆ្នោត បានចុះហត្ថលេខាលើកំណត់ហេតុនៃការរាប់សន្លឹកឆ្នោត (ទ.១១០២) និងទទួលបានទម្រង់នេះពី គឃ.សប
- រាជរដ្ឋាភិបាលអនុញ្ញាតឱ្យកម្មករ និយោជិតឈប់សម្រាកដើម្បីទៅបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី៥ ឆ្នាំ២០២២ ១ថ្ងៃមុនថ្ងៃបោះឆ្នោត និង ១ថ្ងៃក្រោយថ្ងៃបោះឆ្នោត ដោយរក្សាប្រាក់ឈ្នួល និងអត្ថប្រយោជន៍ផ្សេងៗ ដែលបង្កលក្ខណៈឱ្យប្រជាពលរដ្ឋទៅបោះឆ្នោតមានអត្រាខ្ពស់គួរឱ្យកត់សម្គាល់
- ចំនួនភ្នាក់ងារនៃគណបក្សនយោបាយ អ្នកសង្កេតការណ៍ជាតិ អន្តរជាតិ និងអ្នកសារព័ត៌មានមានចំនួនច្រើនចូលរួមសង្កេតមើល និងជាសាក្សីក្នុងការបោះឆ្នោត
- ការរៀបចំផ្សព្វផ្សាយលទ្ធផលបឋមនៃការបោះឆ្នោត បានផ្តល់ភាពងាយស្រួលដល់ភាគីពាក់ព័ន្ធក្នុងការតាមដាន ពិនិត្យ និងផ្ទៀងផ្ទាត់លទ្ធផលនៃការបោះឆ្នោតតាមការិយាល័យបោះឆ្នោត និងឃុំ សង្កាត់ បានត្រឹមត្រូវ ច្បាស់លាស់ និងមានតម្លាភាព។

### ២- ការលំបាក

- **អំឡុងពេលចុះបញ្ជីបេក្ខជននៃគណបក្សនយោបាយ**
  - គណបក្សនយោបាយមួយចំនួនបំពេញឯកសារមានកំហុសច្រើន

- គណបក្សមួយចំនួនមកដាក់ពាក្យសុំមានតែទម្រង់ ១០០៨ ខ្វះឯកសារភ្ជាប់
- ការបំពេញពាក្យសុំឡើងវិញដែលមិនគ្រប់លក្ខខណ្ឌរបស់គណបក្សនយោបាយមានការយឺតយ៉ាវអូសបន្លាយពេលវេលា
- គណបក្សនយោបាយយកបញ្ជីបេក្ខជនមកដាក់ហើយ តែមានបេក្ខជនមួយចំនួនសុំលាលែង
- គណបក្សនយោបាយមួយចំនួនមិនទាន់គោរពបានត្រឹមត្រូវតាមច្បាប់ និងនីតិវិធីនៃចុះបញ្ជីបេក្ខជន
- មានការក្លែងឯកសារ និងជីវប្រវត្តិសង្ខេបរបស់បេក្ខជនឈរឈ្មោះ ដែលនាំឱ្យបេក្ខជននៃគណបក្សនយោបាយពុំមានលក្ខណសម្បត្តិត្រឹមត្រូវតាមច្បាប់
- គណបក្សនយោបាយមួយចំនួនមិនបានស្នើសុំបង្កើតគណនីប្រើប្រាស់ប្រព័ន្ធគ្រប់គ្រងការចុះបញ្ជីបេក្ខជននៃគណបក្សនយោបាយ និងគណបក្សនយោបាយមួយចំនួនទៀតស្នើសុំបង្កើតគណនីហើយប៉ុន្តែនៅរៀបចំបញ្ជីបេក្ខជនដោយដៃ
- គណបក្សនយោបាយមួយចំនួនគ្មានទីស្នាក់ការច្បាស់លាស់នៅតាមឃុំ សង្កាត់ដែលនាំឱ្យពិបាកក្នុងការទាក់ទង។

**– អំឡុងពេលបិទផ្សាយបញ្ជីបេក្ខជនដំបូង**

- ការបិទផ្សាយបញ្ជីបេក្ខជនដំបូងរបស់ គឃ.សប មួយចំនួនមានការអូសបន្លាយ ដោយសារបញ្ជីបេក្ខជននៃគណបក្សនយោបាយខ្លះត្រូវបានតម្រូវឱ្យកែតម្រូវ ឬ/និងកំពុងបន្តនីតិវិធីបណ្តឹងទៅតាមកំណត់ច្បាប់
- មានបេក្ខជនមួយចំនួនសុំលាឈប់មិនឈរឈ្មោះឱ្យគណបក្សនយោបាយ។

**– អំឡុងពេលបញ្ចូលទិន្នន័យក្នុងប្រព័ន្ធកម្មវិធីគ្រប់គ្រងការចុះបញ្ជីបេក្ខជននៃគណបក្សនយោបាយ**

- បញ្ជីរាយនាមបេក្ខជនមួយចំនួនមានការសរសេរខុសអក្ខរាវិរុទ្ធ ឈ្មោះ ថ្ងៃខែឆ្នាំកំណើតជាមួយនឹងបញ្ជីបោះឆ្នោតផ្លូវការ ឆ្នាំ២០២១
- ការបញ្ចូលប្រវត្តិរូបនៅខ្វះទិន្នន័យ ខ្វះស្នាមមេដៃ កាលបរិច្ឆេទ ឬខ្វះហត្ថលេខារបស់បេក្ខជនដែលតម្រូវឱ្យធ្វើការស្កេនម្តងទៀត។

**– អំឡុងពេលឃោសនាបោះឆ្នោត**

- គណបក្សនយោបាយមួយចំនួនធ្វើសកម្មភាពឃោសនាបោះឆ្នោតមុនកាលបរិច្ឆេទកំណត់
- គណបក្សនយោបាយមួយចំនួនធ្វើសកម្មភាពឃោសនាបោះឆ្នោតមិនគោរពគោលការណ៍ចែងក្នុងច្បាប់បោះឆ្នោត។

**– អំឡុងពេលជ្រើសរើសសមាសភាព គ.ក.ប**

- គ.ខ.ប កំពង់ស្ពឺ បានធ្វើសំណើសុំបន្តការទទួលពាក្យចំនួន ១ថ្ងៃទៀត ដោយនៅថ្ងៃចុងក្រោយនៃការទទួលពាក្យមានភ្លៀងធ្លាក់ខ្លាំង ជាហេតុបណ្តាលឱ្យបេក្ខជនមកដាក់ពាក្យមិនគ្រប់ចំនួនតាមតម្រូវការ ដោយខ្វះបេក្ខជនសរុបចំនួន ១៧នាក់
- គ.ខ.ប មណ្ឌលគិរីខ្វះបេក្ខជន ៦០នាក់នៅការិយាល័យចំនួន ១៨ ក្នុងឃុំចំនួន ១១ ដោយពុំមានបេក្ខជនមកដាក់ពាក្យជាហេតុនាំឱ្យ គ.ខ.ប បានយកបេក្ខជនពីឃុំផ្សេងៗដែលមានបេក្ខជនដាក់ពាក្យច្រើនទៅបំពេញបន្ថែម

- នៅតាមឃុំ សង្កាត់ភាគច្រើនពុំសូវមានបេក្ខជនច្រើនមកដាក់ពាក្យនោះទេគឺក្នុងមួយតំណែងមានបេក្ខជនដាក់ពាក្យតែមួយនាក់ប៉ុណ្ណោះ ការទទួលខុសត្រូវខ្ពស់ ហើយអ្នកខ្លះមិនចង់ប្រកួតប្រជែងជាមួយបេក្ខជនចាស់ដែលមានបទពិសោធន៍
- រយៈពេលបំពេញការងារខ្លីពេកបេក្ខជនមិនសូវចាប់អារម្មណ៍ដាក់ពាក្យបម្រើការងារ
- កង្វះធនធានមនុស្សនៅទីជនបទ និងតំបន់ដាច់ស្រយាល
- នៅតាមឃុំ សង្កាត់ភាគច្រើនពុំមានបេក្ខជនគ្រប់ចំនួនសម្រាប់ការធ្វើសម្រាំងពាក្យក្នុងមួយមុខតំណែង ៣រូប តាមលក្ខខណ្ឌដែលបានកំណត់ដោយ គ.ជ.ប
- ក្នុងមួយតំណែងមានបេក្ខជនដាក់ពាក្យតែមួយនាក់។

– **អំឡុងពេល១ថ្ងៃ មុនថ្ងៃបោះឆ្នោត**

- អាកាសធាតុនៅតំបន់នៃខេត្តមួយចំនួនមានភ្លៀងធ្លាក់
- ទីតាំងការិយាល័យបោះឆ្នោតដែលសាងសង់អំពីតង់នៃ គធ.ខប មួយចំនួនដួលរលំដោយសារខ្យល់កន្ត្រាក់ និងភ្លៀង
- បញ្ជីបោះឆ្នោតផ្លូវការដែលបានបិទផ្សាយនៅការិយាល័យបោះឆ្នោតចំនួន ១៥ នៃ គ.ធ.ប ភ្នំពេញត្រូវបានខូចខាតស្ទើរទាំងស្រុង។

– **អំឡុងពេលបោះឆ្នោត និងរាប់សន្លឹកឆ្នោត**

- អ្នកបោះឆ្នោតមួយចំនួនពុំមានឯកសារដើម្បីប្រើប្រាស់ក្នុងការបោះឆ្នោត
- ប្រជាពលរដ្ឋមួយចំនួនតូចមានទិន្នន័យក្នុងបញ្ជីបោះឆ្នោតខុសពីទិន្នន័យក្នុង អ.ខ។

## VII- សំណូមពរ

តាមរយៈរបាយការណ៍បូកសរុបរបស់គណៈកម្មការរាជធានី ខេត្តរៀបចំការបោះឆ្នោត និងរបស់អគ្គនាយកដ្ឋាន និងអង្គភាពផ្សេងៗទៀតចំណុះអគ្គលេខាធិការដ្ឋាន គ.ជ.ប បានកត់សម្គាល់ឃើញមានសំណូមពរលើការងារ ក៏ដូចជាសម្ភារបរិក្ខារដូចខាងក្រោម ៖

– ស្នើសុំផ្តល់ម៉ាស៊ីនបញ្ចាំងស្លាយ (Projector) ដល់គ្រប់ គធ.ខប សម្រាប់វគ្គបណ្តុះបណ្តាលនៅតាមមណ្ឌលប្រមូលផ្តុំ ដោយកន្លងមកខ្ចីពីសាលារៀន ឬសាលាស្រុក ឬកន្លែងផ្សេងៗទៀត
– គធ.ខប មួយចំនួនស្នើសុំ គ.ជ.ប ជួយសាងសង់ឃ្លាំងដាក់សម្ភារបរិក្ខារឱ្យបានសមស្រប
– គធ.ខប ទាំង២៥ ស្នើសុំ គ.ជ.ប ពន្លឿនការចែកសៀវភៅណែនាំ សៀវភៅជំនួយស្មារតី និងឯកសារពាក់ព័ន្ធនឹងការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោត និងការបោះឆ្នោតឱ្យបានលឿនទាន់ពេលវេលាសម្រាប់យកទៅបង្រៀននៅពេលបើកវគ្គបណ្តុះបណ្តាលបន្ត
– គឃ.សប ស្នើសុំ គ.ជ.ប អនុវត្តកម្មវិធីស្វែងយល់អំពីការបោះឆ្នោតបន្តទៀត ទាំងការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោត និងការបោះឆ្នោត
– ស្នើសុំបន្ថែមរយៈពេលបណ្តុះបណ្តាល និងដំឡើងប្រាក់កម្រៃដល់ គ.ក.ប
– ស្នើសុំប្រាក់ឧបត្ថម្ភបន្ថែមដល់មន្ត្រីដែលទៅបំពេញការងារនៅការិយាល័យបោះឆ្នោតដែលស្ថិតនៅតំបន់ដាច់ស្រយាល
– ប្រជាពលរដ្ឋសំណូមពរដល់ គ.ជ.ប ផ្តល់ ឯ.អ រហូតដល់ថ្ងៃបោះឆ្នោត និងអនុញ្ញាតឱ្យប្រើ អ.ខ ប្រភេទចាស់ ឬហួសសុពលភាពទៅបោះឆ្នោតបាន។

## VIII- សេចក្តីសន្និដ្ឋាន

ដំណើរការរៀបចំការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី៥ ឆ្នាំ២០២២ បានឆ្លងកាត់ដំណាក់កាលដ៏លំបាកមួយចំនួនដូចជា ការប្រយុទ្ធប្រឆាំងនឹងជំងឺកូវីដ-១៩ ពិសេសក្នុងដំណាក់កាលពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោត ឆ្នាំ២០២១ ការរងផលប៉ះពាល់ពីគ្រោះធម្មជាតិរួមមាន ភ្លៀង ជំនន់ និងខ្យល់កន្ត្រាក់នៅតំបន់ខ្លះ និងការប្រឈមនឹងបញ្ហាបច្ចេកទេសមួយចំនួន ប៉ុន្តែជាទិដ្ឋភាពរួម ដំណើរការបោះឆ្នោតបានប្រព្រឹត្តទៅដោយរលូនល្អ តាមច្បាប់ បទបញ្ញា និងនីតិវិធី និងប្រតិទិនកំណត់ ក្នុងបរិយាកាសប្រកបដោយសុខសន្តិភាព សន្តិសុខ សុវត្ថិភាព និងសណ្តាប់ធ្នាប់ល្អ គ្មានអំពើហិង្សា និងគ្មានការគំរាមកំហែង។

នៅមុនថ្ងៃបោះឆ្នោត **ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា** បានប្រោសព្រះរាជទាននូវព្រះរាជសារផ្ញើជូនជនរួមជាតិ បងប្អូន កូនក្មួយ មេត្តាប្រើសិទ្ធិសេរីភាព បោះឆ្នោតទៅតាមសតិសម្បជញ្ញៈរបស់ខ្លួនម្នាក់ៗដែលមានទំនុកចិត្តទៅលើបេក្ខជន ឬគណបក្សនយោបាយណាមួយ។

ការកែលម្អ និងធ្វើឱ្យប្រសើរឡើងទាំងក្នុងក្របខ័ណ្ឌច្បាប់ និងបច្ចេកទេស ពិសេសការពង្រឹង និងពង្រីកវិសាលភាពនៃការប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន ដើម្បីជាជំនួយដល់ការគ្រប់គ្រង និងបច្ចេកទេសក្នុងការរៀបចំការបោះឆ្នោត បានបង្កើនប្រសិទ្ធភាពការងារ តម្លាភាព ភាពឆាប់រហ័ស និងជំនឿទុកចិត្តលើការងារបោះឆ្នោត។

ប្រជាពលរដ្ឋដ៏ច្រើនកុះករចំនួន ៨០.៣២% នៃអ្នកមានឈ្មោះក្នុងបញ្ជីបោះឆ្នោតបានអញ្ជើញទៅបោះឆ្នោតដោយសេរី ដោយរីករាយ និងទំនុកចិត្ត ដោយគ្មានការភ័យខ្លាច និងការគាបសង្កត់។

ក្រោយការបោះឆ្នោត គណបក្សនយោបាយឈរឈ្មោះបោះឆ្នោត និងអង្គការសង្កេតការណ៍បោះឆ្នោតជាតិភាគច្រើនបានចេញសេចក្តីថ្លែងការណ៍កោតសរសើរ និងគាំទ្រការបោះឆ្នោត។ បន្ថែមលើនេះ អង្គការសង្កេតការណ៍បោះឆ្នោតអន្តរជាតិភាគច្រើនបានចេញសេចក្តីថ្លែងការណ៍ វាយតម្លៃខ្ពស់ចំពោះដំណើរការនៃការរៀបចំការបោះឆ្នោត និងពិសេសពីបរិយាកាសល្អប្រសើរនៃការបោះឆ្នោត ដោយលើកឡើងជាអាទិ៍ថា “ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី៥ ឆ្នាំ២០២២ នៅកម្ពុជា ប្រព្រឹត្តទៅដោយជោគជ័យ ដោយសេរី យុត្តិធម៌ ស្មើភាព សន្តិភាព តម្លាភាព និងស្តង់ដាអន្តរជាតិ” “ការបោះឆ្នោតនៅកម្ពុជាបានដំណើរការតាមគន្លងលទ្ធិប្រជាធិបតេយ្យ សេរី ពហុបក្ស ប្រកបដោយជោគជ័យគួរឱ្យកត់សម្គាល់”។ ល។

ជោគជ័យនៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី៥ នេះ គឺជាសមិទ្ធផលថ្មីមួយទៀតនៃលទ្ធិប្រជាធិបតេយ្យ និងការកែទម្រង់ការបោះឆ្នោតនៅកម្ពុជា។ លទ្ធផលនេះគឺអាស្រ័យដោយមានការដឹកនាំដ៏ត្រឹមត្រូវរបស់ថ្នាក់ដឹកនាំ គ.ជ.ប ការអនុវត្តការងារប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់របស់មន្ត្រីបោះឆ្នោតគ្រប់លំដាប់ថ្នាក់ និងកិច្ចសហការឧបត្ថម្ភល្អរបស់ស្ថាប័នជាតិ រាជរដ្ឋាភិបាល គណៈបញ្ជាការសន្តិសុខអចិន្ត្រៃយ៍សម្រាប់ការបោះឆ្នោត អាជ្ញាធរដែនដីគ្រប់លំដាប់ថ្នាក់ ប្រជាពលរដ្ឋអ្នកបោះឆ្នោតទាំងអស់ និងភាគីពាក់ព័ន្ធដែលមានគណបក្សនយោបាយ អង្គការសង្កេតការណ៍បោះឆ្នោត និងអ្នកសារព័ត៌មានជាតិ និងអន្តរជាតិ។

ថ្ងៃអង្គារ ៥កើត ខែស្រាពណ៍ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦

រាជធានីភ្នំពេញ ថ្ងៃទី២ ខែសីហា ឆ្នាំ២០២២

ជ.គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត

ប្រធាន

ប្រាជ្ញ ចន្ទ